ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមិទ្ធផល ព្រឹទ្ធសភា នីតិកាលទី ១

១៩៩៩-២០០៥

រៀបចំ និងចងក្រងដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ខែមិថុនា ឆ្នាំ២០០៥

មាតិកា

លេខរៀង	ចំណងជើង	ទំព័រ
សារបស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា		
១	ប្រវត្តិរបស់ព្រឹទ្ធសភា	១
២	បញ្ជីឈ្មោះសមាជិកព្រឹទ្ធសភា តាមគណបក្សនយោបាយ (១៩៩៩)	៧
៣	បញ្ជីឈ្មោះសមាជិកព្រឹទ្ធសភា តាមគណបក្សនយោបាយ (២០០៥)	១០
៤	បញ្ជីឈ្មោះសមាជិកព្រឹទ្ធសភាចេញ-ចូល	១៣
៥	តួនាទី ភារកិច្ច របស់ព្រឹទ្ធសភា	១៥
៦	ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា	១៦
៧	នីតិវិធីពិនិត្យ និងអនុម័តអត្ថបទច្បាប់	១៧
៨	សកម្មភាពរបស់ព្រឹទ្ធសភា	២០
៩	ការផ្តួចផ្តើមធ្វើច្បាប់	៦៥
១០	សញ្ញាសក្តិ និងឯកសណ្ឋានរបស់សមាជិក សមាជិកាព្រឹទ្ធសភា	៦៦
១១	សេចក្តីសំរេចផ្សេងៗរបស់ក្រុមប្រឹក្សាធម្មនុញ្ញទាក់ទងនឹងព្រឹទ្ធសភា	៧២
១២	សកម្មភាពរូបភាពថ្នាក់ដឹកនាំព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា	៩១
១៣	អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា	១១២
១៤	សកម្មភាពរូបភាពថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា	១២៤
១៥	ព្រឹទ្ធសភាបច្ចុប្បន្ន	១៣៤
១៦	ព្រឹទ្ធសភាពីអតីតកាល	១៣៨

ឧបសម្ព័ន្ធ :

ក. បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងប្រការ ៤៤

ខ. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

គ. ផែនទីប្រទេសកម្ពុជា ចែកជាភូមិភាគ

ក្របមុខ : អគារក្រហម

ក្របក្រោយ : អគារបណ្ណាល័យ

ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាររបស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា

នាឆ្នាំ១៩៩៩ ព្រះរាជាណាចក្រកម្ពុជា បានបង្កើតនូវស្ថាប័នព្រឹទ្ធសភាដែលជាផ្នែកមួយនៃអង្គនីតិប្បញ្ញត្តិកម្ពុជា ដើម្បីរួមចំណែកយ៉ាងចំបងថ្លៃថ្លា ដល់ការធានានូវស្ថិរភាពនយោបាយ ការបង្រួបបង្រួម ផ្សះផ្សាជាតិ ប្រជាធិបតេយ្យភាវូបនីយកម្មសង្គម សំដៅធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសជាតិ ជាពិសេស ផ្តល់នូវវិភាគទានដ៏សំខាន់ដល់ការកែទម្រង់ទាំងឡាយ និងការធ្វើសមាហរណកម្មកម្ពុជានៅក្នុងក្របខ័ណ្ឌតំបន់ និងលើឆាកអន្តរជាតិ ។

ក្នុងនីតិកាលទី១ របស់ខ្លួននេះ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សំរេចបាននូវសមិទ្ធផលយ៉ាងត្រចះត្រចង់ និងបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការកសាងប្រព័ន្ធច្បាប់ជាធរមានរបស់រដ្ឋ និងកសាងនូវមូលដ្ឋានគ្រឹះជាសក្តានុពលផ្ទាល់ខ្លួន សំរាប់ការពង្រឹងលក្ខន្តិកៈ និងអត្តសញ្ញាណជាស្ថាប័នជាន់ខ្ពស់ទទួលខុសត្រូវចំពោះមុខជាតិ និងប្រជាពលរដ្ឋទាំងមូល ។ ក្នុងឆ្នាំ២០០៥នេះ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវបានប្រសូត្រឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យសេរីនៅកម្ពុជា និងកំណត់អត្តសញ្ញាណច្បាស់លាស់របស់ស្ថាប័ន ។

នេះជាសមិទ្ធផលជាប្រវត្តិសាស្ត្ររបស់ព្រឹទ្ធសភានីតិកាលទី១ ដែលបានបើកឡើងនូវទំព័រថ្មី ការរួមចំណែកសំរាប់ពេលអនាគតដ៏វែងឆ្ងាយ ។

ជាការពិតណាស់ ជោគជ័យរបស់ព្រឹទ្ធសភានីតិកាលទី១ ពិតជាកើតចេញមកពីការខិតខំប្រឹងប្រែងពីសំណាក់សមាជិក សមាជិកាព្រឹទ្ធសភា និងការគាំទ្រយ៉ាងពេញទំហឹងពីមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រពៃ និងស្និតល្មួតពីគ្រប់ស្ថាប័នជាតិ អង្គការជាតិ និងអន្តរជាតិ និងសហគមន៍អន្តរជាតិ ដែលបានផ្តល់នូវការឧបត្ថម្ភទាំងស្មារតី និងសម្ភារៈដ៏ថ្លៃថ្លា ។

ទូលបង្គំ-ខ្ញុំ សូមឧទ្ទិសកម្រងស្នាដៃដ៏ត្រចះត្រចង់ទាំងនេះជូនដល់សមាជិក សមាជិកាព្រឹទ្ធសភានីតិកាលទី១ ដែលបានចូលរួមចំណែក ជំរុញស្ថាប័ននីតិប្បញ្ញត្តិថ្មីនេះ ប្រកបដោយជោគជ័យ ស្របតាមតួនាទី និងភារកិច្ចកំណត់ក្នុងរដ្ឋធម្មនុញ្ញ ដើម្បីនាំនាវាកម្ពុជាឱ្យឈានឆ្ពោះទៅរកវឌ្ឍនភាព សម្បូរសប្បាយ រុងរឿងដូចបណ្តាអារ្យប្រទេស និងឆ្លើយតបទៅតាមការវិវត្តរបស់សកលលោកនាយុគសម័យបច្ចុប្បន្ននេះ ។

ភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៥

ជា ស៊ីម

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855 23) 211441, 211442, 211443 ទូរសារ : (855 23) 211446, R-mail : oum_sarith@camnet.com.kh

១. ប្រវត្តិរបស់ព្រឹទ្ធសភា

តាមរដ្ឋធម្មនុញ្ញ នៃព្រះរាជអាណាចក្រកម្ពុជាទី ១ ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៤៧ បានចែងកំណត់ឱ្យប្រទេសកម្ពុជាមានស្ថាប័ននីតិប្បញ្ញត្តិពីរ គឺរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។ ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ជាស្ថាប័នមួយ មានតួនាទីជាអង្គការនីតិប្បញ្ញត្តិដូចរដ្ឋសភាដែរ គឺមានសិទ្ធិក្នុងការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ ។ នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧០ ប្រទេសកម្ពុជាត្រូវបានប្រកាសជាសាធារណរដ្ឋខ្មែរតាមច្បាប់ធម្មនុញ្ញលេខ ៤៤២ . ៧០ បរ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៧០ ។ ស្ថាប័នកំពូល១របស់ព្រះរាជាអាណាចក្រកម្ពុជា ត្រូវរក្សាទុកដដែលលើកលែងតែស្ថាប័នព្រះមហាក្សត្រ ដែលត្រូវលុបបំបាត់ ។ នាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧២ រដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋខ្មែរត្រូវបានប្រកាសឱ្យប្រើតាមបញ្ញត្តិលេខ ១៩១៧២ បសខ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧២ បានចែងកំណត់ឱ្យប្រទេសកម្ពុជាអនុវត្តរបបសភាពីរដែលមានរដ្ឋសភា និងព្រឹទ្ធសភា ។

បន្ទាប់ពីការបោះឆ្នោតសកល ដែលរៀបចំធ្វើឡើងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ហៅកាត់ថា **UNTAC**[១] នៅខែ ឧសភា ឆ្នាំ ១៩៩៣ សភាធម្មនុញ្ញបានចាប់បដិសន្ធិឡើង នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៣ ។

នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ សភាធម្មនុញ្ញបានអនុម័តរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ រដ្ឋធម្មនុញ្ញនេះ បានដាក់ព្រះរាជាណាចក្រកម្ពុជាឱ្យស្ថិតនៅក្រោមរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ហើយបានចែងថា រាជរដ្ឋាភិបាលកម្ពុជាត្រូវបំពេញការងារនៅក្រោមក្របខ័ណ្ឌនៃលទ្ធិប្រជាធិបតេយ្យអាស្រ័យសភា ។

ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើង បន្ទាប់ពីកិច្ចប្រជុំរវាងថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សនយោបាយធំៗទាំងពីរ នៅថ្ងៃទី១២ និងទី ១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រោមព្រះរាជាធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** នៅព្រះបរមរាជវាំង ក្នុងគោលបំណងបញ្ចប់វិបត្តិនយោបាយ លើកកំពស់ការបង្រួបបង្រួមផ្សះផ្សាជាតិ និងពង្រឹងស្ថិរភាពនយោបាយ ដោយបានឯកភាពធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តាមច្បាប់ធម្មនុញ្ញ ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ : នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ។

ការបង្កើតស្ថាប័នព្រឹទ្ធសភានេះ គឺជាព្រឹត្តិការណ៍នយោបាយដ៏សំខាន់មួយក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលបានបង្ហាញឱ្យឃើញនូវពន្លឺថ្មីមួយ សំរាប់អនាគតនៃប្រទេសកម្ពុជា ដើម្បីស្ថិរភាពផ្នែកនយោបាយ ព្រមទាំងបង្ហាញអោយឃើញពីការប្តេជ្ញាចិត្តជាបន្តបន្ទាប់ក្នុងការកសាងលទ្ធិប្រជាធិបតេយ្យ និងការពង្រឹងនីតិរដ្ឋ ។ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ។

---

[១] អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា

ថ្នាក់ដឹកនាំព្រឹទ្ធសភា

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស
អនុប្រធានទី ១ ព្រឹទ្ធសភា

ឯកឧត្តម ប៉ោ ប៊ុនស្រ៊ី
អនុប្រធានទី ២ ព្រឹទ្ធសភា

សម័យប្រជុំលើកទី១ នីតិកាល

រូបថតអនុស្សាវរីយ៍ ពេលបើកនីតិកាលទី ១ នៅមន្ទីរព្រឹទ្ធសភា ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩

ៈទី ២៥ ខែ មីនា ឆ្នាំ១៩៩៩

បមុបថតអនុស្សាវរីយ៍ ពេលសច្ចាប្រណិធាន នៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩

២. បញ្ជីឈ្មោះសមាជិកព្រឹទ្ធសភា តាមគណបក្សនយោបាយ (១៩៩៩)

សមាសភាពតែងតាំងដោយព្រះមហាក្សត្រ

	ថ្ងៃ ខែ ឆ្នាំ កំណើត
១. ឯកឧត្តម **អៀង បណ្ណាការ**	២១-០២-១៩៣១
២. លោកជំទាវ **កែវ ប៊ុនធូក**	២៦-១២-១៩៣០

សមាសភាពគណបក្សប្រជាជនកម្ពុជា

	ថ្ងៃ ខែ ឆ្នាំ កំណើត
១. សម្តេច **ជា ស៊ីម**	១៥-១១-១៩៣២
២. ឯកឧត្តម **អ៊ុក ប៊ុនឈឿន**	០៥-០៣-១៩៤៣
៣. ឯកឧត្តម **ឈា ចាំង**	១៥-១១-១៩៣៥
៤. ឯកឧត្តម **ហង់ ជួន**	១៣-០៧-១៩៣៧
៥. ឯកឧត្តម **ចាន់ ភិន**	១២-០៤-១៩៣៨
៦. ឯកឧត្តម **ឆាំង សុខ**	០៥-០៥-១៩៣៩
៧. ឯកឧត្តម **អ៊ុង ឌី**	៣០-០៦-១៩៤៩
៨. ឯកឧត្តម **ឈិត គឹមយាត**	០៨-០៧-១៩៤៧
៩. លោកជំទាវ **ឌី ប៉ូរ៉ាស៊ី**	០១-០៨-១៩៣៩
១០. លោកជំទាវ **មាន សំអាន**	១៦-០៦-១៩៥៦
១១. លោកជំទាវ **ឈូក ឈឹម**	១០-១០-១៩៥៤
១២. ឯកឧត្តម **ទេព ងន**	០១-០១-១៩៤៧
១៣. ឯកឧត្តម **ស៊ឹម កា**	១៩-០៤-១៩៤៨
១៤. ឯកឧត្តម **រស់ ស្រេង**	១៥-០៣-១៩៣៩
១៥. ឯកឧត្តម **នូវ ផ្លាមកេសន**	១៤-០៤-១៩៣២
១៦. ឯកឧត្តម **ពៅ សាអ៊ាត**	២០-០៧-១៩៤៣
១៧. ឯកឧត្តម **ម៉ុល ណារ៉ាល់**	១១-០៧-១៩៣០
១៨. ឯកឧត្តម **សេក សំអៀត**	១៥-០៦-១៩៣០
១៩. ឯកឧត្តម **ប៉េង ឆាត់**	១១-០១-១៩៤៩

២០. ឯកឧត្តម **ហៀយ កើក**	១០-០៤-១៩៣៩
២១. ឯកឧត្តម **គង ចន្ទ**	០២-០៦-១៩៣២
២២. ឯកឧត្តម **ស៊ើយ កែវ**	០៣-០៦-១៩៣៧
២៣. ឯកឧត្តម **កែវ សាន**	០៣-០៣-១៩៣៥
២៤. ឯកឧត្តម **ស៊ិន សុខ**	១៥-១០-១៩៤៨
២៥. ឯកឧត្តម **អ៊ុក ប្រាថ្នា**	១៥-០៩-១៩៥៣
២៦. ឯកឧត្តម **ជា ជេដ្ឋ**	១៣-០១-១៩៤៩
២៧. ឯកឧត្តម **ទ៊ាន់ ម៉ាត់**	០១-០១-១៩៤៨
២៨. ឯកឧត្តម **ថៃ ស៊ីផាន**	០១-០៧-១៩៥៤
២៩. លោកជំទាវ **ពុំ ស៊ីចាន់**	០១-១១-១៩៤៧
៣០. ឯកឧត្តម **ម៉ែន សារុន**	១៩-០៨-១៩៤៦
៣១. ឯកឧត្តម **ថុង ចន់**	០៦-០៨-១៩៤២

សមាសភាពគណបក្សហ្វ៊ុនស៊ិនប៉ិច

	ថ្ងៃ ខែ ឆ្នាំ កំណើត
១. ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស**	០១-០២-១៩៣៦
២. ឯកឧត្តម **ញឹក ប៊ុនឆៃ**	០៧-០២-១៩៥៦
៣. ឯកឧត្តម **ឃួន ហ្វាង**	២០-០២-១៩៣៦
៤. ឯកឧត្តម **ឃួន ប្លែវើត**	១៩-០១-១៩៤០
៥. ឯកឧត្តម **សឹង អៀម**	០២-០១-១៩៣៨
៦. ឯកឧត្តម **គឹម សុខា**	២៧-០៦-១៩៥៣
៧. ឯកឧត្តម **សាប៊ូ ឃាចា**	១៦-០១-១៩៤៣
៨. ឯកឧត្តម **អ៊ុង ស៊ុម**	០៧-០១-១៩៥០
៩. ឯកឧត្តម **ជា ប៉េងឈាង**	២០-០៨-១៩៥២
១០. ឯកឧត្តម **ខៀវ សន**	០៨-០៣-១៩៤០
១១. ឯកឧត្តម **ខៀវ សួន**	១៣-០៤-១៩៤៥
១២. លោកជំទាវ **ម៉ែន ម៉ាណី**	០១-១០-១៩៤៥
១៣. លោកជំទាវ **សម កនិដ្ឋា**	០២-០៨-១៩៥១

១៤. លោកជំទាវ **ម៉ិច សូម៉ាលី**	៣០-០៦-១៩៥៣
១៥. ឯកឧត្តម **ឆាយ ប៊ិនឡាយ**	០៣-០១-១៩៤៧
១៦. ឯកឧត្តម **ស៊ិន ប៊ូ**	០៧-០៩-១៩៤៧
១៧. ឯកឧត្តម **ប្រាក់ ទ៊ាន់នី**	០១-០២-១៩៤០
១៨. ឯកឧត្តម **ស៊ីម សូលី**	១៤-០៧-១៩៤២
១៩. ឯកឧត្តម **ជា គីម**	១៥-១០-១៩៤៨
២០. ឯកឧត្តម **យឹង គីមស្រួន**	២១-១១-១៩៥០
២១. ឯកឧត្តម **ហាស សារឿន**	០៩-០៦-១៩៥០

សមាសភាពគណបក្ស សម រង្ស៊ី

	ថ្ងៃ ខែ ឆ្នាំ កំណើត
១. ឯកឧត្តម **គង់ គាំ**	០៦-០៤-១៩៤១
២. ឯកឧត្តម **ម៉េង រីតា**	១២-០៣-១៩៥៥
៣. ឯកឧត្តម **ទុក ម៉ឿន**	៣១-១២-១៩៤៨
៤. ឯកឧត្តម **ថាច់ សេដ្ឋា**	១៤-០៥-១៩៥៣
៥. ឯកឧត្តម **អ៊ូ ប៊ុនឡុង**	០៧-១២-១៩៣៤
៦. ឯកឧត្តម **ហ៊ុត ទ្រី**	០៥-០៥-១៩៣៣
៧. ឯកឧត្តម **ចៅ ផល្លី**	១៥-០១-១៩៥៣

៣. បញ្ជីឈ្មោះសមាជិកព្រឹទ្ធសភា តាមគណបក្សនយោបាយ (២០០៥)

សមាសភាពតែងតាំងដោយព្រះមហាក្សត្រ

	ថ្ងៃ ខែ ឆ្នាំ កំណើត
១. ឯកឧត្តម **អៀច បណ្ណាការ**	២១-០២-១៩៣១
២. ឯកឧត្តម **អ៊ុំ ម៉ាន្នីន**	០៤-០៣-១៩២៤

សមាសភាពគណបក្សប្រជាជនកម្ពុជា

	ថ្ងៃ ខែ ឆ្នាំ កំណើត
១. សម្ដេច **ជា ស៊ីម**	១៥-១១-១៩៣២
២. ឯកឧត្តម **អ៊ុក ប៊ុនឈឿន**	០៥-០៣-១៩៤៣
៣. ឯកឧត្តម **ឈា ចាំង**	១៥-១១-១៩៣៥
៤. ឯកឧត្តម **គង់ សារាជ**	២២-០៨-១៩៤៧
៥. ឯកឧត្តម **ចាន់ តិន**	១២-០៤-១៩៣៨
៦. ឯកឧត្តម **អ៊ុំ សារិទ្ធ**	០២-០៤-១៩៤៧
៧. ឯកឧត្តម **អ៊ុង ឆី**	៣០-០៦-១៩៤៩
៨. ឯកឧត្តម **ឈិត គីមយាត**	០៨-០៦-១៩៤៧
៩. លោកជំទាវ **ឆី ប៊ូរ៉ាស៊ី**	០១-០៨-១៩៣៩
១០. លោកជំទាវ **មាន សំអាន**	១៦-០៦-១៩៥៦
១១. លោកជំទាវ **ឈូក ឈឹម**	១០-១០-១៩៥៤
១២. ឯកឧត្តម **ទេព ងន**	០១-០១-១៩៤៧
១៣. ឯកឧត្តម **ស៊ឹម កា**	១៩-០៤-១៩៤៨
១៤. ឯកឧត្តម **រស់ ស្រេង**	១៥-០៣-១៩៣៩
១៥. ឯកឧត្តម **ជា សុន**	២៣-១១-១៩៤៥
១៦. ឯកឧត្តម **សោម សុផា**	១៥-១០-១៩៣៧
១៧. ឯកឧត្តម **តូច សាក់**	១២-០៤-១៩៤៣
១៨. ឯកឧត្តម **សេក សំអៀត**	១៥-០៦-១៩៣០
១៩. ឯកឧត្តម **ប៉េង ផាត់**	១១-០១-១៩៤៩

២០. ឯកឧត្តម **ហ៊ើយ ភើក**	១០-០៤-១៩៣៩
២១. ឯកឧត្តម **ភង ចន្ទ**	០២-០៦-១៩៣២
២២. ឯកឧត្តម **ស៊ើយ កែច**	០៣-០៦-១៩៣៧
២៣. ឯកឧត្តម **ជ័យ សាផុន**	១០-១០-១៩៣០
២៤. ឯកឧត្តម **ឆិត រាម**	១៩៤៣
២៥. ឯកឧត្តម **យ៉ង់ សែម**	០១-១២-១៩៤៣
២៦. ឯកឧត្តម **ជា ជេដ្ឋ**	១៣-០១-១៩៤៨
២៧. ឯកឧត្តម **ទ៉ាន់ ម៉ាត់**	០១-០១-១៩៤៨
២៨. លោកជំទាវ **ឡាក់ វុន**	២១-១២-១៩៤៥
២៩. លោកជំទាវ **ពុំ ស៊ីចាន់**	០១-១១-១៩៤៧
៣០. ឯកឧត្តម **ម៉ែន សារុន**	១៩-០៨-១៩៤៦
៣១. ឯកឧត្តម **ថុង ចន់**	០៦-០៨-១៩៤២

សមាសភាពគណបក្សហ្វ៊ុនស៊ិនប៉ិច

	ថ្ងៃ ខែ ឆ្នាំ កំណើត
១. សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស**	០១-០២-១៩៣៦
២. ឯកឧត្តម **ចៅ ប៊ុនស្រ៊ី**	០១-១០-១៩៤៩
៣. ឯកឧត្តម **ឆា ចំរ៉ាត់**	០២-០១-១៩៤៦
៤. ឯកឧត្តម **ឆ្នាំ ប៊ុនស្រុន**	០៣-១២-១៩៤២
៥. ឯកឧត្តម **ស៊ីង អឿម**	០២-០១-១៩៣៨
៦. ឯកឧត្តម **ឡាយ ឈុនសារ៉ែត**	០៦-០៥-១៩៥២
៧. ឯកឧត្តម **សាប៊ូ ឆាចា**	១៦-០១-១៩៤៣
៨. ឯកឧត្តម **អ៊ុង ស៊ឹម**	០៧-០១-១៩៥០
៩. សម្តេចរាជបុត្រីព្រះរៀម **នរោត្តម បុប្ផាទេវី**	០៨-០១-១៩៤៣
១០. ឯកឧត្តម **រស់ ឆេង**	២៧-០៣-១៩៤៦
១១. ឯកឧត្តម **ខៀវ សួន**	១៣-០៤-១៩៤៥
១២. លោកជំទាវ **ម៉ែន ម៉ាលី**	០១-១០-១៩៤៥
១៣. លោកជំទាវ **សម កនិដ្ឋា**	០២-០៨-១៩៥១

១៤. លោកជំទាវ **ម៉ិច សុម៉ាលី** ៣០-០៦-១៩៥៣

១៥. ឯកឧត្តម **ឆាយ ប៊ិនឡាយ** ០៣-០១-១៩៤៧

១៦. ឯកឧត្តម **ហួត ប៊ុនលី** ១៥-០១-១៩៤៤

១៧. ឯកឧត្តម **ជា គីម** ១៥-១០-១៩៤៨

១៨. ឯកឧត្តម **ហាស សារ៉េន** ០៩-០៦-១៩៥០

១៩. អ្នកម្នាង **នរោត្តម ឌីយ៉ាត** ០៥-០៤-១៩៤៩

២០. ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ស៊ីរិរ័ត្ន** ២១-០៦-១៩៤៦

២១. ឯកឧត្តម **ប្រាក់ ង៉ាន់នី** ០១-០២-១៩៤០

សមាសភាពគណបក្ស សម រង្ស៊ី

ថ្ងៃ ខែ ឆ្នាំ កំណើត

១. ឯកឧត្តម **គង់ គាំ** ០៦-០៤-១៩៤១

២. ឯកឧត្តម **ម៉េង រីតា** ១២-០៣-១៩៥៥

៣. ឯកឧត្តម **រ៉ុង ឈឿន** ៣១-១២-១៩៤៨

៤. ឯកឧត្តម **ថាច់ សេដ្ឋា** ១៤-០៥-១៩៥៣

៥. ឯកឧត្តម **អ៊ុង ប៊ុនអាង** ៣១-១២-១៩៤៩

៦. ឯកឧត្តម **ហ៊ុត ទ្រី** ០៥-០៥-១៩៣៣

៧. ឯកឧត្តម **ចៅ ផល្លី** ១៥-០១-១៩៥៣

៤. បញ្ជីឈ្មោះសមាជិកព្រឹទ្ធសភាចេញ-ចូល

ល.រ	សមាជិកចេញ			ឈ្មោះសមាជិកចូល	ព្រះរាជក្រឹត្យតែងតាំង	ថ្ងៃប្រកាសសមាជិកថ្មី សម័យប្រជុំ
	ឈ្មោះ	មូលហេតុ	គណបក្ស			
១	យីង គីមអួន	លាឈប់	ហ៊្វុនស៊ិនប៉ិច	សេរី កុសល	នស-រកត-០២០០-០៣៨ ចុះថ្ងៃទី០១-២-០០	២៩-៩-២០០០ សម័យប្រជុំទី៣
២	ស៊ិន សុង	ស្លាប់	ប្រជាជនកម្ពុជា	លី គីមហាន	នស-រកត-០៣០១-០៥៨ ចុះថ្ងៃទី១៥-៣-០១	០៤-៦-២០០១ សម័យប្រជុំទី៥
៣	ឃួន ប្លែរ៉េត	លាឈប់	ហ៊្វុនស៊ិនប៉ិច	ន.ស៊ីវ៉ុវុឌ្ឍ	នស-រកត-០៧០១-២១៨ ចុះថ្ងៃទី០៤-៧-០១	០៩-៨-២០០១ សម័យប្រជុំទី៥
៤	ស៊ិន ប៊ូ	ទៅអគ្គាធរ សវនកម្មជាតិ	ហ៊្វុនស៊ិនប៉ិច	ស៊ិន ពិនសេន	នស-រកត-០៧០១-២៥២ ចុះថ្ងៃទី៣១-៧-០១	០៩-៨-២០០១ សម័យប្រជុំទី៥
៥	ប៊ិល ណាល់	ស្លាប់	ប្រជាជនកម្ពុជា	តូច សាក់	នស-រកត-០៨០១-២៦៦ ចុះថ្ងៃទី០៨-៨-០១	១៣-៨-២០០១ សម័យប្រជុំទី៥
៦	លី គីមហាន	ស្លាប់	ប្រជាជនកម្ពុជា	ទិត រាម	នស-រកត-១១០១-៤២០ ចុះថ្ងៃទី០៩-១១-០១	០៥-១២-២០០១ សម័យប្រជុំទី៦
៧	ពៅ សាវ៉ាត	គណបក្ស ផ្លាស់ប្តូរ	ប្រជាជនកម្ពុជា	សោម សុផា	នស-រកត-១២០១-៤៥៥ ចុះថ្ងៃទី១២-១២-០១	២០-១២-២០០១ សម័យប្រជុំទី៦
៨	អាំង សុង	គណបក្ស ផ្លាស់ប្តូរ	ប្រជាជនកម្ពុជា	អ៊ុំ សារិទ្ធ	នស-រកត-១២០១-៤៥៥ ចុះថ្ងៃទី១២-១២-០១	២០-១២-២០០១ សម័យប្រជុំទី៦
៩	ផៃ ស៊ីផាន	គណបក្ស ផ្លាស់ប្តូរ	ប្រជាជនកម្ពុជា	ឡាក់ អួន	នស-រកត-១២០១-៤៥៥ ចុះថ្ងៃទី១២-១២-០១	២០-១២-២០០១ សម័យប្រជុំទី៦
១០	កែវ សាន	គណបក្ស ផ្លាស់ប្តូរ	ប្រជាជនកម្ពុជា	ជ័យ សាផុន	នស-រកត-០១០២-០០២ ចុះថ្ងៃទី០៧-០១-០២	០៨-០១-២០០២ សម័យប្រជុំទី៦
១១	គីម សុខា	លាឈប់	ហ៊្វុនស៊ិនប៉ិច	ឈឹម សៀកឡេង	នស-រកត-១១០២-៣០៥ ចុះថ្ងៃទី០៨-១១-០២	១៦-១២-២០០២ សម័យប្រជុំទី៨
១២	ហង់ ជួន	ស្លាប់	ប្រជាជនកម្ពុជា	គង់ សារាជ	នស-រកត-១១០២-៣១១ ចុះថ្ងៃទី១៦-១១-០២	១៦-១២-២០០២ សម័យប្រជុំទី៨
១៣	ន.ស៊ីវ៉ុវុឌ្ឍ	លាឈប់	ហ៊្វុនស៊ិនប៉ិច	ផ្ទាំ ប៊ុនស្រុន	នស-រកត-១០០៣-៣០៤ ចុះថ្ងៃទី២០-១០-០៣	១៣-០២-២០០៤ សម័យប្រជុំទី៩
១៤	ឈឹម សៀកឡេង	លាឈប់	ហ៊្វុនស៊ិនប៉ិច	ឡាយ ឈុនសារ៉េត	នស-រកត-១០០៣-៣០៤ ចុះថ្ងៃទី២០-១០-០៣	១៣-០២-២០០៤ សម័យប្រជុំទី៩
១៥	ឃួន ប្រាង់	ស្លាប់	ហ៊្វុនស៊ិនប៉ិច	ឯក សេរីវឌ្ឍ	នស-រកត-០៣០៤-០៥០ ចុះថ្ងៃទី២២-៣-០៤	១២-៧-២០០៤ សម័យប្រជុំទី៩

១៦	ញឹក ប៊ុនឆៃ	ទៅរដ្ឋាភិបាល	ហ៊្វុនស៊ិនប៉ិច	ប៉ោ ប៊ុនស្រ៊ី	នស/រកត/០៧០៤/១៣១ ចុះថ្ងៃទី១៨ -០៧-០៤	២០-៨-២០០៤ សម័យប្រជុំទី៩
១៧	ជា ប៉េងឈាង	ទៅរដ្ឋាភិបាល	ហ៊្វុនស៊ិនប៉ិច	សម្តេចព្រះរៀម នរោត្តម បុប្ផាទេវី	នស/រកត/០៧០៤/១៤៩ ចុះថ្ងៃទី២៨ -០៧-០៤	២០-៨-២០០៤ សម័យប្រជុំទី៩
១៨	សេរី កុសល	ទៅរដ្ឋាភិបាល	ហ៊្វុនស៊ិនប៉ិច	ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ស៊ីរីរ័ត្ន	នស/រកត/០៧០៤/១៤៩ ចុះថ្ងៃទី២៨ -០៧-០៤	២០-៨-២០០៤ សម័យប្រជុំទី៩
១៩	អ៊ុក ប្រាថ្នា	ទៅរដ្ឋាភិបាល	ប្រជាជនកម្ពុជា	យ៉ង់ សែម	នស/រកត/០៧០៤/១៥០ ចុះថ្ងៃទី២៨ -០៧-០៤	២០-៨-២០០៤ សម័យប្រជុំទី៩
២០	អ៊ូ ប៊ុនឡុង	ទៅរដ្ឋាភិបាល	សម រង្ស៊ី	អ៊ឹង ប៊ុនអាង	នស/រកត/០៧០៤/១៥១ ចុះថ្ងៃទី២៨ -០៧-០៤	២០-៨-២០០៤ សម័យប្រជុំទី៩
២១	ខៀវ សន	ទៅរដ្ឋសភា	ហ៊្វុនស៊ិនប៉ិច	រស់ ឆេង	នស/រកត/០៧០៤/១៤៩ ចុះថ្ងៃទី២៨ -០៧-០៤	២០-៨-២០០៤ សម័យប្រជុំទី៩
២២	ស៊ិន ពិនសេន	ទៅរដ្ឋសភា	ហ៊្វុនស៊ិនប៉ិច	ហូត ប៊ុងលី	នស/រកត/០៧០៤/១៤៩ ចុះថ្ងៃទី២៨ -០៧-០៤	២០-៨-២០០៤ សម័យប្រជុំទី៩
២៣	ស៊ុម សូលី	ទៅរដ្ឋសភា	ហ៊្វុនស៊ិនប៉ិច	អ្នកម្នាង នរោត្តម ឌីយ៉ាត	នស/រកត/០៧០៤/១៤៩ ចុះថ្ងៃទី២៨ -០៧-០៤	២០-៨-២០០៤ សម័យប្រជុំទី៩
២៤	ឯក សេរីវឌ្ឍ	ទទួលភារកិច្ចថ្មី	ហ៊្វុនស៊ិនប៉ិច	ទា ចំរ៉ាត់	នស/រកត/១០០៤/៣១៦ ចុះថ្ងៃទី១៩-១០-០៤	២២-១០-២០០៤ សម័យប្រជុំទី៩
២៥	រុង ផ្លាមកេសន	លាឈប់	ប្រជាជនកម្ពុជា	ជា សុន	នស/រកត/០៣០៥/១៤២ ចុះថ្ងៃទី១៨-៣-០៥	៣០-៣-២០០៥ សម័យប្រជុំទី៩
២៦	កែវ ប៊ុនធូក	ស្លាប់	តំណាង ព្រះមហាក្សត្រ	អ៊ុំ ម៉ាន្នីរីន	នស/រកត/០៦០៥/២៩៣ ចុះថ្ងៃទី២៤-០៦-២០០៥	សម័យប្រជុំវិសាមញ្ញ

កំណត់សំគាល់ :

លេខរៀងទី ២ : ឯកឧត្តម **ស៊ិន សុខ** ជាប្រធានគណៈកម្មការទី ៤ ចាប់ពីឆ្នាំ ១៩៩៩ រហូតដល់ខែ មីនា ឆ្នាំ ២០០១

លេខរៀងទី ១១ : ឯកឧត្តម **គឹម សុខា** ជាប្រធានគណៈកម្មការទី ១ ចាប់ពីឆ្នាំ ១៩៩៩ រហូតដល់ខែ តុលា ឆ្នាំ ២០០២

លេខរៀងទី ១៦ : ឯកឧត្តម **ញឹក ប៊ុនឆៃ** ជាអនុប្រធានទី ២ ព្រឹទ្ធសភា ចាប់ពីឆ្នាំ ១៩៩៩ រហូតដល់ ខែ កក្កដា ឆ្នាំ ២០០៤

លេខរៀងទី ១៧ : ឯកឧត្តម **ជា ប៉េងឈាង** ជាប្រធានគណៈកម្មការទី ២ ចាប់ពីឆ្នាំ ១៩៩៩ រហូតដល់ខែ កក្កដា ឆ្នាំ ២០០៤

៥. តួនាទី និង ភារកិច្ច របស់ព្រឹទ្ធសភា

ព្រឹទ្ធសភា ជាអង្គការនីតិប្បញ្ញត្តិរបស់ជាតិ ដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មសង្គម និងក្នុងការកសាងកម្ពុជាជានីតិរដ្ឋ ។ ព្រឹទ្ធសភា មានមុខងារសំខាន់មួយទៀត គឺការរួមវិភាគទាននៅក្នុងដំណើរការស្ថិរភាវូបនីយកម្មជីវភាពនយោបាយរបស់ជាតិ ដែលជាស្នូលនៃការពង្រឹងពង្រីកនយោបាយបង្រួបបង្រួមផ្សះផ្សាជាតិ និងអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចំរើនរុងរឿង និងសម្បូណ៌សប្បាយ ។

ព្រឹទ្ធសភា មានមុខងារសំខាន់ៗ ៣ គឺ :

ក. មុខងារសម្របសម្រួល

ខ. មុខងារសម្រិតសម្រាំង

គ. មុខងារផ្តល់ជម្រើស ។

ខាងក្រោមនេះ គឺជាសេចក្តីពិពណ៌នាយ៉ាងពិស្តារអំពីមុខងារទាំងបីខាងលើ :

ក. មុខងារសម្របសម្រួល

មុខងារសម្របសម្រួលនេះ មានលក្ខណៈទូលំទូលាយនៅក្នុងស្ថិរភាវូបនីយកម្មជីវភាពនយោបាយរបស់ជាតិទាំងក្នុងករណីជាតិសុខសាន្ត ទាំងក្នុងករណីជាតិកើតវិបត្តិ ។ កិច្ចការនេះផ្សារភ្ជាប់នឹងពេលវេលា កាលៈទេសៈ បរិយាកាសដែលកើតមានជាទូទៅនៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ហើយពាក់ព័ន្ធដល់គ្រប់មជ្ឈដ្ឋានសង្គម និងទិដ្ឋភាពទាំងអស់នៃជីវភាព និងផលប្រយោជន៍របស់ជាតិ ។ ក្នុងការបំពេញមុខងារនេះ ព្រឹទ្ធសភាដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់យោបល់ខាងនយោបាយ និងច្បាប់ ដោយតម្កល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋជាធំ និងព្យាយាមធ្វើឱ្យមានតុល្យភាពរវាងផលប្រយោជន៍របស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ។

ខ. មុខងារសម្រិតសម្រាំង

ជាមុខងារដ៏សំខាន់ នៅក្នុងដំណើរការកសាងច្បាប់ ក្នុងគោលបំណងលើកកំពស់គុណភាពនៃសេចក្តីព្រាងច្បាប់ ដែលត្រូវបានរៀបចំតាក់តែងឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និងបានដាក់ឆ្លងរដ្ឋសភាអនុម័តរួចហើយ ឱ្យកាន់តែល្អប្រពៃឡើងថែមទៀត ។ ការសម្រិតសម្រាំង ត្រូវប្រមូលផ្តុំលើប្រសិទ្ធភាព គុណភាព និងតម្លៃ ។ ដូច្នេះចាំបាច់ត្រូវមានការវិភាគលើចំណុចខ្លាំង ចំណុចខ្សោយ បច្ច័យល្អ បច្ច័យអាក្រក់ ព្រមទាំងផលប៉ះពាល់ផ្សេងៗ ដែលគួរពិចារណា និងកែលំអ ។ ភាគច្រើននៃតួនាទីនេះមានរៀបរាប់យ៉ាងពិស្តារនៅក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ។

គ. មុខងារផ្តល់នូវជម្រើស

មុខងារនេះ តម្រូវឱ្យព្រឹទ្ធសភាជួយដល់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភា ក្នុងការជ្រើសយកច្បាប់ ឬវិធានការណាមួយតាមទំរង់រូបភាព មធ្យោបាយ ផ្លូវដ៏ល្អខ្ចី ងាយស្រួលអនុវត្ត និងទទួលយកបានពីគ្រប់មជ្ឈដ្ឋានសង្គម ។

ទំហំការងារដែលបានលើកឡើងនៅក្នុងមុខងារទាំង៣ ខាងលើនេះ បង្ហាញឱ្យឃើញពីវិសាលភាពដ៏ធំធេងនៃសកម្មភាពរបស់ព្រឹទ្ធសភានិងតួនាទីសំខាន់ដែលព្រឹទ្ធសភាត្រូវអនុវត្តនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរ និងក្នុងការងារ

របស់រដ្ឋ។ នេះគឺជាតួនាទីមួយមានរយៈពេលវែង និងមានលក្ខណៈទូលំទូលាយ ដែលតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់ទាមទារឱ្យមានចំណេះដឹងបទពិសោធន៍គ្រប់គ្រាន់ និងទស្សនវិស័យពេញលេញក្នុងជីវភាពនយោបាយនៅកម្ពុជា។ ក្នុងការធានាឱ្យមានស្ថិរភាពនយោបាយនៅក្នុងប្រទេស ព្រឹទ្ធសភាត្រូវប្រើប្រាស់យន្តការសម្របសម្រួលមួយដ៏ឈ្លាសវៃដែលចេះតម្រង់ទិស និងបញ្ចៀសសង្គមពីវិបត្តិតូច ធំទាំងឡាយ ។

៦. ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា

៦.១ ការរៀបចំព្រឹទ្ធសភា

សំរាប់នីតិកាលទី ១ នេះ ចំនួនសមាជិកព្រឹទ្ធសភាមាន ៦១រូប ក្នុងនោះមានសមាជិកា ៧រូប។ សមាជិក ២រូប តែងតាំងដោយព្រះមហាក្សត្រ ៣១រូប មកពីគណបក្សប្រជាជនកម្ពុជា ២១រូប មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច និង ៧រូប មកពីគណបក្សសម រង្ស៊ី។ បន្ទាប់ពីមានការផ្លាស់ប្តូរថ្មី (សមាជិកចេញ-ចូល) សមាជិកាព្រឹទ្ធសភាបានកើនពី ៧រូប មក ១០រូប។

អង្គការដឹកនាំរបស់ព្រឹទ្ធសភា គឺគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលមានសមាសភាព ១២រូប។ ព្រឹទ្ធសភា មានគណៈកម្មការជំនាញចំនួន ៩។

រចនាសម្ព័ន្ធរបស់ព្រឹទ្ធសភា

៦.២ ការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗមានថិរវេលាយ៉ាងតិច ៣ខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្ដីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ។

ការប្រជុំអនុម័តបញ្ហាទាំងឡាយ ដែលត្រូវការសម្លេងភាគច្រើន ពីរភាគបី ឬបីភាគបួន នៃចំនួនសមាជិក ព្រឹទ្ធសភាទាំងមូលត្រូវមានកូរ៉ុមប្រាំពីរភាគដប់។ ការប្រជុំអនុម័តបញ្ហាទាំងឡាយ ដែលត្រូវការសម្លេងភាគច្រើនដោយប្រៀប ឬ សម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ត្រូវមានកូរ៉ុម ប្រាំមួយភាគដប់។

នៅចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាទទួលភារកិច្ចចាត់ចែងការងារ។

៧. នីតិវិធីពិនិត្យ និងអនុម័តអត្ថបទច្បាប់

បញ្ញត្តិជាមូលដ្ឋាន :

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បទបញ្ជាផ្ទៃក្នុងរដ្ឋសភាឆ្នាំ ១៩៩៣
- សេចក្ដីសម្រេចលេខ ០០៥/៩៩៩/ពស/សរ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់ប្រធានព្រឹទ្ធសភា ស្ដីពីការប្រកាសឱ្យប្រើបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៤៩/០០៤/២០០២ កបធ.ច ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២ និង
- សេចក្ដីសម្រេចលេខ ០៣១/០៨០៥/ពស/សរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៥ របស់ប្រធានព្រឹទ្ធសភា ស្ដីពីការប្រកាសឱ្យប្រើ វិសោធនកម្មប្រការ ៤៤ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

ចាប់តាំងពីឆ្នាំ១៩៩៩មក ព្រះរាជាណាចក្រកម្ពុជាបានប្រកាន់យករបបសភាពីរគឺរដ្ឋសភា និងព្រឹទ្ធសភា។ ក្នុងមុខងារនីតិប្បញ្ញត្តិ ព្រឹទ្ធសភាមានភារកិច្ចពិនិត្យនិងផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តលើកដំបូងរួចហើយ។ ក្នុងដំណើរការអនុវត្តភារកិច្ចនេះ រដ្ឋសភា និងព្រឹទ្ធសភាត្រូវគោរពតាមរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុង និងបញ្ញត្តិទាំងឡាយ ដែលទាក់ទងនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថាប័ននីមួយៗ។

ការពិភាក្សា និងអនុម័តត្រូវធ្វើតាមលំដាប់លំដោយដូចតទៅ :

ក. ការដាក់ជូនសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់

សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តលើកដំបូងរួចហើយ ត្រូវដាក់ជូនមកគណៈកម្មាធិការ-អចិន្ត្រៃយ៍ព្រឹទ្ធសភា ។

សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរចែកជាមាត្រា ហើយមានសេចក្ដីថ្លែងហេតុភ្ជាប់មកជាមួយ។

គណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ ហើយសម្រេចប្រគល់សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះឱ្យគណៈកម្មការជំនាញណាមួយ ក្នុងចំណោមគណៈកម្មការជំនាញទាំង ៩ របស់ព្រឹទ្ធសភា។

ខ ការពិនិត្យក្នុងគណៈកម្មការជំនាញ

គណៈកម្មការពិនិត្យយ៉ាងល់អិតលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលបានទទួលពីគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយមានការចូលរួមពីតំណាងរាជរដ្ឋាភិបាល បើជាសេចក្ដីព្រាងច្បាប់ ឬពីសមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភា បើជាសេចក្ដីស្នើច្បាប់។ តំណាងទាំងនេះមានសិទ្ធិឆ្លើយបំភ្លឺ ចំពោះសំនួរដែលគណៈកម្មការលើកឡើង ។ តំណាងគណៈកម្មការដទៃទៀតរបស់ព្រឹទ្ធសភា តំណាងអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល អាចចូលរួមបានតាមការកោះអញ្ជើញរបស់គណៈកម្មការ ។ អ្នកតំណាងទាំងនោះគ្មានសិទ្ធិអនុម័តឡើយ ។

គណៈកម្មការត្រូវរៀបរៀងរបាយការណ៍អំពីការពិនិត្យនេះ ដើម្បីរាយការណ៍ជូនព្រឹទ្ធសភា។ របាយការណ៍នេះ ត្រូវបង្ហាញពីទស្សនៈរបស់គណៈកម្មការ និងអំពីវិសោធនកម្មទាំងឡាយដែលគណៈកម្មការស្នើឡើង ចំពោះសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ហើយត្រូវចម្លងចែកជូន សមាជិកព្រឹទ្ធសភាទាំងអស់ ឱ្យបានមុនថ្ងៃប្រជុំអនុម័តសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះ ។

គណៈកម្មការជំនាញអាចប្រជុំបានលុះត្រាតែមានសមាជិកច្រើនជាងពាក់កណ្ដាលចូលរួម ឯការអនុម័តត្រូវយកតាមសំលេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកគណៈកម្មការ ។

គ. ការពិភាក្សា និងការអនុម័តក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភា

គណៈកម្មាធិការអចិន្ត្រៃយ៍បញ្ជូនសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះទៅសុំការអនុម័តពីព្រឹទ្ធសភាដោយដាក់បញ្ចូលទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភា តាមសំណើរបស់គណៈកម្មការជំនាញ ដែលបានពិនិត្យចប់សព្វគ្រប់ហើយ ។

ការប្រជុំត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធានព្រឹទ្ធសភា។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូបដឹកនាំការប្រជុំ។ ព្រឹទ្ធសភាប្រជុំជាសាធារណៈ ។ ព្រឹទ្ធសភា អាចប្រជុំជាសម្ងាត់តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

តំណាងរាជរដ្ឋាភិបាល ឬតំណាងម្ចាស់សេចក្ដីស្នើច្បាប់បំភ្លឺ និងការពារសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះ ។

ប្រធានគណៈកម្មការជំនាញរាយការណ៍ជូនព្រឹទ្ធសភា ហើយការពារជំហររបស់គណៈកម្មការ ជាពិសេសលើសំណើវិសោធនកម្មរបស់គណៈកម្មការ ។

ការពិភាក្សា និងអនុម័តត្រូវធ្វើជាលំដាប់លំដោយដូចតទៅ :

- ពិភាក្សា និងអនុម័តខ្លឹមសាររួមនៃសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់
- ពិភាក្សា និងអនុម័តម្ដងមួយមាត្រា ឬម្ដងមួយជំពូក ឬធ្វើតែចំណុចណាដែលគណៈកម្មការ ជំនាញសុំឱ្យពិចារណា
- អនុម័តសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ទាំងមូល ។

ឃ. ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា

បើព្រឹទ្ធសភាសុំឱ្យកែសម្រួល ព្រឹទ្ធសភាត្រូវបញ្ជូនសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះ ទៅរដ្ឋសភាវិញដោយបញ្ជាក់អំពីចំណុច ដែលខ្លួនមិនយល់ព្រម និងអំពីខ្លឹមសារថ្មីដែលខ្លួនចង់ឱ្យកែសម្រួលតាម ។

តាមមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ការបញ្ជូនទៅបញ្ជូនមក រវាងព្រឹទ្ធសភា និងរដ្ឋសភា អាចធ្វើបានច្រើនដងក្នុងរយៈពេល ដែលមានកំណត់ក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ។ សូមមើលរូបទី ១ : គំនូសបំព្រួញ នីតិវិធីនៃការពិនិត្យ និងអនុម័តច្បាប់ ។

ង. ការប្រកាសឱ្យប្រើច្បាប់

ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយ នៅទូទាំងប្រទេសឱ្យទាន់តាមពេលកំណត់ខាងលើ ។

រូបទី ១ **គំនូសបំព្រួញ នីតិវិធីនៃការពិនិត្យ និងអនុម័តច្បាប់**



កំណត់សំគាល់ : ដំណើរនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ :

(១). រវាងស្ថាប័នរាជរដ្ឋាភិបាល និងសភា

(២). ដំណើរការក្នុងសភានីមួយៗ

(៣). ការបង្វិលទៅមករវាងសភាទាំងពីរ

៨. សកម្មភាពរបស់ព្រឹទ្ធសភា

សន្ទស្សន៍មតិ យោបល់របស់សមាជិក សមាជិកា ព្រឹទ្ធសភា ក្នុងសម័យប្រជុំនីមួយៗ គិតជាភាគរយតាមគណបក្ស



គណបក្ស	សម័យប្រជុំ លើកទី ១ ២៥/០៧/៩៨ ដល់ ៣០/០៦/៩៩	សម័យប្រជុំ វិសាមញ្ញ ១៧/០៨/៩៩ និង ២០/០៨/៩៩	សម័យប្រជុំ លើកទី ២ ២៨/១០/៩៩ ដល់ ២១/០២/០០	សម័យប្រជុំ លើកទី ៣ ២៥/០៥/០០ ដល់ ២៨/០៨/០០	សម័យប្រជុំ លើកទី ៤ ០៥/១២/០០ ដល់ ១៤/២/០១	សម័យប្រជុំ លើកទី ៥ ០៤/៦/០១ ដល់ ១៣/៨/០១	សម័យប្រជុំ លើកទី ៦ ១៥/១២/០១ ដល់ ០៨/០១/០២	សម័យប្រជុំ លើកទី ៧ ១៥/០៦/០២ ដល់ ០៥/០៩/០២	សម័យប្រជុំ លើកទី ៨ ១៦/១២/០២ ដល់ ២៧/២/០៣	សម័យប្រជុំ លើកទី ៩ ២៥/៧/០៤ ដល់ ៣០/០៥/០៥	សម័យប្រជុំ វិសាមញ្ញ ៣០/០៥/០៥ និង ០៥/០៧/០៥	សម័យប្រជុំ លើកទី ១០ ០៧/០៩/០៥ ដល់
CPP	១០	១៣	៣៩	៤២	៦៩	៧២	២៩	២២	១៣	៣០	០	០៧
គិតជា %	៣០%	៤៥%	៣៥%	៤២%	៣០%	៤៧%	៣៨%	២០%	១៥%	៣៦%	០%	១៤%
FUN	១១	៥	៣៥	៥២	៥៣	៣៨	២៤	៤៤	៣៤	៣២	០	០៨
គិតជា %	៣២%	១៧%	៣១%	២៧%	២៣%	២៥%	៣១%	៤០%	៤០%	៣៨%	០%	១៦%
SRP	១៣	១១	៣៩	៦១	១០៩	៤៤	២៤	៤៦	៣៨	២១	០	៣៦
គិតជា %	៣៨%	៣៨%	៣៤%	៣១%	៤៧%	២៨%	៣១%	៤១%	៤៥%	២៥%	០%	៧០%

* ចាប់ពីថ្ងៃទី ២៥ ខែមីនា ដល់ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៥ សមាជិកព្រឹទ្ធសភា គណបក្សសម រង្ស៊ី ធ្វើពហិការ (មិនចូលរួមប្រជុំ)

៨.១ សម័យប្រជុំពេញអង្គ និងវិសាមញ្ញ

ស្ថិតិនៃការប្រជុំព្រឹទ្ធសភា (១៩៩៩-២០០៥)



សម័យប្រជុំ	លើកទី ១	វិសាមញ្ញ	លើកទី ២	លើកទី ៣	លើកទី ៤	លើកទី ៥	លើកទី ៦	លើកទី ៧	លើកទី ៨	លើកទី ៩	វិសាមញ្ញ	លើកទី ១០
ចំនួនកោះប្រជុំ	០៩	០២	០៧	១០	១៥	១២	០៥	០៥	០៨	១៤	០២	០៥

ក្នុងនីតិកាលទី ១ ព្រឹទ្ធសភាកោះប្រជុំបាន ៩៤ដង ។

ចំនួនច្បាប់ដែលព្រឹទ្ធសភាបានអនុម័ត និងផ្តល់យោបល់មានចំនួន ១២៨ ក្នុងចំណោមអត្ថបទច្បាប់ ១៣៧ ដែលរដ្ឋសភាបានបញ្ជូនមក ។ ក្នុងចំណោម ១២៨ ច្បាប់ដែលព្រឹទ្ធសភាបានអនុម័ត និងផ្តល់យោបល់មានច្បាប់ ២ ដែលព្រឹទ្ធសភាបានស្នើសុំឱ្យរដ្ឋសភាធ្វើការកែសម្រួលឡើងវិញ និងច្បាប់មួយទៀតព្រឹទ្ធសភា សំរេចលើកចោលពុំពិចារណា ។

ស្ថិតិច្បាប់ដែលព្រឹទ្ធសភា នីតិកាលទី ១ បានពិនិត្យ និងផ្តល់យោបល់ ក្នុងសម័យប្រជុំនីមួយៗ



ចំនួនច្បាប់ដែលព្រឹទ្ធសភានីតិកាលទី ១ បានអនុម័ត

សម័យប្រជុំ	លើក ទី ១	វិសាមញ្ញ	លើក ទី ២	លើក ទី ៣	លើក ទី ៤	លើក ទី ៥	លើក ទី ៦	លើក ទី ៧	លើក ទី ៨	លើក ទី ៩	វិសាមញ្ញ	លើក ទី ១០
ចំនួនច្បាប់	១៤	៣	៤	១១	៧	៩	៨	៧	១២	២៨	០១	២៤

៨.២ បញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និង ផ្ដល់យោបល់ជូនរដ្ឋសភា ក្នុងនីតិកាលទី ១

សម័យប្រជុំពេញអង្គលើកទី ១

ល.រ	ឈ្មោះច្បាប់	សម្លេងអនុម័ត	ថ្ងៃខែឆ្នាំអនុម័ត
១	ច្បាប់ស្ដីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន	៥២ សម្លេង	១៧/០៥/៩៩
២	ច្បាប់ស្ដីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម	៥៣ សម្លេង	១៧/០៥/៩៩
៣	ច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្ដុះ-បណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា	៥១ សម្លេង	១៧/០៥/៩៩
៤	ច្បាប់ស្ដីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា-រដ្ឋសភា និងអធិការកិច្ច	៤២ សម្លេង	២១/០៥/៩៩
៥	ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃទីភ្នាក់ងារធានាការវិនិយោគពហុភាគី	៤៦ សម្លេង	២១/០៥/៩៩
៦	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្ដីពីការហាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីន ប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន	៥៤ សម្លេង	៣១/០៥/៩៩
៧	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃ សាធារណរដ្ឋសិង្ហបុរី ស្ដីពីការជំរុញនិងការការពារវិនិយោគ	៥២ សម្លេង	២៣/០៦/៩៩
៨	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋកូរ៉េ ស្ដីពីការជំរុញនិងការការពារវិនិយោគ	៥២ សម្លេង	២៣/០៦/៩៩
៩	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ស្ដីពីការជំរុញ និងការ ការពារវិនិយោគ	៥២ សម្លេង	២៣/០៦/៩៩

១០	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសហព័ន្ធស្វីស ស្តីពីការជំរុញ និងការការពារវិនិយោគ	៥២ សម្លេង	២៣/០៦/៩៩
១១	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខៈ១៥០ ស្តីពីរដ្ឋបាលការងារនៃអង្គការអន្តរជាតិខាងការងារ	៥១ សម្លេង	២៣/០៦/៩៩
១២	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខៈ ៨៧ ៩៨.១០០.១០៥.១១១.១៣៨ នៃអង្គការអន្តរជាតិខាងការងារ	៤៤ សម្លេង	២៣/០៦/៩៩
១៣	ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧	៥២ សម្លេង	៣០/០៦/៩៩
១៤	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៍	៤៩ សម្លេង	៣០/០៦/៩៩

សម័យប្រជុំវិសាមញ្ញ

១	ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន	៤៨ សម្លេង	១៧/០៨/៩៩
២	ច្បាប់ស្តីពីរយៈពេលឃុំខ្លួនជាបណ្តោះអាសន្ន	៤៣ សម្លេង	១៧/០៨/៩៩
៣	ច្បាប់ស្តីពីការធ្វើវិសោធនកម្មលើមាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល	៣៣ សម្លេង	២០/០៨/៩៩

សម័យប្រជុំពេញអង្គលើកទី ២

១	ច្បាប់ស្តីពីវិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រ១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា ៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា ៤៤ ក្នុងជំពូកទី ២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី ៤ និងមាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី ៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម	៤៨ សម្លេង	០៥/១១/៩៩

២	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ២ ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍នៅទីក្រុងម៉ានីល នាថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៨	៥៥ សម្លេង	២៥/១១/៩៩
៣	ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០	៤៣ សម្លេង	២៤/១២/៩៩
៤	ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា	៤៤ សម្លេង	២១/០១/០០

សម័យប្រជុំពេញអង្គលើកទី ៣

១	ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា	៤៦ សម្លេង	០២/០៦/០០
២	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពិធីសារ និងអនុស្សារណៈនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ាន	៥០ សម្លេង	២៦/០៦/០០
៣	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន	៥២ សម្លេង	២៧/០៧/០០
៤	ច្បាប់ស្តីពីការធានារ៉ាប់រង	៤៥ សម្លេង	០៦/០៧/០០
៥	ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨	៤៤ សម្លេង	១០/០៧/០០
៦	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ស្តីពីការជំរុញ និងការការពារវិនិយោគ	៥០ សម្លេង	១៧/០៧/០០
៧	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ស្តីពីការជំរុញ និងការការពារវិនិយោគ	៥០ សម្លេង	១៧/០៧/០០
៨	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារ លើការធ្វើវិសោធនកម្មទៅលើកិច្ចព្រមព្រៀង ស្តីពីគំរោងអនុគ្រោះពន្ធគយរួមសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន	៤៩ សម្លេង	០២/០៨/០០

៩	ច្បាប់ស្តីពីច្បាប់បន្ថែមទៅលើច្បាប់សវនកម្មនៃព្រះរាជា-ណាចក្រកម្ពុជា	៣៣ សម្លេង	០៩/០៨/០០
១០	ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ	៤២ សម្លេង	២៤/០៨/០០
១១	ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលទៅក្នុងសន្ធិសញ្ញា ស្តីពីការហាមឃាត់ជាទូទៅ នៃការសាកល្បងអាវុធនុយក្លេអ៊ែរ	៤៧ សម្លេង	២៨/០៨/០០

សម័យប្រជុំពេញអង្គលើកទី ៤

១	ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា	៣៩ សម្លេង	១៣/១២/០០
២	ច្បាប់ស្តីពីការអនុម័តយល់ព្រម លើការធានាទូទាត់ របស់រាជរដ្ឋាភិបាលកម្ពុជា ឱ្យសាជីវកម្មអាហ៊័រណ នីហ៊័រណ បច្ចេកវិទ្យាថាមពលអគ្គិសនីចិន	៤២ សម្លេង	២១/១២/០០
៣	ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១	៤៤ សម្លេង	២៧/១២/០០
៤	ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩	៤៣ សម្លេង	០៥/០១/០១
៥	ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ	៥១ សម្លេង	១៥/០១/០១
៦	ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់	៥៣ សម្លេង	០១/០២/០១
៧	ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់	៤៩ សម្លេង	១៤/០២/០១

សម័យប្រជុំពេញអង្គលើកទី ៥

១	ច្បាប់ស្តីពីការអនុម័តយល់ព្រម លើកិច្ចព្រមព្រៀងរវាងរាជ-រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដើម្បីជំរុញនិងការពារទៅវិញទៅមកនូវការវិនិយោគ	៥១ សម្លេង	០៤/០៦/០១

២	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្ដីពីការជំរុញ និងការការពារការវិនិយោគ	៩១ សម្លេង	០៤/០៦/០១
៣	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្ដីពីដំណោះស្រាយវិវាទពាក់ព័ន្ធទៅនឹងការវិនិយោគ រវាងបណ្ដារដ្ឋហើយនិងបុគ្គលនៃរដ្ឋដទៃ	៩៣ សម្លេង	០៤/០៦/០១
៤	ច្បាប់ស្ដីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិថែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្ដីសម្រេចមជ្ឈត្តករបរទេស	៩២ សម្លេង	១២/០៦/០១
៥	ច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ	៨៦ សម្លេង	២៧/០៦/០១
៦	ច្បាប់ស្ដីពីការធ្វើនិយតកម្មមាត្រា ៣ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ	៩១ សម្លេង	២៣/០៧/០១
៧	ច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា១៩ និងមាត្រា២៩ នៃរដ្ឋធម្មនុញ្ញ	៩១ សម្លេង	២៣/០៧/០១
៨	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការមូលនិធិអូប៉ិច សម្រាប់ការអភិវឌ្ឍអន្តរជាតិ ដើម្បីការជំរុញ និងការការពារវិនិយោគ	៨៩ សម្លេង	២៤/០៧/០១
៩	ច្បាប់ស្ដីពីភូមិបាល	៨៨ សម្លេង	១៣/០៨/០១

សម័យប្រជុំពេញអង្គលើកទី ៦

១	ច្បាប់ស្ដីពីវិសោធនកម្មមាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០ និងមាត្រា ៩១ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ	៨៨ សម្លេង	០៦/០១/០១
២	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ	៨៦ សម្លេង	២០/១២/០១

៣	ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០	៤៩ សម្លេង	២០/១២/០១
៤	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ៥ របស់អាស៊ាន ស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត	៥១ សម្លេង	២០/១២/០១
៥	ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២	៤៤ សម្លេង	២៧/១២/០១
៦	ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់	៤៩ សម្លេង	០៨/០១/០២
៧	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋក្រូអាស្យាស្តីពីការជំរុញ និងការការពារវិនិយោគ	៤៩ សម្លេង	០៨/០១/០២
៨	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជ-រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋគុយបា ស្តីពីការជំរុញនិងការការពារវិនិយោគ	៤៨ សម្លេង	០៨/០១/០២

សម័យប្រជុំពេញអង្គលើកទី ៧

១	ច្បាប់ស្តីពីវិស័យប្រៃសណីយ៍	៥៤ សម្លេង	២០/០៦/០២
២	ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ	៤៩ សម្លេង	២១/០៦/០២
៣	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំ លើកទី ២ (២០០១-២០០៥)	៤៨ សម្លេង	០៨/០៧/០២
៤	ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ (HIV/AIDS)	៥២ សម្លេង	០៩/០៧/០២
៥	ច្បាប់ស្តីពីព្រៃឈើ	៤៦ សម្លេង	១៥/០៨/០២
៦	ច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ	៥២ សម្លេង	០៥/០៩/០២
៧	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការអនុវត្តកញ្ចប់ទីពីរនៃកិច្ចសន្យាក្នុងវិស័យសេវាហិរញ្ញវត្ថុនៅក្រោម	៥៣ សម្លេង	០៥/០៩/០២

សម័យប្រជុំពេញអង្គលើកទី ៨

១	ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ	៥២ សម្លេង	១៦/១២/០២
២	ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣	៤៧ សម្លេង	២៤/១២/០២
៣	ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ	៥៤ សម្លេង	៣០/១២/០២
៤	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងនិងក្នុងរង្វង់ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលនៃការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន	៥១ សម្លេង	៣១/១២/០២
៥	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការរៀបចំពិសេសសម្រាប់ផលិតផលវេទយិតនិងផលិតផលវេទយិតខ្ពស់	៥៤ សម្លេង	៣០/១២/០២
៦	ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម	៥១ សម្លេង	៣១/១២/០២
៧	ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្តីពីការបង្កើតក្រុមប្រឹក្សាសហប្រតិបត្តិការគយ	៥៤ សម្លេង	៣០/១២/០២
៨	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ៨ ស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន អំពីការសម្របសម្រួលទំនិញឆ្លងកាត់	៥៣ សម្លេង	០៩/០១/០៣
៩	ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ	៥២ សម្លេង	២២/០១/០៣
១០	ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល	៥២ សម្លេង	១២/០២/០៣
១១	ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា	៤៨ សម្លេង	២៦/០២/០៣
១២	ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ	៤៩ សម្លេង	២៦/០២/០៣

សម័យប្រជុំពេញអង្គលើកទី ៩

១	ច្បាប់ស្តីពីច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ	៤៨ សម្លេង	១២/០៧/០៤
២	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភព-លោក	៥០ សម្លេង	០៦/០៩/០៤
៣	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ	៥១ សម្លេង	០៨/១០/០៤
៤	ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និងមាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ	៥០ សម្លេង	០៨/១០/០៤
៥	ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សារាជសម្បត្តិ	៤៩ សម្លេង	១១/១០/០៤
៦	ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤	៤៦ សម្លេង	១១/១០/០៤
៧	ច្បាប់ស្តីពីការរៀបចំព្រះបរមងារ និងព្រះរាជបុព្វសិទ្ធិថ្វាយអតីតព្រះមហាក្សត្រ និងព្រះអគ្គមហេសី នៃព្រះរាជាណាចក្រកម្ពុជា	៥៤ សម្លេង	២២/១០/០៤
៨	ច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	៥៣ សម្លេង	០៥/១១/០៤

៩	ច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	៩៣ សម្លេង	០៩/១១/០៤
១០	ច្បាប់ស្ដីពីការបង្កើតក្រសួងកិច្ចការនារី	៨៣ សម្លេង	០៩/១១/០៤
១១	ច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥	៨៦ សម្លេង	២៨/១២/០៤
១២	ច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់-គ្រងឆ្នាំ ២០០២	៨៨ សម្លេង	២២/០២/០៥
១៣	ច្បាប់ស្ដីពីការអនុមតយល់ព្រមលើសន្ធិសញ្ញា រវាងព្រះ-រាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្ដីពីបត្យាប័ន	៨៨ សម្លេង	២២/០២/០៥
១៤	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្ដីពីអាវុធគីមី	៨៨ សម្លេង	២២/០២/០៥
១៥	ច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់-គ្រងឆ្នាំ ២០០១	៨៩ សម្លេង	១៦/០៣/០៥
១៦	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្ដីពីទំនាក់ទំនងកុងស៊ុល	៨៦ សម្លេង	១៦/០៣/០៥
១៧	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើធម្មនុញ្ញអង្គការអន្តរជាតិទេសន្តរប្រវេសន៍	៨៦ សម្លេង	១៦/០៣/០៥
១៨	ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងមូលដ្ឋានស្ដីពីកម្មវិធីសហប្រតិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន	៨៦ សម្លេង	១៦/០៣/០៥
១៩	ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាទោល ស្ដីពីគ្រឿងញៀនឆ្នាំ ១៩៦១	៨៦ សម្លេង	១៦/០៣/០៥
២០	ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្ដីពីសារធាតុ ដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ ១៩៧១	៨៦ សម្លេង	១៦/០៣/០៥
២១	ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ ១៩៨៨	៨៦ សម្លេង	១៦/០៣/០៥

២២	ច្បាប់ស្តីពីស្ថិតិ	៤៩ សម្លេង	៣០/០៣/០៥
២៣	ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន	៤៨ សម្លេង	៣០/០៣/០៥
២៤	ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ	៤៥ សម្លេង	១២/០៥/០៥
២៥	ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម	៥៣ សម្លេង	៣០/០៥/០៥
២៦	ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨៨ និង មាត្រា ១១១-ថ្មី នៃរដ្ឋធម្មនុញ្ញ	៥៣ សម្លេង	៣០/០៥/០៥
២៧	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ស្តីពីការមិនប្រគល់ខ្លួនជូនតុលាការឧក្រិដ្ឋកម្មអន្តរជាតិ	៥០ សម្លេង	៣០/០៥/០៥
២៨	ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា	៤៧ សម្លេង	៣០/០៥/០៥

សម័យប្រជុំវិសាមញ្ញ

០១	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអន្តរ-រដ្ឋាភិបាល ស្តីពីពាណិជ្ជកម្ម ថាមពលអគ្គិសនីតំបន់ ក្នុងមហាអនុតំបន់មេគង្គ	៤៩ សម្លេង	៣០/០៦/០៥

សម័យប្រជុំពេញអង្គលើកទី ១០

១	ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញា ស្តីពីការកំណត់សំគាល់នៃគ្រឿងផ្ទុះប្លាស្ទិក សំរាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក	៤៩ សម្លេង	០៧/០៩/០៥
២	ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញា ស្តីពីការការពាររូបកាយពីសារធាតុនុយក្លេអ៊ែរ	៤៨ សម្លេង	០៧/០៩/០៥
៣	ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង	៤៧ សម្លេង	០៧/០៩/០៥

៤	ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃអនុសញ្ញា ស្ដីពីការបង្ក្រាបអំពើខុសច្បាប់ ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍ដែនសមុទ្រ	៤៨ សម្លេង	០៧/០៩/០៥
៥	ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអន្តរជាតិ ស្ដីពីការបង្ក្រាបការដាក់គ្រាប់បែកផ្ទុះរបស់ភេរវករ	៤៨ សម្លេង	០៧/០៩/០៥
៦	ច្បាប់ស្ដីពីការអនុម័យល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិក នៃអនុសញ្ញាស្ដីពីការបង្ក្រាបអំពើខុសច្បាប់ ទៅនឹងសុវត្ថិភាពនៃទីតាំងអចិន្ត្រៃយ៍ ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្រ	៤៨ សម្លេង	០៧/០៩/០៥
៧	ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាស្ដីពីការទប់ស្កាត់ និងការដាក់ទោសទៅលើឧក្រិដ្ឋកម្មទាំងឡាយប្រឆាំងនឹងបុគ្គល ដែលត្រូវការពារជាអន្តរជាតិ រួមទាំងភ្នាក់ងារការទូត	៤៩ សម្លេង	០៧/០៩/០៥
៨	ច្បាប់ស្ដីពីបណ្ណសារ	៤៦ សម្លេង	០៨/០៩/០៥
៩	ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្ដីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់-តាំង	៤៨ សម្លេង	១៩/០៩/០៥
១០	ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃពិធីសារស្ដីពីការប្រឆាំងការរត់ពន្ធជនអន្តោ-ប្រវេសន៍នៅតាមដែនគោក ដែនសមុទ្រ និងដែនអាកាស ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្ដីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង	៤៨ សម្លេង	១៩/០៩/០៥
១១	ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអន្តរជាតិ ស្ដីពីការលុបបំបាត់ចោលនូវការផ្ដល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម	៤៨ សម្លេង	១៩/០៩/០៥

១២	ច្បាប់ស្តីពីការអនុម័តព្រមលើពិធីសារនៃការធ្វើវិសោធនកម្ម លើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីតំបន់វិនិយោគអាស៊ាន	៤៨ សម្លេង	១៩/០៩/០៥
១៣	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រណែតធីឡែន	៤៨ សម្លេង	១៩/០៩/០៥
១៤	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការជំរុញ និង ការការពារវិនិយោគ	៤៨ សម្លេង	១៩/០៩/០៥
១៥	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ	៤៨ សម្លេង	១៩/០៩/០៥
១៦	ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការ-ពារជនរងគ្រោះ	៤៥ សម្លេង	២៩/០៩/០៥
១៧	ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូ-ទាត់សងប្រាក់	៤១ សម្លេង	២៩/០៩/០៥
១៨	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែម រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយម-វៀតណាម ទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ ១៩៨៥	៤៩ សម្លេង	២៥/១១/០៥
១៩	ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់	៤៣ សម្លេង	០៨/១២/០៥
២០	ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារ ស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជា-ជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង	៤២ សម្លេង	០៨/១២/០៥

២១	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីការការ-ពារបេតិកភណ្ឌវប្បធម៌អរូបី	៤៣ សម្លេង	០៨/១២/០៥
២២	ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់	៤៣ សម្លេង	០៨/១២/០៥
២៣	ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់-គ្រងឆ្នាំ ២០០៣	៤២ សម្លេង	០៨/១២/០៥
២៤	ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦	៤៩ សម្លេង	២៨/១២/០៥

ក្រៅពីការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ខាងលើ ព្រឹទ្ធសភាបានអនុម័តកិច្ចការជាច្រើនទៀត ដែលទាក់ទងនឹងកិច្ចការផ្ទៃក្នុងរបស់ព្រឹទ្ធសភា ដូចជាការអនុម័តបទបញ្ជាផ្ទៃក្នុង ការបោះឆ្នោតជ្រើសតាំងគណៈកម្មការទាំង៩ ការបោះឆ្នោតបំពេញបន្ថែមសមាជិកគណៈកម្មការនានា និងការប្រកាសទទួលស្គាល់សមាជិកថ្មីរបស់ព្រឹទ្ធសភាបាន ២៦រូប ។

៨.៣ គណៈកម្មាធិការអចិន្ត្រៃយ៍ :

គណៈកម្មាធិការអចិន្ត្រៃយ៍មាន :

- ប្រធានព្រឹទ្ធសភា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍
- អនុប្រធានទាំង ២ របស់ព្រឹទ្ធសភា
- និងប្រធានគណៈកម្មការនានារបស់ព្រឹទ្ធសភា ជាសមាជិក ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមានភារកិច្ច ចាត់ចែងការងាររបស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា រៀបចំរបៀបវារៈនៅពេលប្រជុំព្រឹទ្ធសភានីមួយៗ ធានាការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចលើការចោទប្រកាន់ ការចាប់ខ្លួន ការឃុំខ្លួន ការឃាត់ខ្លួន ដែលពាក់ព័ន្ធដល់ការប្រាសចាកសមាជិកភាពរបស់សមាជិកព្រឹទ្ធសភា ឬបញ្ហាលើកអភ័យឯកសិទ្ធិរបស់សមាជិកព្រឹទ្ធសភាណាមួយ ។

កូរ៉ុមសំរាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងមូល ។ រាល់ការសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវអនុម័តដោយសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកទាំងមូល ។

សមាសភាពនៃគណៈកម្មាធិការអចិន្ត្រៃយ៍មាន :

- គណបក្សប្រជាជនកម្ពុជា ០៥រូប
- គណបក្សហ្វ៊ុនស៊ិនប៉ិច ០៦រូប
- គណបក្សសម រង្ស៊ី ០១រូប

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស
អនុប្រធានទី ១

សម្តេច ជា ស៊ីម ប្រធាន

ឯកឧត្តម ប៉ោ ប៊ុនស្រ៊ី
អនុប្រធានទី ២

លោកជំទាវ ម៉ែន ម៉ាលី

សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី

ឯកឧត្តម ចាន់ តិន

ឯកឧត្តម ជា ចេដ្ឋ

លោកជំទាវ ទី បូរ៉ាស៊ី

ឯកឧត្តម អ៊ុក ប៊ុនឈឿន

ឯកឧត្តម គង់ គាំ

ឯកឧត្តម សឹង អៀម

ឯកឧត្តម សាប៊ូ បាចា

សកម្មភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍

ក្នុងការអនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍ បានប្រជុំចំនួន៩៦លើក ដោយបានរៀបចំរបៀបវារៈនៃសម័យប្រជុំព្រឹទ្ធសភាចំនួន ៩៤ដង អនុម័តសេចក្តីសំរេចស្តីពី តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទាំង៩ អនុម័តគំរោងថវិកា របស់ព្រឹទ្ធសភាប្រចាំឆ្នាំ អនុម័តសេចក្តីសំរេចបង្កើតក្រុមសមាជិកព្រឹទ្ធសភា ទទួលបន្ទុកការងារសហភាពអន្តរសភា (IPU) ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកការងារអន្តរសភាអាស៊ាន (AIPO) ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកការងារសភានៃប្រទេសប្រើភាសាបារាំង (APF) បង្កើតក្រុមមិត្តភាព ជាមួយសភានៃប្រទេសនានា និងអនុម័តសេចក្តីសំរេចជាច្រើនទៀត ។

សកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំព្រឹទ្ធសភា ទទួលអាញត្តិច្បាប់ និងសេចក្តីសំរេចទាំងឡាយ ដែលព្រឹទ្ធសភាបានអនុម័ត រ៉ាប់រងការអនុវត្ត បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងចាត់ចែងការទាក់ទងអន្តរជាតិរបស់ព្រឹទ្ធសភា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈ មិនអាចបំពេញមុខងារបានដោយហេតុមកពីមានជម្ងឺ ឬ បំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅក្រៅប្រទេស អនុប្រធានព្រឹទ្ធសភាមួយរូបទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ថ្នាក់ដឹកនាំ	ដឹកនាំអង្គប្រជុំព្រឹទ្ធសភា	ដឹកនាំអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍	ប្រមុខរដ្ឋស្តីទី
សម្តេច ជា ស៊ីម ប្រធាន	៨៣ពេល	៤៣ពេល	១២ដង
សម្តេច ស៊ីសុវត្ថិ ជីវ័ននុរីរក្ស អនុប្រធានទី ១	៥០ពេល	៤៦ពេល	០១ដង
ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី ២	០៤ពេល	០៦ពេល	០១ដង
ឯកឧត្តម ប៉ោ ប៊ុនស្រ៊ី អនុប្រធានទី ២		០១ពេល	

កំណត់សំគាល់ : ឯកឧត្តម ប៉ោ ប៊ុនស្រ៊ី ទទួលជាអនុប្រធានទី២ បន្ទាប់ពី ឯកឧត្តម ញឹក ប៊ុនឆៃ ទៅទទួលការងារនៅក្នុងរាជរដ្ឋាភិបាល ។

៨.៤ សកម្មភាពរបស់គណៈកម្មការនានា :

គណៈកម្មការរបស់ព្រឹទ្ធសភា មានភារកិច្ចពិនិត្យលើបញ្ហានានា មុននឹងសុំការសំរេចពីប្រធាន ឬពិនិត្យលើអត្ថបទច្បាប់ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន មុននឹងបញ្ជូនទៅសុំការអនុម័តពីព្រឹទ្ធសភា ។ គណៈកម្មការទទួលខុសត្រូវទាំងស្រុងលើយោបល់ដែលខ្លួនបានលើកឡើងជូនអង្គប្រជុំ ។ ក្នុងការពិនិត្យលើអត្ថបទច្បាប់ គណៈកម្មការមានសិទ្ធិសុំឱ្យព្រឹទ្ធសភា លើកចោលពុំពិចារណាបញ្ញត្តិជាមុនថា តើគួរពិចារណា ឬមិនគួរ ? ឬទទួលពិចារណាហើយទុកជាការប្រញាប់ផង ។

ក្រៅពីការពិនិត្យលើអត្ថបទច្បាប់ គណៈកម្មការមានភារកិច្ចតាមដានការអនុវត្តច្បាប់ និងចុះមូលដ្ឋានដើម្បីសួរសុខទុក្ខព្រមទាំងស្វែងយល់ពីសភាពការណ៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

គណៈកម្មការនីមួយៗមានសមាជិក៩រូប មានមន្ត្រីមួយចំនួនជាជំនួយការ មានថវិកាចំនួន ៦លាន រៀលក្នុងមួយខែ និងមាន រថយន្ត ១គ្រឿង ។សមាជិកព្រឹទ្ធសភាម្នាក់ៗ មានការិយាល័យមួយ ដែលបំពាក់ដោយតុ កៅអី ទូដាក់ឯកសារ សាឡុង ទូរស័ព្ទ ទូទឹកកក និងកុំព្យូទ័រ មួយសម្រាប់ ។

ក្នុងចំណោមគណៈកម្មការទាំង៩ មាន៤គណៈកម្មការដែលដឹកនាំដោយ ប្រធានមកពីគណបក្សប្រជាជនកម្ពុជា ។ ៤ គណៈកម្មការទៀត ដឹកនាំដោយ ប្រធានមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច និង១គណៈកម្មការដឹកនាំដោយ ប្រធានមកពី គណបក្សសម រង្ស៊ី ។

៨.៥ សមាសភាព គណៈកម្មការជំនាញទាំង ៩

គណៈកម្មការទី ១ : សិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង

លោកជំទាវ ម៉ែន ម៉ាលី ប្រធាន
(FUN)

ឯកឧត្តម អ៊ុង ធី អនុប្រធាន
(CPP)

ឯកឧត្តម ឡាយ ឈុនសារ៉ែត លេខាធិការ
(FUN)

ឯកឧត្តម កង ចន្ទ សមាជិក
(CPP)

ឯកឧត្តម អ៊ុក ម៉ឿន សមាជិក
(SRP)

១. តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង

គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង ហៅកាត់ថា "គណៈកម្មការទី ១" ។

គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង សរសេរកាត់ថា "គ.ស.ប.ព" ។

គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងនៃព្រឹទ្ធសភាមានតួនាទីដូចតទៅ :

ក- គាំទ្រលើកស្ទួយ និងការពារសិទ្ធិជនគ្រប់រូបឱ្យមានសេចក្តីថ្លៃថ្នូរ និងមានសិទ្ធិស្មើគ្នា ដើម្បីជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងសង្គមជាតិ និងក្នុងសកលលោក ។

ខ- តាមពិនិត្យមើលនូវការអនុវត្តសិទ្ធិមនុស្ស នៅកម្ពុជាឱ្យបានសមស្របទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងឯកសារបទដ្ឋានអន្តរជាតិទាំងឡាយ ក្នុងវិស័យសិទ្ធិមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានចូលរួមទទួលស្គាល់ ។

គណៈកម្មការការពារសិទ្ធិមនុស្ស និង ទទួលពាក្យបណ្តឹងនៃព្រឹទ្ធសភាមានភារកិច្ចដូចតទៅ :

ក. ការងារពាក្យបណ្តឹង:

- ទទួលពាក្យបណ្តឹងទូទៅពីបុគ្គល ពីអ្នកតំណាង ពីក្រុម ពីអង្គការ ឬសមាគមនានា
- ពិនិត្យពាក្យបណ្តឹង និងធ្វើការសម្របសម្រួលដើម្បីស្វែងរកដំណោះស្រាយនៃបណ្តឹងនោះ ដោយធ្វើសហប្រតិបត្តិការជាមួយស្ថាប័ន ឬសមត្ថកិច្ចនានាដោយផ្ទាល់ ឬតាមរយៈលិខិតស្នាម
- ចុះសិក្សាស្រាវជ្រាវជាក់ស្តែង នូវបញ្ហាស្តីអំពីការរំលោភសិទ្ធិមនុស្សនៅតាមមូលដ្ឋាននានាដោយផ្ទាល់
- ធ្វើរបាយការណ៍លើលទ្ធផលនៃការស្រាវជ្រាវនោះ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ឬ លើកសំណូមពរទៅស្ថាប័ននានាដែលពាក់ព័ន្ធ ។

ខ. ការងារច្បាប់:

- ផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ដើម្បីអនុវត្តបទប្បញ្ញត្តិសិទ្ធិមនុស្សនានា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងឯកសារសិទ្ធិមនុស្សអន្តរជាតិទាំងឡាយ ដែលកម្ពុជាបានចុះហត្ថលេខា
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ទាំងឡាយ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូង ហើយដែលពាក់ព័ន្ធលើសិទ្ធិមនុស្ស
- ពិនិត្យមើលសារឡើងវិញ នូវច្បាប់ទាំងឡាយ ដែលបាននឹងកំពុងអនុវត្ត ហើយដែលអាចនាំឱ្យចុះខ្សោយដល់ការលើកស្ទួយសិទ្ធិមនុស្ស ដើម្បីសម្របសម្រួលជាមួយរដ្ឋសភា ឱ្យធ្វើការកែលំអឡើងវិញ
- ផ្តួចផ្តើមគំនិតធ្វើសវនាការជាសាធារណៈ ស្តីពីសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ព្រមទាំងបញ្ហានានាដែលពាក់ព័ន្ធលើវិស័យសិទ្ធិមនុស្ស ។

គ- ការអប់រំ និងផ្សព្វផ្សាយ:

- លើកស្ទួយ និងជំរុញឱ្យមានការអប់រំសិទ្ធិមនុស្ស ចំពោះសិស្ស និស្សិតនៅក្នុងកម្មវិធីសិក្សាគ្រប់កំរិត
- លើកស្ទួយ និងជំរុញឱ្យមានការផ្សព្វផ្សាយចំណេះដឹងសិទ្ធិមនុស្សជាសាធារណៈ តាមរយៈប្រព័ន្ធព័ត៌មាននានា មានវិទ្យុ ទូរទស្សន៍ ការបោះពុម្ពឯកសារជាដើម ។

គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង នៃព្រឹទ្ធសភាមានសមត្ថកិច្ចដូចតទៅ :

ក- ក្រោយពីបានទទួលសិទ្ធិនិងអំណាចពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ឱ្យពិនិត្យសេចក្តីស្នើច្បាប់ ឬ សេចក្តីព្រាងច្បាប់ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូង ឬ បញ្ហានានា ហើយគណៈកម្មការអាចសុំព្រឹទ្ធសភា :

- លើកចោលពុំពិចារណា
- បញ្ចេញមតិជាមុនថាតើគួរពិចារណា ឬមិនគួរ ?
- ទទួលពិចារណា ហើយនិងទុកជាការប្រញាប់ ឬមិនប្រញាប់ក៏បាន ។

ខ- អនុញ្ញាតឱ្យអ្នកតែងច្បាប់មកការពារ និងធ្វើរបាយការណ៍អំពីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅចំពោះមុខ គណៈកម្មការ ។

គ- រាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ឬព្រឹទ្ធសភាពេញអង្គនូវស្ថានភាពរំលោភសិទ្ធិមនុស្ស និង សំណូមពរដើម្បីកែលំអ និងលើកស្ទួយការគោរពសិទ្ធិមនុស្ស ។

ឃ- ផ្តល់យោបល់ទៅរដ្ឋសភា ដើម្បីធ្វើច្បាប់លើកកំពស់វិស័យសិទ្ធិមនុស្សឱ្យល្អប្រសើរ ។

ង- លើកសំណូមពរទៅរាជរដ្ឋាភិបាលលើបញ្ហានានា ដែលទាក់ទងទៅនឹងបញ្ហាសិទ្ធិមនុស្ស ។

ច- ស្រាវជ្រាវប្រមូលផ្តុំនិងវិភាគព័ត៌មាន ដើម្បីបញ្ជាក់ហេតុផលខាងរចនាសម្ព័ន្ធដែលបណ្តាលឱ្យមានការរំលោភសិទ្ធិមនុស្ស និងកំណត់វិធានការដោះស្រាយឱ្យមានប្រសិទ្ធភាព ក្នុងគោលដៅលុបបំបាត់នូវបញ្ហានេះចោល ។

ឆ- អញ្ជើញឥស្សរជន មន្ត្រីរាជរដ្ឋាភិបាល ឬអាជ្ញាធរពាក់ព័ន្ធមកបំភ្លឺបញ្ហាការងារសិទ្ធិមនុស្ស ដែលគណៈកម្មការ ត្រូវការចាំបាច់ ។

ជ- ធ្វើការសម្របសម្រួលជាមួយរាជរដ្ឋាភិបាល ឬអាជ្ញាធរដែលពាក់ព័ន្ធ ដើម្បីចាត់វិធានការទប់ស្កាត់ការរំលោភសិទ្ធិ មនុស្ស ។

ឈ-ចេញសេចក្តីរាយការណ៍ ឬសេចក្តីថ្លែងការណ៍ជាសាធារណៈ និងធ្វើការបញ្ជាក់លើរឿងសិទ្ធិមនុស្ស ។

ញ-ធ្វើសហប្រតិបត្តិការជាមួយអង្គការសិទ្ធិមនុស្សជាតិ អន្តរជាតិ ដើម្បីការពារ និងជំរុញសិទ្ធិមនុស្ស ក្នុងព្រះរាជាណាចក្រ កម្ពុជា ។

ដ- បង្កើតទំនាក់ទំនងជាមិត្តភាពខាងបញ្ហាសិទ្ធិមនុស្សជាមួយសមាជិកសភាបរទេស ។

ឋ- ស្នើសុំប្រធានព្រឹទ្ធសភាឱ្យតែងតាំងអ្នកជំនាញការ និងជំនួយការដែលពុំមែនជាសមាជិកព្រឹទ្ធសភាឱ្យចូលរួម ក្នុងការងារ នៃគណៈកម្មការ តែអ្នកជំនាញការ និងជំនួយការនោះ គ្មានសិទ្ធិនឹងធ្វើការសំរេចជូសមុខឱ្យគណៈកម្មការបានឡើយ ។

គណៈកម្មការទី ២ : ហិរញ្ញវត្ថុ និងធនាគារ

សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី ព្រះប្រធាន
(FUN)

លោកជំទាវ ពុំ ស៊ីចាន់ អនុប្រធាន
(CPP)

ឯកឧត្តម ឆាយ ប៊ិនឡាយ លេខាធិការ
(FUN)

ឯកឧត្តម វ៉ាន់ ម៉ាត់ សមាជិក
(CPP)

ឯកឧត្តម សមាជិក
(SRP)

២. តួនាទី និង ភារកិច្ចរបស់គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ

គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ អាចហៅកាត់ថា "គណៈកម្មការទី ២" ។

គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ សរសេរជាអក្សរកាត់ថា "គ.ហ.ធ" ។

គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ មានតួនាទីសម្របសម្រួលក្នុងបំណងការពារ និងលើកតំកើងប្រសិទ្ធភាពនៃការប្រតិបត្តិច្បាប់ និង លិខិតបទដ្ឋានទាំងឡាយណា ដែលទាក់ទងទៅនឹងកិច្ចការហិរញ្ញវត្ថុ និងធនាគារ ។

គណៈកម្មការហិរញ្ញវត្ថុ និងធនាគារមានភារកិច្ច :

- សិក្សាស្រាវជ្រាវ ប្រមូលព័ត៌មាន ដែលមានទាក់ទងនឹងកិច្ចការជំនាញរបស់គណៈកម្មការហិរញ្ញវត្ថុ និងធនាគារដើម្បីបំពេញភារកិច្ចសម្របសម្រួលការងារ
- ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងបញ្ហានានាជូនគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា
- ធ្វើសេចក្តីរាយការណ៍ និងការពារអំពីសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងបញ្ហានានាដែលបានពិនិត្យ និងផ្តល់យោបល់ពីគណៈកម្មការជូនអង្គប្រជុំព្រឹទ្ធសភាពេញអង្គ និងវិសាមញ្ញ
- សហការជាមួយប្រធានស្ថាប័ន ឬអ្នកធ្វើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ដើម្បីអញ្ជើញឱ្យចូលរួមធ្វើបាយការណ៍ បំភ្លឺ និងការពារច្បាប់
- ទទួលពិនិត្យ និងរកដំណោះស្រាយលើការតវ៉ាទាំងឡាយ ដែលទាក់ទងនឹងមុខជំនាញទៅតាមតួនាទី សមត្ថកិច្ចរបស់គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ ស្របតាមក្របខ័ណ្ឌអំណាចនីតិប្បញ្ញត្តិ
- កសាងគោលការណ៍ បទដ្ឋាន និងនីតិវិធីហិរញ្ញវត្ថុ ធនាគារ ដែលទាក់ទងនឹងថវិការបស់ព្រឹទ្ធសភា ដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍សំរេច
- លើកផែនការថវិកា ត្រួតពិនិត្យ និងវាយតំលៃលើការប្រើប្រាស់ថវិកាស្វយ័តរបស់ព្រឹទ្ធសភា
- ការសិក្សាស្រាវជ្រាវ និងតាមដានលើរាល់កិច្ចការ ដែលទាក់ទងនឹងសវនកម្មជាតិ និងកិច្ចការសវនកម្មផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។

គណៈកម្មការហិរញ្ញវត្ថុ និងធនាគារមានសមត្ថកិច្ចក្នុងការពិនិត្យលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងបញ្ហានានា និងលើកមតិជូនគណៈកម្មាធិការអចិន្ត្រៃយ៍ :

- **អាចលើកចោលពុំពិចារណា**
- **បញ្ចេញមតិជាមុនថា តើគួរពិចារណា ឬមិនគួរ ?**
- **ទទួលពិចារណា ហើយនិងទុកជាការប្រញាប់ផងក៏បាន ។**

គណៈកម្មការទី ៣ : សេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន

ឯកឧត្តម ចាន់ ភិន ប្រធាន
(CPP)

ឯកឧត្តម ហួត ប៉ុងលី អនុប្រធាន
(FUN)

ឯកឧត្តម យ៉ង់ សែម លេខាធិការ
(CPP)

ឯកឧត្តម ប្រាក់ វ៉ាន់នី សមាជិក
(FUN)

ឯកឧត្តម ហ៊ុត ទ្រី សមាជិក
(SRP)

៣. តួនាទី និងភារកិច្ចរបស់គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន

គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន អាចហៅកាត់ថា "គណៈកម្មការទី ៣" ។

គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន សរសេរកាត់ "គ.ស.ផ.វ.ក.អ.ប" ។

គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន មានតួនាទី :

ក- ជាអ្នកជំនួយការគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដែលពាក់ព័ន្ធនឹងការងាររបស់ខ្លួន

ខ- សម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល

គ- សិក្សាពិនិត្យខ្លឹមសារលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងបញ្ហានានាដែលគណៈកម្មាធិការអចិន្ត្រៃយ៍បញ្ជូនមក ។

គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថានមានភារកិច្ច :

ក- ពិនិត្យ ពិចារណា និងដោះស្រាយនូវពាក្យបណ្តឹង និងជួយធ្វើអន្តរាគមន៍ទៅស្ថាប័ន ដែលពាក់ព័ន្ធ

ខ- ស្រង់យកព័ត៌មានណា ដែលមិនប្រក្រតី ឬផ្ទុយនឹងច្បាប់ដែលកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលពាក់ព័ន្ធដល់ព្រឹទ្ធសភា និងគណៈកម្មការទី ៣

គ- ការទំនាក់ទំនងជាមួយអង្គការ ជាតិ និងអន្តរជាតិនានា ដើម្បីស្វែងយល់នូវបញ្ហាទាំងឡាយដែលពាក់ព័ន្ធក្នុងការងាររបស់គណៈកម្មការទី ៣ និងព្រឹទ្ធសភា

ឃ- ចុះបេសកកម្ម អង្កេតនូវបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធដល់គណៈកម្មការទី៣ ហើយធ្វើរបាយការណ៍ជូនគណៈកម្មាធិការ-អចិន្ត្រៃយ៍ព្រឹទ្ធសភា

ង- ភារកិច្ចជាមូលដ្ឋានរបស់គណៈកម្មការទី ៣ គឺការបំពេញការងារតាមការកំណត់របស់រដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ។

គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន មានសមត្ថកិច្ច :

ក- ក្នុងការពិនិត្យលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងលើកមតិជូនគណៈកម្មាធិការអចិន្ត្រៃយ៍ :

- អាចលើកចោលពុំពិចារណា
- បញ្ចេញមតិជាមុនថា តើគួរពិចារណា ឬមិនគួរ ?
- ទទួលពិចារណា ហើយនិងទុកជាការប្រញាប់ផងក៏បាន ។

ខ- សហការជាមួយប្រធានស្ថាប័ន ឬអ្នកធ្វើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ដើម្បីអញ្ជើញឱ្យចូលមកធ្វើបាយការណ៍បំភ្លឺ និងការពារច្បាប់ ។

គណៈកម្មការទី ៤ : មហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត

ឯកឧត្តម ជា ចេដ្ឋ, ប្រធាន
(CPP)

ឯកឧត្តម ធា ចឺរ៉ាត់, អនុប្រធាន
(FUN)

ឯកឧត្តម សេក សំអៀត, លេខាធិការ
(CPP)

ឯកឧត្តម អ៊ុង ស៊ីម, សមាជិក
(FUN)

ឯកឧត្តម ចៅ ផល្លី, សមាជិក
(SRP)

៤. តួនាទី និងភារកិច្ចរបស់គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត

គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាតអាចហៅថា "គណៈកម្មការទី ៤" ។

គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត អាចសរសេរអក្សរកាត់ថា "គ.ម.ក.អ.ប" ។

គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត ជាសេនាធិការជួយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងព្រឹទ្ធសភា :

ក- សម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល

ខ- ពិនិត្យស្រាវជ្រាវ នូវបណ្តាសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងកិច្ចការផ្សេងទៀត ដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការ ។

គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត មានភារកិច្ច :

ក- ពិនិត្យជាប្រក្រតីរាល់សកម្មភាពការងារមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់នានា នៃព្រះរាជាណាចក្រកម្ពុជាដែលនៅជាធរមាន និងបណ្តាកិច្ចព្រមព្រៀងជាមួយបរទេស ស្តីពីការងារមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត

ខ- អង្កេតរាល់ករណីមិនប្រក្រតី (ផ្ទុយពីច្បាប់) ដែលកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ហើយករណីទាំងនោះពាក់ព័ន្ធដល់ព្រឹទ្ធសភា ជាបន្ទុកក្នុងការទទួលខុសត្រូវរបស់គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត

គ- គណៈកម្មការមានភារកិច្ច ពិនិត្យ ពិចារណានូវរាល់ពាក្យបណ្តឹង និងធ្វើអន្តរាគមន៍ជាលាយលក្ខណ៍អក្សរទៅស្ថាប័នដែលមានភារកិច្ចដោះស្រាយ

ឃ- តាមសេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ចុះបេសកកម្មអង្កេត និងបោសសំអាតនូវរាល់សកម្មភាពមិនប្រក្រតីរបស់ស្ថាប័នមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត និងកិច្ចការទាំងឡាយណាដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការ រួចធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីមានវិធានការទៅស្ថាប័នមានសមត្ថកិច្ច។

គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាតមានសមត្ថកិច្ច :

ក- ក្នុងការពិនិត្យ សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងលើកមតិជូនគណៈកម្មាធិការអចិន្ត្រៃយ៍ :

- មិនទទួលយកមកពិចារណា
- ទទួលយកមកពិចារណា ដោយចាត់ទុកថាជាការប្រញាប់ ឬពុំមែនជាការប្រញាប់

ខ- អនុញ្ញាតឱ្យអ្នកតែងច្បាប់ ឬអ្នកដែលមានការពាក់ព័ន្ធមកការពារ និងធ្វើរបាយការណ៍ អំពីសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ នៅចំពោះមុខគណៈកម្មការ

គ- អញ្ជើញឥស្សរជន មន្ត្រីរាជរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធមកបំភ្លឺអំពីបញ្ហាការងារមហាផ្ទៃ ការពារជាតិ និងអធិការកិច្ច ដែលគណៈកម្មការត្រូវការចាំបាច់ ។

គណៈកម្មការទី ៥ : កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

លោកជំទាវ ទី បុរ៉ាស៊ី ប្រធាន
(CPP)

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន អនុប្រធាន
(FUN)

ឯកឧត្តម ឆិត រាម លេខាធិការ
(CPP)

លោកជំទាវ ឈុក ឈឹម សមាជិកា
(CPP)

ឯកឧត្តម ជា គីម សមាជិក
(FUN)

៥. តួនាទី និងភារកិច្ចរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

គណៈកម្មការ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន អាចហៅកាត់ថា "គណៈកម្មការទី ៥" និង សរសេរអក្សរកាត់ថា "គ.ប.ស.ឃ.ព" ។

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន មានតួនាទីសម្របសម្រួលធ្វើឱ្យការអនុវត្តគោលនយោបាយជាតិ លើវិស័យការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មានបានប្រតិបត្តិល្អប្រសើរ ។

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន មានភារកិច្ចដូចតទៅ :

ក- ពិនិត្យស្រាវជ្រាវ ផ្តល់មតិយោបល់ លើរាល់សំណើ សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ លិខិតបទដ្ឋាននានា បញ្ជូនមកពីគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការនានា ឬអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ខ- សម្របសម្រួល ស្រាវជ្រាវ ប្រមូលព័ត៌មានក្នុង និង ក្រៅប្រទេស និងជូនព័ត៌មាន ឬលើកមតិយោបល់ជូនគណៈកម្មាធិការ-អចិន្ត្រៃយ៍ក្នុងករណីចាំបាច់

គ- ជាសេនាធិការរបស់ព្រឹទ្ធសភា ក្នុងការពិនិត្យ តាមដានមើលការអនុវត្តគោលការណ៍ គោលនយោបាយលើវិស័យការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ដែលច្បាប់បានបញ្ញត្តិ និងជួយជូនមតិយោបល់ក្នុងករណីចាំបាច់ ដើម្បីលើកកំពស់គុណភាពការងារលើវិស័យនេះ

ឃ- ទាក់ទងជាមួយគណៈកម្មការនានារបស់រដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីស្វែងយល់ជាមុននូវរាល់គំនិតផ្តើម និងការសំរេចលើ សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហានានាពាក់ព័ន្ធនឹងភារកិច្ចរបស់គណៈកម្មការ

ង- បំពេញការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រគល់ជូន ។

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន មានសមត្ថកិច្ចក្របខ័ណ្ឌនីតិប្បញ្ញត្តិ តាមតួនាទី និងភារកិច្ចរបស់ខ្លួន ។

គណៈកម្មការទី ៦ : នីតិកម្ម

ឯកឧត្តម អ៊ុក ប៊ុនឈឿន ប្រធាន
(CPP)

ឯកឧត្តម រស់ ឆេង អនុប្រធាន
(FUN)

ឯកឧត្តម ថុង ចន់ លេខាធិការ
(CPP)

លោកជំទាវ ម៉ិច សុម៉ាលី សមាជិកា
(FUN)

ឯកឧត្តម ថាច់ សេដ្ឋា សមាជិក
(SRP)

៦. តួនាទី និងភារកិច្ចរបស់គណៈកម្មការនីតិកម្មនៃព្រឹទ្ធសភា

គណៈកម្មការនីតិកម្ម ហៅកាត់ថា "គណៈកម្មការទី ៦" ។

គណៈកម្មការនីតិកម្មសរសេរជាអក្សរកាត់ថា "គ.ន.ក" ។

គណៈកម្មការនីតិកម្មព្រឹទ្ធសភា មានតួនាទីសម្របសម្រួល ធ្វើឱ្យការប្រតិបត្តិរដ្ឋធម្មនុញ្ញ និងច្បាប់ប្រព្រឹត្តទៅមានផែនឯកភាពក្នុងប្រព័ន្ធច្បាប់ ដើម្បីធានាដល់ការគោរពប្រតិបត្តិច្បាប់ឱ្យបានល្អប្រសើរ ។

គណៈកម្មការនីតិកម្ម មានភារកិច្ចដូចតទៅ :

ក- ទទួលពិនិត្យលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានា ដែលទាក់ទងនឹងវិស័យយុត្តាធិការ និងវិស័យច្បាប់ ដែលបញ្ជូនមកដោយគណៈកម្មការនានា ឬគណៈកម្មាធិការអចិន្ត្រៃយ៍ និងនាំយកយោបល់នៃការពិនិត្យជូនស្ថាប័នទាំងនោះ

ខ- ទទួលជួយគណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងការរៀបរៀងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានា ដែលបានត្រូវព្រឹទ្ធសភាអនុម័តតម្រូវឱ្យធ្វើ ឬកែសំរួល

គ- ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់រដ្ឋសភា និងរាជរដ្ឋាភិបាល និងអង្គការយុត្តាធិការ ដើម្បីស្វែងយល់ជាមុននូវរាល់គំនិតផ្តើម និងការសំរេចនៃសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានានោះ

ឃ- ជួយព្រឹទ្ធសភាក្នុងការចុះត្រួតពិនិត្យតាមដានការប្រតិបត្តិរដ្ឋធម្មនុញ្ញ និងច្បាប់ក្នុងជួរមន្ត្រីរាជការ និងប្រជារាស្ត្រ ដើម្បីស្វែងរកការពិត និងនាំយកយោបល់នោះជូនព្រឹទ្ធសភាបើចាំបាច់

ង- បំពេញការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រគល់ឱ្យ ។

សមត្ថកិច្ចរបស់គណៈកម្មការនីតិកម្ម គឺធ្វើក្នុងក្របខ័ណ្ឌអំណាចនីតិប្បញ្ញត្តិទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួន ។

គណៈកម្មការទី ៧ : អប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍

ឯកឧត្តម គង់ គាំ ប្រធាន

(SRP).

ឯកឧត្តម តូច សាក់ អនុប្រធាន

(CPP)

អ្នកម្នាង នរោត្តម ឌីយ៉ាត លេខាធិការ

(FUN)

ឯកឧត្តម ឆ្នាំ ប៊ុនស្រុន សមាជិក

(FUN)

ឯកឧត្តម គង់ សារាជ សមាជិក

(CPP)

៧. តួនាទី និងភារកិច្ចរបស់គណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍

- គណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍ អាចហៅថា "គណៈកម្មការទី ៧" និងអាចសរសេរកាត់ថា "គ.អ.ធ.វ.ទ" ។
- គណៈកម្មការទី ៧ ត្រូវតាមដានប្រព័ន្ធច្បាប់អនុម័តដោយរដ្ឋសភា និងប្រតិបត្តិដោយរាជរដ្ឋាភិបាល ដែលទាក់ទិនដល់កិច្ចការជំនាញរបស់គណៈកម្មការ ដើម្បីបំរើសេចក្តីត្រូវការរបស់ព្រឹទ្ធសភា ។
- បំពេញភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល គណៈកម្មការទី ៧ អាចចុះស្វែងយល់ និងសម្របសម្រួលបញ្ហាច្បាស់លាស់ណាមួយ ក្នុងមុខជំនាញទៅតាមការកំណត់របស់ព្រឹទ្ធសភា ។

គណៈកម្មការទី ៧ ត្រូវទទួលពិនិត្យស្រាវជ្រាវ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ស្របតាមជំនាញដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រគល់ឱ្យ ។

គណៈកម្មការទី ៧ អាចលើកមតិជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា អំពីការយល់ថាមិនគួរទទួលយកមកពិចារណា ឬដោយចាត់ទុកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ថាជាការប្រញាប់ ឬពុំមែនជាការប្រញាប់ ។

គណៈកម្មការទី ៧ មានសិទ្ធិទាក់ទង និងទទួលការសហការពីសមត្ថកិច្ចជំនាញពាក់ព័ន្ធរបស់រដ្ឋសភា របស់រាជរដ្ឋាភិបាល និងរបស់ស្ថាប័នមូលដ្ឋានទាំងអស់យ៉ាងស្មោះអស់ពីចិត្ត ដើម្បីរកព័ត៌មាន និងឯកសារដែលបំរើកិច្ចការរបស់ព្រឹទ្ធសភា ។

គណៈកម្មការទី ៧ មានសិទ្ធិទាក់ទង និងសុំជំនួយពីអង្គការបរទេសនានា ក្រោយពីបានសុំការយល់ព្រមផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរពីគណៈកម្មាធិការអចិន្ត្រៃយ៍ និងដោយមានរបាយការណ៍ ស្តីពីលទ្ធផលនៅពេលបញ្ចប់ ។

គណៈកម្មការទី ៨ : សុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី

ឯកឧត្តម សឹង អឿម ប្រធាន
(FUN)

ឯកឧត្តម ឈា ចាំង អនុប្រធាន
(CPP)

លោកជំទាវ សម កនិដ្ឋា លេខាធិការ
(FUN)

លោកជំទាវ មាន សំអាន សមាជិកា
(CPP)

ឯកឧត្តម ម៉េង រីតា សមាជិក
(SRP)

៨. តួនាទី និងភារកិច្ចរបស់គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី

គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី ហៅកាត់ថា "គណៈកម្មការទី ៨" ហើយអាចសរសេរកាត់ថា "គ.ស.ស.ក.ក" មានតួនាទីដូចតទៅ :

- ជាជំនួយការរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ក្នុងការសម្របសម្រួល នៃការមិនចុះសំរុងគ្នារវាងរាជរដ្ឋាភិបាល និងរដ្ឋសភា ក្នុងវិស័យជំនាញរបស់ខ្លួន
- ត្រួតពិនិត្យ សិក្សា ពិភាក្សា និងវាយតំលៃ កែសម្រួលខ្លឹមសារនៃសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ បទដ្ឋានផ្សេងៗ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ឱ្យ ។

គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី មានភារកិច្ចដូចតទៅ :

- ជួយគណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងការពិនិត្យលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ទាក់ទងនឹងវិស័យសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារីទាំងនោះ ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍វិញ ដើម្បីពិចារណា និងសំរេចជូនទៅព្រឹទ្ធសភា
- ជួយគណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងការចុះត្រួតពិនិត្យតាមដាន នូវការប្រព្រឹត្តទៅរបស់ស្ថាប័នប្រតិបត្តិឱ្យស្របទៅនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ ដើម្បីស្វែងរកការពិត ស្វែងយល់គោលគំនិតលើបញ្ហាពាក់ព័ន្ធ និងមុខជំនាញរបស់គណៈកម្មការ ហើយធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍
- ធ្វើការសម្របសម្រួល ដើម្បីស្វែងរកដំណោះស្រាយរវាងស្ថាប័ននីតិប្រតិបត្តិ និងនីតិប្បញ្ញត្តិ តាមសមត្ថភាពរបស់គណៈកម្មការ ដើម្បីជាប្រយោជន៍ដល់សង្គមជាតិទាំងមូល ។

គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី មានសមត្ថកិច្ចដូចតទៅ :

ក- បង្កនិង បង្កើតទំនាក់ទំនងសហប្រតិបត្តិការរវាងក្រសួងជំនាញពាក់ព័ន្ធ (សុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី) ក្នុងគោលបំណងលើកស្ទួយជីវភាព សុខភាពរបស់ប្រជាពលរដ្ឋ

- ការពារសិទ្ធិសេរីភាព និងផលប្រយោជន៍របស់ប្រជាពលរដ្ឋតូចតាចតាមផ្លូវច្បាប់ឱ្យបានល្អប្រសើរក្នុងវិស័យដូចពោលខាងលើនេះ
- ទំនាក់ទំនងឱ្យបានល្អនឹងគណៈកម្មការទាំង ៨ របស់ព្រឹទ្ធសភា និងស្ថាប័នផ្សេងៗរបស់រាជរដ្ឋាភិបាល ក្រៅពីមុខជំនាញរបស់គណៈកម្មការ ។

គណៈកម្មការទី ៩ : សាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម

ឯកឧត្តម សាប៊ូ បាចា ប្រធាន
(FUN)

ឯកឧត្តម ឈិត គីមយាត អនុប្រធាន
(CPP)

ឯកឧត្តម ហាស សារ៉េន លេខាធិការ
(FUN)

ឯកឧត្តម បៀយ កើក សមាជិក
(CPP)

ឯកឧត្តម ខៀវ សួន សមាជិក
(FUN)

៩. តួនាទី និងភារកិច្ចរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និង ពាណិជ្ជកម្ម

គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម អាចហៅកាត់ថា "គណៈកម្មការទី ៩" ។

គណៈកម្មការ សាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម អាចសរសេរជាអក្សរកាត់ថា "ស.ប.ឧ.ព" ។

គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម មានតួនាទីសម្របសម្រួល ការពារ និងលើកតម្កើងប្រសិទ្ធភាពនៃការប្រតិបត្តិច្បាប់រដ្ឋធម្មនុញ្ញ និងលិខិតបទដ្ឋានទាំងឡាយណា ដែលទាក់ទងនឹងកិច្ចការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ។

គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម មានភារកិច្ច ដូចតទៅ:

- ក- សិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មាន ដែលមានទាក់ទិននឹងកិច្ចការជំនាញរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ដើម្បីបំពេញភារកិច្ចសម្របសម្រួលការងារ
- ខ- ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា
- គ- ធ្វើសេចក្តីរាយការណ៍លើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ដែលបានពិនិត្យ និងផ្តល់យោបល់រួចហើយជូនអង្គប្រជុំព្រឹទ្ធសភាពេញអង្គនិងវិសាមញ្ញ
- ឃ- សហការយ៉ាងជិតស្និទ្ធជាមួយប្រធានស្ថាប័ន ឬអ្នកធ្វើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ដើម្បីអនុញ្ញាតឱ្យអ្នកទាំងនោះអាចចូលមកធ្វើបាយការណ៍ និងការពារច្បាប់
- ង- ទទួលពាក្យពិនិត្យ និងរកដំណោះស្រាយលើការតវ៉ាទាំងឡាយ ដែលទាក់ទិននឹងកិច្ចការជំនាញរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ទៅតាមក្របខ័ណ្ឌអំណាចនីតិប្បញ្ញត្តិនិងទៅតាមតួនាទី សមត្ថកិច្ចរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម
- ជ- រៀបរៀងសេចក្តីស្នើច្បាប់ ឬធ្វើវិសោធនកម្មច្បាប់ ឬបញ្ហាផ្សេងៗ ទៅតាមអំណាចនីតិប្បញ្ញត្តិរបស់ព្រឹទ្ធសភា
- ឈ-ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់រដ្ឋសភា ស្ថាប័ននានានៃរាជរដ្ឋាភិបាល និងអង្គការយុត្តាធិការ ដើម្បីស្វែងយល់ជាមុននូវរាល់គំនិតផ្តួចផ្តើម និងការសម្រេចនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានា
- ញ- បំពេញការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ឱ្យ ។

សមត្ថកិច្ចគណៈកម្មការទី ៩ គ្របដណ្តប់លើវិស័យសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ។

៨.៦ សមាជិក សមាជិកានៅក្រៅគណៈកម្មការរបស់ព្រឹទ្ធសភា

ឯកឧត្តម អ៊ុំ ម៉ាន្ធីន

តំណាងព្រះមហាក្សត្រ

ឯកឧត្តម អៀវ បណ្ណាការ

តំណាងព្រះមហាក្សត្រ

ឯកឧត្តម ម៉ែន សារុន

(CPP)

ឯកឧត្តម ស៊ីម កា

(CPP)

ឯកឧត្តម ស៊ើយ កែវ

(CPP)

ឯកឧត្តម រស់ ស្រេង

(CPP)

ឯកឧត្តម ទេព ងន

(CPP)

ឯកឧត្តម ប៉េង ផាត់

(CPP)

ឯកឧត្តម ជា សុន

(CPP)

លោកជំទាវ ឡាក់ អុន

(CPP)

ឯកឧត្តម ជ័យ សាផុន

(CPP)

ឯកឧត្តម សោម សុផា

(CPP)

ឯកឧត្តម អ៊ុំ សារិទ្ធ

(CPP)

ឯកឧត្តម អ៊ុង ប៊ុនអាង

(SRP)

តារាងសង្ខេបសកម្មភាពរបស់គណៈកម្មការនានា (១៩៩៩-២០០៥)

សកម្មភាពគណៈកម្មការ	គ.១	គ.២	គ.៣	គ.៤	គ.៥	គ.៦	គ.៧	គ.៨	គ.៩
ពិនិត្យអត្ថបទច្បាប់		៣២	២២	០៨	២៤	១៨	០៣	០៩	១២
ចុះមូលដ្ឋាន (លើក)	១៣៦១	១៤៤	២១១	៤៤៣	៥៨	០៥	៦៦៩	៣៤២	៤០៤
ទទួលពាក្យបណ្ដឹង	៩៥០	១០	៦១	៥៣៩	០៥	២៨០	៣៥		

៨.៧ សកម្មភាពរបស់សមាជិក សមាជិកាព្រឹទ្ធសភា

គិតចាប់តាំងពីពេលព្រឹទ្ធសភាត្រូវបានបង្កើតឡើងមកទល់ពេលនេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ជាមួយគ្នានេះដែរ សមាជិក សមាជិកាព្រឹទ្ធសភា បានជួយដោះស្រាយបញ្ហាជាច្រើនជូនប្រជាពលរដ្ឋ ដែលជួបការលំបាកក្នុងជីវភាព ការបង្កបង្កើនផល និងដែលមានបញ្ហាផ្សេងៗ ហើយដែលបានស្នើសុំឱ្យសមាជិក សមាជិកាព្រឹទ្ធសភាជួយធ្វើអន្តរាគមន៍។

ដោយមានការគាំទ្រយ៉ាងពេញលេញពីអង្គការនានា ដូចជាសហភាពអន្តរសភា(IPU)ដែលផ្ដល់មូលនិធិដោយ (UNDP) វិទ្យាស្ថានបណ្ដុះបណ្ដាល ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) គម្រោងគាំទ្រនីតិប្បញ្ញត្តិកម្ពុជា-កាណាដា (CCLSP) មូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ (KAF) ព្រឹទ្ធសភាបារាំង ក្រុមមិត្តភាពសភានៃបណ្ដាប្រទេសប្រើភាសាបារាំង (APF) និងមជ្ឈមណ្ឌលស្ថាប័នប្រជាធិបតេយ្យអូស្ត្រាលី(CDI) ក៏ដូចជាកម្មវិធី អភិវឌ្ឍន៍សហប្រជាជាតិ(UNDP) អង្គការអន្តរសភាអាស៊ាន (AIPO) សមាជិក សមាជិកាព្រឹទ្ធសភា បានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្តអភិវឌ្ឍសមត្ថភាព ក្នុងការតាក់តែងច្បាប់ និងការងារនីតិកម្ម ដើម្បីលើកកំពស់លទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨.៨ គណៈកម្មការពិសេស :

ក្នុងករណីចាំបាច់ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការពិសេស ដែលមានសមាជិកច្រើន ឬតិចតាមតម្រូវការ ។

នីតិកាលទី ១ ព្រឹទ្ធសភាបានបង្កើតគណៈកម្មការពិសេសបី ទទួលបន្ទុកកិច្ចការទាក់ទងនឹងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា និងការពិនិត្យសិក្សាអំពីការស្នើផ្ដល់គ្រឿងឥស្សរិយយស ជូនសមាជិក សមាជិកាព្រឹទ្ធសភា នៅពេលបញ្ចប់នីតិកាលទី ១។

១. គណៈកម្មការពិសេសទទួលបន្ទុកព្រាងសេចក្ដីស្នើបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ដែលអនុម័តដោយព្រឹទ្ធសភាមានសមាសភាពដូចតទៅ :

១. សម្ដេច ស៊ីសុវត្ថិ ជីវ័ន្តមុនីរ៉េត្ន ជាប្រធាន

២. ឯកឧត្តម រ៉ុង ឌី ជាអនុប្រធាន

៣. ឯកឧត្តម រ៉ុក ម៉ឿន ជាលេខាធិការ

៤. ឯកឧត្តម រ៉ុក ប៊ុនឈឿន ជាសមាជិក

៥. ឯកឧត្តម ពៅ សាវ៉ាត ជាសមាជិក

៦. ឯកឧត្តម ជា ម៉េងឈាង ជាសមាជិក

៧. ឯកឧត្តម គីម សុខា ជាសមាជិក

និងមានសមាជិកបំរុង ៥រូប :

១. ឯកឧត្តម ជា ជេដ្ឋ

២. ឯកឧត្តម ផៃ ស៊ីផាន

៣. ឯកឧត្តម យឹម គីមរុន

៤. ឯកឧត្តម ខៀវ សន

៥. ឯកឧត្តម ថាច់ សេដ្ឋា

២. គណៈកម្មការពិសេស ទទួលបន្ទុកតាក់តែងសេចក្តីព្រាងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលបង្កើតដោយថ្នាក់ដឹកនាំព្រឹទ្ធសភា មានសមាសភាព ដូចតទៅ :

១. ឯកឧត្តម អ៊ុក ប៊ុនឈឿន ជាប្រធាន

២. លោកជំទាវ ម៉ែន ម៉ាលី ជាអនុប្រធាន

៣. ឯកឧត្តម ជា ជេដ្ឋ ជាលេខាធិការ

៤. លោកជំទាវ ទី បូរ៉ាស៊ី ជាសមាជិកា

៥. លោកជំទាវ ពុំ ស៊ីចាន់ ជាសមាជិកា

៦. ឯកឧត្តម ចាន់ តិន ជាសមាជិក

៧. ឯកឧត្តម ស៊ឹម អឿម ជាសមាជិក

៨. ឯកឧត្តម សាប៊ូ បាចា ជាសមាជិក

៣. គណៈកម្មការពិសេស ទទួលបន្ទុកពិនិត្យសិក្សាអំពីការស្នើផ្តល់គ្រឿងឥស្សរិយយសជូនសមាជិក សមាជិកាព្រឹទ្ធសភា នៅពេលបញ្ចប់នីតិកាលទី ១ ដែលបង្កើតដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា មានសមាសភាពដូចតទៅ :

១. ឯកឧត្តម ម៉ៅ ប៊ុនស្រ៊ី ជាប្រធាន

២. លោកជំទាវ ម៉ែន ម៉ាលី ជាសមាជិកា

៣. សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី ជាសមាជិកា

៤. ឯកឧត្តម ចាន់ តិន ជាសមាជិក

៥. ឯកឧត្តម ជា ជេដ្ឋ ជាសមាជិក

៦. លោកជំទាវ ទី បូរ៉ាស៊ី ជាសមាជិកា

៧. ឯកឧត្តម អ៊ុក ប៊ុនឈឿន ជាសមាជិក

៨. ឯកឧត្តម គង់ គាំ ជាសមាជិក

៩. ឯកឧត្តម ស៊ិន អឿម ជាសមាជិក

១០. ឯកឧត្តម សារ៉ុ បាចា ជាសមាជិក

៨.៩ ទំនាក់ទំនងសាធារណៈ

ព្រឹទ្ធសភាចាត់ទុកទំនាក់ទំនងសាធារណៈជាកិច្ចការមួយយ៉ាងសំខាន់ ក្នុងចំណោមកិច្ចការសំខាន់ៗឯទៀតរបស់ខ្លួន។ ទំនាក់ទំនងសាធារណៈជាស្ពានផ្សារភ្ជាប់ស្ថាប័នព្រឹទ្ធសភា និងប្រជាពលរដ្ឋទូទាំងប្រទេស។ កិច្ចការនេះជួយព្រឹទ្ធសភាឱ្យបង្កើនបាននូវឧត្តមភាពនៃអំណោចរបស់ខ្លួន ក្នុងការអនុម័តដ៏ត្រឹមត្រូវនូវសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ឬកិច្ចការដទៃទៀត ដែលជាឧត្តមប្រយោជន៍របស់ជាតិ។ ទំនាក់ទំនងសាធារណៈជួយព្រឹទ្ធសភាឱ្យយល់ដឹងអំពីស្ថានភាពពិតរបស់ប្រជាពលរដ្ឋ។ ផ្តើមចេញពីនេះ ប្រជាពលរដ្ឋកាន់តែមានការកក់ក្តៅ និងជឿទុកចិត្តមកលើស្ថាប័នជាន់ខ្ពស់ ហើយនឹងឆ្លើយតបជាវិជ្ជមានមកវិញតាមរយៈការចូលរួមអនុវត្ត។

មធ្យោបាយច្រើនរូបភាព ត្រូវបានយកមកប្រើប្រាស់ក្នុងទំនាក់ទំនងសាធារណៈនេះ ដូចជា:

- ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិមានវិទ្យុ និងទូរទស្សន៍ជាតិ ទាំងរូបភាព និងសម្លេង នូវទិដ្ឋភាពនៃការប្រជុំរបស់ព្រឹទ្ធសភា និងសកម្មភាពផ្សេងៗទៀត របស់ថ្នាក់ដឹកនាំ ឬរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា ឬសមាជិក សមាជិកាព្រឹទ្ធសភា ការផ្សព្វផ្សាយសកម្មភាពផ្សេងៗ តាមព្រឹត្តិបត្រប្រចាំខែរបស់ព្រឹទ្ធសភា (បានចំនួន ៥៣លេខក្នុងមួយលេខៗ មានចំនួន ១៥០០ក្បាល)។

- ការជួបប្រាស្រ័យទាក់ទងផ្ទាល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន ឬការជួបផ្លាស់ប្តូរយោបល់ជាមួយអង្គការសង្គមស៊ីវិល ឬអាជ្ញាធរគ្រប់ជាន់ថ្នាក់ តាមរយៈការប្រជុំដកបទពិសោធន៍ ឬសិក្ខាសាលា។

- ការទទួលជួបជាមួយប្រជាពលរដ្ឋដែលមកសុំពិគ្រោះយោបល់លើបញ្ហាច្បាប់ ឬមកដាក់ពាក្យបណ្តឹងផ្សេងៗនៅមន្ទីរព្រឹទ្ធសភា។

- ការបើកឱ្យប្រជាពលរដ្ឋចូលមកទស្សនា និងថតសមិទ្ធផលនានារបស់ព្រឹទ្ធសភា។

- ការបើកឱ្យសិស្ស និស្សិត មន្ត្រីរាជការចូលមកធ្វើកម្មសិក្សាស្វែងយល់ពីព្រឹទ្ធសភា។

- ការបើកឱ្យសិស្ស និស្សិត មន្ត្រីរាជការចូលមកធ្វើការសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យព្រឹទ្ធសភា (មានចំនួន ១៦៤៥១នាក់ ក្នុងឆ្នាំ ២០០៣ មានចំនួន១៤៥០៣នាក់ ក្នុងឆ្នាំ ២០០៤ និងមានចំនួន ១៩៧៥០នាក់ ក្នុងឆ្នាំ ២០០៥)។

- ការផ្សាយតាមគេហទំព័រ **(Website)** របស់ព្រឹទ្ធសភានូវព័ត៌មាន និងច្បាប់សំខាន់ៗ ។ល។

៨.១០ ទំនាក់ទំនងអន្តរជាតិ

ការងារអន្តរជាតិមានសារៈសំខាន់ ក្នុងការលើកកំពស់កិត្យានុភាពជាតិទាំងនៅក្នុងតំបន់ ទាំងនៅលើពិភពលោក ។

ការងារអន្តរជាតិ បានប្រព្រឹត្តទៅក្រោមរូបភាពជាច្រើន មានការផ្លាស់ប្តូរគណៈប្រតិភូជាន់ខ្ពស់ ការផ្លាស់ប្តូរគណៈប្រតិភូគណៈកម្មការជំនាញ ការចូលរួមក្នុងសិក្ខាសាលា សន្និសីទ និងការប្រជុំផ្សេងៗ ។ ព្រឹទ្ធសភា បានអនុម័តច្បាប់ ផ្តល់សច្ចាប័នលើសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀងពហុភាគី ទ្វេភាគី ។ល ។ ដែលជាកិច្ចការយ៉ាងសំខាន់របស់ព្រឹទ្ធសភាចំនួន ៥៣ច្បាប់ ។

ឆ្នាំ	១៩៩៩	២០០០	២០០១	២០០២	២០០៣	២០០៤	២០០៥
ចំនួនច្បាប់	១០	០៧	០៧	០៧	០១	០២	១៩

ក្នុងន័យពង្រីកនិងពង្រឹងចំណងមិត្តភាព និងសហប្រតិបត្តិការជាមួយរដ្ឋាភិបាល និងអង្គការសភានៃប្រទេសជាមិត្ត សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា បានអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រជប៉ុន សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាមានិតចិន ។ សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** អនុប្រធានទី១ព្រឹទ្ធសភា បានយាងទៅចូលរួមក្នុងសន្និសីទកំពូលនៃព្រឹទ្ធសភាពិភពលោកនៅប្រទេសបារាំង សន្និសីទកំពូលនៃព្រឹទ្ធសភានៅទ្វីបអាហ្វ្រិក នៅប្រទេសម៉ូរីតានី យាងទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងយាងទៅចូលរួមក្នុងសន្និសីទនៃអង្គការអន្តរសភាអាស៊ាន (AIPO) នៅសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ។

ក្នុងនីតិកាលទី ១ គណៈប្រតិភូព្រឹទ្ធសភាចំនួន ៨២ បានអញ្ជើញទៅចូលរួមក្នុងកម្មវិធីផ្សេងៗ នៅប្រទេសជាច្រើន ដើម្បីផ្លាស់ប្តូរបទពិសោធន៍លើការងាររបស់ព្រឹទ្ធសភា ។

ម្យ៉ាងទៀត ព្រឹទ្ធសភាក៏មានកិត្តិយសយ៉ាងខ្ពង់ខ្ពស់ បានទទួលគណៈប្រតិភូក្រុមប្រឹក្សានយោបាយប្រជាជនចិន គណៈប្រតិភូព្រឹទ្ធសភាបារាំង គណៈប្រតិភូព្រឹទ្ធសភាប៊ែលហ្ស៊ិក គណៈប្រតិភូព្រឹទ្ធសភាកាណាដា គណៈប្រតិភូសភាអូស្ត្រាលី ព្រមទាំងគណៈប្រតិភូសមាជិកសភា និងអង្គការសភាជាច្រើនទៀត ។

គណៈប្រតិភូព្រឹទ្ធសភាចេញទៅបរទេស (១៩៩៩-២០០៥)

ឆ្នាំ	១៩៩៩	២០០០	២០០១	២០០២	២០០៣	២០០៤	២០០៥
ចំនួនគណៈប្រតិភូ	៣	១៧	១៨	១២	០៤	០១	២៧

ទន្ទឹមនឹងនោះដែរ តាមរយៈទំនាក់ទំនងសហប្រតិបត្តិការអន្តរជាតិនេះ ព្រឹទ្ធសភាបានទទួលនូវជំនួយ ដែលមានទឹកប្រាក់សរុប ៤.០៧៩.៦៦៣ដុល្លារសហរដ្ឋអាមេរិកពីប្រទេសជាមិត្ត ។

ប្រទេសផ្តល់ជំនួយដល់ព្រឹទ្ធសភា

ល.រ.	ប្រទេសផ្តល់ជំនួយ	បរិយាយ	ថវិកាសរុប (US$)
១	ជប៉ុន	សម្ភារៈការិយាល័យ ម៉ាស៊ីនថតចម្លង កុំព្យូទ័រ មីក្រូហ្វូន និងតម្លើងប្រព័ន្ធទូរស័ព្ទផ្ទៃក្នុង និងជួសជុលអគារ៨ខ្នង	៩២៥.១៦៩.១៦
២	ប្រទេសព្រុយណេ	ជួសជុលអគារ	២០.០០០
៣	សាធារណរដ្ឋប្រជាមានិតចិន	ជួសជុលបំពាក់សម្ភារៈសាលប្រជុំ ជួសជុលផ្លូវថ្នល់ ជំបូលអគារក្រហម សាងសង់បណ្ណាល័យ អគារការិយាល័យ៣ ជួសជុលខ្លោងទ្វារធំ និងរថយន្ត ១២កៅអី ចំនួន ០២ គ្រឿង	៣.០៧៩.៤៩៤
៤	សាធារណរដ្ឋសង្គមនិយមវៀតណាម	កុំព្យូទ័រ តុ កៅអី និងម៉ាស៊ីនថតចម្លង	៥៥.០០០
៥	សាធារណរដ្ឋកូរ៉េ	ទូដាក់ឯកសារ១០ និងរថយន្ត ១គ្រឿង	
៦	សាធារណរដ្ឋឥណ្ឌូនេស៊ី	បំពាក់សម្ភារៈ និងជួសជុលបន្ទប់ទទួលភ្ញៀវ	

យន្តការសំរាប់ដឹកនាំការងារអន្តរជាតិ មានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន។ បន្ទាប់ពីនេះ ព្រឹទ្ធសភាបានបង្កើតឱ្យមានក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកការងារអង្គការសហភាពអន្តរសភា ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកការងារអង្គការអន្តរសភាអាស៊ាន ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកការងារសមាគមសភាប្រទេសប្រើភាសាបារាំង និងបានបង្កើតក្រុមសមាជិកព្រឹទ្ធសភាមិត្តភាពជាមួយប្រទេសជាមិត្តជាច្រើនទៀត។

៩ ការផ្តួចផ្តើមគំនិតធ្វើច្បាប់ :

ព្រឹទ្ធសភានីតិកាលទី ១ (១៩៩៩-២០០៥) នៃព្រះរាជាណាចក្រកម្ពុជា បានសំរេចនូវសមិទ្ធផលដ៏ធំធេង ក្នុងវិស័យកសាងច្បាប់ ដែលរដ្ឋសភាបញ្ជូនមក។ ប៉ុន្តែ នៅចុងនីតិកាលទី ១ នេះ សមាជិកព្រឹទ្ធសភាមួយក្រុម បានផ្តួចផ្តើមគំនិតធ្វើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សំរាប់នីតិកាលបន្តបន្ទាប់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី ៣។ ព្រឹទ្ធសភា បានអនុម័តយល់ស្របលើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១។ បន្ទាប់ពីក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសំរេចលេខ ០៧០/០០២/២០០៥ កបធ.ច ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ច្បាប់នេះត្រូវបានប្រមុខរដ្ឋស្តីទីប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៥ (សូមមើលឧបសម្ព័ន្ធខ)។

១០. សញ្ញាសក្តិ និង ឯកសណ្ឋានរបស់សមាជិក សមាជិកាព្រឹទ្ធសភា

សញ្ញាសក្តិនិងឯកសណ្ឋានរបស់សមាជិកព្រឹទ្ធសភា មានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០១/២៣១ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ ។

១. សញ្ញាសក្តិមាន ៥ប្រភេទ

- សំរាប់ប្រធានព្រឹទ្ធសភា
- សំរាប់អនុប្រធានព្រឹទ្ធសភា
- សំរាប់ប្រធានគណៈកម្មការ
- សំរាប់អនុប្រធានគណៈកម្មការ
- សំរាប់លេខាធិការគណៈកម្មការ សមាជិក សមាជិកាព្រឹទ្ធសភា ។

២. ឯកសណ្ឋានមាន ២ប្រភេទ

- ឯកសណ្ឋានផ្លូវការ
- ឯកសណ្ឋានប្រពៃណីជាតិ ។

ប្រធានព្រឹទ្ធសភា

សក្តិចុងកអាវ

សក្តិស្មា

សក្តិចុងដៃអាវ

អនុប្រធានព្រឹទ្ធសភា

សក្តិចុងកអាវ

សក្តិស្មា

សក្តិចុងដៃអាវ

ប្រធានគណៈកម្មការព្រឹទ្ធសភា

សក្តិចុងកអាវ

សក្តិស្មា

សក្តិចុងដៃអាវ

អនុប្រធានគណៈកម្មការព្រឹទ្ធសភា

សក្តិចុងកអាវ

សក្តិស្មា

សក្តិចុងដៃអាវ

លេខាធិការគណៈកម្មការ និងសមាជិក សមាជិកាព្រឹទ្ធសភា

សក្តិចុងកអាវ

សក្តិស្មា

សក្តិចុងដៃអាវ

សំលៀកបំពាក់ផ្លូវការ



សំលៀកបំពាក់ប្រពៃណីជាតិ



កន្លាស់សញ្ញាព្រឹទ្ធសភា

១១. សេចក្តីសម្រេចផ្សេងៗរបស់ក្រុមប្រឹក្សាធម្មនុញ្ញទាក់ទងនឹងព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៥ ចុះថ្ងៃទី១២ មេសា ឆ្នាំ១៩៩៩

សេចក្តីសម្រេច

លេខ : ០៤ កបធ.សសរ.ច

ចុះថ្ងៃទី ៣០ មេសា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញសំណើលេខ ០០៣/៤៩៩/ពសរប ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ១៩៩៩ របស់សម្តេចប្រធានព្រឹទ្ធសភា សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលទទួលបាននៅអគ្គលេខាធិការ-ដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៩

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់កថាខណ្ឌទី២ ឃ្លាទី ១ ចែងថា "បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ "។ ការសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងដោយសម្តេចប្រធានព្រឹទ្ធសភា ជាការស្របតាមរដ្ឋធម្មនុញ្ញ

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្អែកតាមមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី២ ឃ្លាទី២ ដែលចែងថា "ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ" ។

-យល់ឃើញថា ឃ្លាដើមនៃប្រការ ៩ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាចែងថា "ក្រោយពីព្រះមហាក្សត្រ និងសម្តេចព្រះរាជអគ្គមហេសី ...." មានលក្ខណៈខុសនឹងប្រការ ២ ឃ្លាទី ២ ដែលចែងថា "ព្រះមហាក្សត្រ សម្តេចព្រះរាជអគ្គមហេសី.........." គឺឃ្លាក្រោយនេះពុំមានពាក្យ "និង" ទេ ។

-យល់ឃើញថា ប្រការ ៤៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ស្តីពីការជ្រើសតាំងប្រធានបណ្តោះអាសន្នមួយរូប ឱ្យដឹកនាំការប្រជុំបន្ត ពុំមានចែងក្នុងរដ្ឋធម្មនុញ្ញទេ និងជាប្រការមួយពិបាកនឹងអនុវត្តក្នុងការជាក់ស្តែង ។

សំរេច

មាត្រា១-បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាមាន ១៦ ជំពូក និង ៨០មាត្រា ដែលព្រឹទ្ធសភាបានអនុម័តកាលពី ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ១៩៩៩ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៤៨ ដែលមិនស្របនឹងមាត្រា ១១០ ថ្មី នៃរដ្ឋធម្មនុញ្ញ ។

មាត្រា២- សេចក្តីសំរេចនេះធ្វើនៅភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និងត្រា : ចាន់ សុក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៣១/០០៣/២០០០

ចុះថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០០០

សេចក្ដីសំរេច

លេខ : ០៣៦/០០២/២០០០ កបធ. ច

ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ៨/៤/៩៨ ប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

-បានឃើញបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

-បានឃើញលិខិតលេខ ០៩៥/៥០០/ពស/ជក របស់សម្ដេចប្រធានព្រឹទ្ធសភា ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០០ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា១១៣ ថ្មី ជំពូកទី ៨ ថ្មីនៃរដ្ឋធម្មនុញ្ញ

ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ប្រធានព្រឹទ្ធសភា បានសុំក្នុងលិខិតលេខ ០៩៥/៥០០/ពស/ជក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០០ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយតែវាក្យខណ្ឌទី ១ នៃមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ ជាពិសេសត្រង់សេចក្ដីថា "បើជាការប្រញាប់ រយៈពេលនោះ ត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ" ។

-យល់ឃើញថា យើងអាចលើកយកពាក្យថា "បើជាការប្រញាប់ " មកពិនិត្យបានក្នុង ៤ករណីគឺ:

១-ករណីដែលក្នុងអត្ថបទនៃសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ មានមាត្រាណាមួយ ចែងថា "ច្បាប់នេះ ត្រូវចាត់ទុក ជាការប្រញាប់" ។

២-ករណីដែលមានលិខិតផ្លូវការរបស់រាជរដ្ឋាភិបាល ឬរបស់ម្ចាស់សេចក្ដីស្នើច្បាប់ សុំឱ្យរដ្ឋសភាពិនិត្យសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់នោះជាការប្រញាប់ ។

៣-ករណីដែលមានការស្នើសុំពីរដ្ឋសភា ឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់ ។

៤-ករណីដែលរាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីស្នើច្បាប់ ស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់ ។

ករណីទី ១ : ករណីដែលក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ មានមាត្រាណាមួយចែងថា: "ច្បាប់នេះ ត្រូវបានចាត់ទុកជាការប្រញាប់ " ។

ជាបឋម យើងគួរធ្វើការវែកញែក រវាង " ការប្រញាប់ក្នុងការធ្វើច្បាប់ " ហើយនិង " ការប្រញាប់ក្នុងការអនុវត្តច្បាប់ " ។

"ការប្រញាប់ក្នុងការធ្វើច្បាប់ " គឺបានន័យថា រដ្ឋសភា ត្រូវខំធ្វើនិងអនុម័តច្បាប់ឱ្យបានឆាប់រហ័ស ហើយច្រើនតែតាមសំណើសុំរបស់រាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីស្នើច្បាប់ ។ ប៉ុន្តែ នេះគ្រាន់តែជាការខិតខំរបស់រដ្ឋសភា មិនមែនជាការបង្ខំរដ្ឋសភាឱ្យធ្វើតាមសំណូមពរនោះទេ ។

"ការប្រញាប់ក្នុងការអនុវត្តច្បាប់ "គឺក្នុងន័យដែលមានចែងក្នុងមាត្រា៩៣ ថ្មី វាក្យខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ត្រង់សេចក្តីថា : "ប៉ុន្តែបើច្បាប់នេះបានចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាម នៅទូទាំងប្រទេស ក្រោយថ្ងៃ ប្រកាសឱ្យប្រើ " ។ ពាក្យថា "ចូលជាធរមាន" គឺសំដៅលើការអនុវត្តច្បាប់ ។

ប្រការដែលមានមាត្រាណាមួយចែង ក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើ ច្បាប់ថា : "ច្បាប់នេះ ត្រូវបានចាត់ទុកជាការប្រញាប់ " នោះ គឺសំដៅតែទៅលើ "ការប្រញាប់ ក្នុងការអនុវត្តច្បាប់" ប៉ុណ្ណោះ ពីព្រោះជាខ្លឹមសារ នៃសេចក្តីដែលមានចែងក្នុងច្បាប់តែម្តង ដើម្បីគំរូវការអនុវត្តឱ្យស្របនឹងមាត្រា៩៣ ថ្មី វាក្យខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ។ គឺមិនមែនតាមលិខិតមួយផ្សេងដោយឡែក ដែលធ្វើឡើងដោយរាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីស្នើច្បាប់ ដើម្បីសុំឱ្យរដ្ឋសភាពិនិត្យជាការប្រញាប់ឡើយ ។

ក្នុងករណីនេះ បើមានត្រឹមតែមាត្រា ក្នុងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ចែងថា "ជាការប្រញាប់ " ប៉ុណ្ណោះ គឺមិនមែនជា "ការប្រញាប់ ក្នុងការធ្វើច្បាប់ទេ " ។ ព្រឹទ្ធសភា មានរយៈពេលធម្មតាគឺ ១ខែ សំរាប់ពិនិត្យហើយឱ្យយោបល់ ។

ករណីទី ២ : រាជរដ្ឋាភិបាល ធ្វើលិខិតសុំឱ្យរដ្ឋសភាពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ជាការប្រញាប់ ទោះបីក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់បានចែង ឬមិនបានចែងថា "ច្បាប់នេះត្រូវបានចាត់ទុកជាការប្រញាប់ " ក៏ដោយ ។

ក្នុងករណីនេះ រដ្ឋសភាត្រូវសំរេច លើពាក្យសុំនោះ តាមនីតិវិធីដែលមានចែងក្នុងប្រការ ៤៥ និង ៤៦ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា គឺថារាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីស្នើច្បាប់ ត្រូវជូនហេតុផលអំពីការសុំជាការប្រញាប់នោះ ។ ប្រធានរដ្ឋសភានាំសេចក្តីទៅថ្លែងជាវាបរដ្ឋសភា ដើម្បី សុំរដ្ឋសភាសំរេចថា យល់ព្រមទុកជាប្រញាប់ ឬមិនយល់ព្រម ។

បើរដ្ឋសភាសំរេចយល់ព្រម ពេលនោះរដ្ឋសភាយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ មកពិនិត្យពិភាក្សា

មុនគេ ស្របតាមប្រការ ៤៤ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ ក្រោយបានអនុម័តយល់ព្រមលើកដំបូងហើយ រដ្ឋសភាបញ្ជូនមកព្រឹទ្ធសភា ដើម្បីពិនិត្យនិងឱ្យយោបល់ ដូចមានចែងក្នុងមាត្រា១១៣ ថ្មី វាក្យខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ។ បើគ្មានពាក្យសុំពីរដ្ឋសភាថា ជាការប្រញាប់ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺ ១ខែសំរាប់ពិនិត្យនិងឱ្យយោបល់។

ករណីទី៣ : ជាការត្រឹមត្រូវ រដ្ឋសភាអាចនឹងសុំឱ្យព្រឹទ្ធសភាពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ "ជាការប្រញាប់" បានដែរ នៅពេលដែលរដ្ឋសភាបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលខ្លួនបានអនុម័តយល់ព្រមលើកដំបូងរួចហើយ មកព្រឹទ្ធសភា តាមមាត្រា១១៣ ថ្មី វាក្យខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ។ ការស្នើសុំរបស់រដ្ឋសភាឱ្យព្រឹទ្ធសភា ពិនិត្យជាការប្រញាប់នេះមានចែងក្នុងប្រការ ៤២ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។ ព្រឹទ្ធសភាត្រូវសំរេចលើពាក្យសុំនេះ តាមនីតិវិធីដូចមានចែងក្នុងប្រការ ៤៣ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺថា រដ្ឋសភាត្រូវជូនហេតុផលជាលាយលក្ខណ៍អក្សរ ហើយប្រធានព្រឹទ្ធសភានាំសេចក្តីទៅថ្លែងជំរាបព្រឹទ្ធសភា ដើម្បីសុំព្រឹទ្ធសភាសំរេចថា យល់ព្រម ឬមិនយល់ព្រមទុកជាការប្រញាប់។

ដូច្នេះ វាអាស្រ័យលើព្រឹទ្ធសភាជាអ្នកសំរេច ថាត្រូវទុកជាការប្រញាប់ ឬមិនគួរ ទោះបីមានសំណើពីរដ្ឋសភាថា ទុកជាការប្រញាប់ក៏ដោយ។ បើព្រឹទ្ធសភាយល់ថា គួរទុកជាការប្រញាប់ តាមសំណើរបស់រដ្ឋសភា ពេលនោះព្រឹទ្ធសភាត្រូវអនុវត្តតាមប្រការ ៤១ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺត្រូវចុះសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក្នុងរបៀបវារៈពិភាក្សាមុនគេ ហើយត្រូវពិនិត្យនិងឱ្យយោបល់ ក្នុងរយៈពេលប្រាំថ្ងៃ ដើម្បីឱ្យស្របនឹងមាត្រា ១១៣ ថ្មី វាក្យខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ។ បើព្រឹទ្ធសភាយល់ថា មិនគួរទុកជាការប្រញាប់ទេ ព្រឹទ្ធសភាមានរយៈពេល ១ខែ ដូចធម្មតា សំរាប់ពិនិត្យនិងឱ្យយោបល់។

ករណីទី ៤ : រដ្ឋសភាពុំបានសុំទេ ប៉ុន្តែរាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីស្នើច្បាប់សុំឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់។ នីតិវិធី ដូចក្នុងករណីទី ៣ ដែរ គឺត្រូវអនុវត្តប្រការ ៤១, ៤២ និង ៤៣ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។ ព្រឹទ្ធសភា ជាអ្នកសំរេចខ្លួនឯងថា គួរយល់ព្រមតាមសុំ ឬទេ។ បើយល់ព្រម ត្រូវពិនិត្យ និងឱ្យយោបល់ ក្នុងរយៈពេល ៥ថ្ងៃ។ ប៉ុន្តែ បើមិនយល់ព្រមទេ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺ ១ខែដដែល។

តាមការវិភាគទាំង៤ករណីខាងលើនេះមក ព្រឹទ្ធសភាមានរយៈពេលធម្មតា ១ខែ ក្នុងការពិនិត្យ និងឱ្យយោបល់ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ ក្នុងករណីដែលមានពាក្យសុំពីរដ្ឋសភា ពីរាជរដ្ឋាភិបាល ឬពីម្ចាស់សេចក្តីស្នើច្បាប់ឱ្យពិនិត្យជាការប្រញាប់ ព្រឹទ្ធសភាមានអំណាចសំរេចខ្លួនឯងថា ត្រូវទុក ឬមិនត្រូវទុកជាការប្រញាប់។ -យល់ឃើញថា របៀបគិតរយៈពេល ឬរបៀបរាប់ថ្ងៃ ពុំមានចែងក្នុងច្បាប់ណាមួយឱ្យបានច្បាស់លាស់ទេ ក្នុងប្រទេសយើង។ តាមទម្លាប់រដ្ឋបាលក្តី តុលាការក្តី គេមានរបៀបរាប់ថ្ងៃ និងរយៈពេល ពីរយ៉ាង គឺ :

១-របៀបរាប់រយៈពេលគត់ (ជាភាសាបារាំង គេហៅថា "**délai franc**")។

២-របៀបរាប់រយៈពេលមិនគត់ (ជាភាសាបារាំង គេហៅថា "**délai non franc**") ។

របៀបរាប់ទី ១ : រយៈពេលគត់

គឺគេមិនរាប់ថ្ងៃទទួល (ឯកសារ) ដែលភាសាឡាតាំងហៅថា " **dies a quo** " និងថ្ងៃដែលត្រូវផុតដែលភាសាឡាតាំងហៅថា " **dies ad quem** " ។ ឧបមាថារយៈពេលគត់ ៥ថ្ងៃ ។ ថ្ងៃទទួលឯកសារគឺថ្ងៃទី ៥ មិថុនា ហើយនិងថ្ងៃដែលផុតគឺថ្ងៃទី ១០ មិថុនា ។ គេមិនរាប់ថ្ងៃទី ៥ មិថុនាទេ គឺគេចាប់រាប់ពីថ្ងៃទី ៦ មិថុនា ទៅ ។ គេមិនរាប់ថ្ងៃទី ១០ ខែ មិថុនា ដែលជាថ្ងៃត្រូវផុតទេ គឺគេរាប់ថ្ងៃទី ១១ មិថុនា ទើបចប់ផុតបរិបូរណ៍ ។ ហើយគេរាប់ពីម៉ោង ១២យប់ (ម៉ោងសូន្យ) ដល់ម៉ោង ១២យប់ សំរាប់រាប់មួយថ្ងៃពេញ ។

ដូច្នេះ ក្នុងឧទាហរណ៍ខាងលើនេះ គេត្រូវរាប់ថ្ងៃទី ១១ មិថុនា រហូតដល់ម៉ោង ១២យប់ ទើបផុតរយៈពេលគត់ ៥ថ្ងៃ ។

របៀបរាប់ទី ២ : រយៈពេលមិនគត់

គឺគេមិនរាប់ថ្ងៃទទួល (ឯកសារ) ដូចគ្នានឹងរបៀបទី ១ដែរ ។ ប៉ុន្តែ គេរាប់ថ្ងៃដែលត្រូវផុតគឺថ្ងៃទី ១០ មិថុនា រហូតដល់ម៉ោង ១២យប់ ។

ក្នុងករណីគ្មានការប្រញាប់ គេប្រើរបៀបរាប់ទី ១ ។ រយៈពេលនេះ ច្រើនតែវែង ដូចជា ១ខែ ឬ ២ខែ ។ល ។

ក្នុងករណី "ការប្រញាប់" គេប្រើរបៀបទី ២ ។ រយៈពេលនេះច្រើនតែខ្លី ដូចជា ៥ថ្ងៃ ឬ រាប់ម៉ោង (៤៨ម៉ោង ឬ ៧២ម៉ោង ។ល ។) គេច្រើនប្រើរបៀបរាប់នេះ សំរាប់កិច្ចការដែលប្រញាប់ ដូចក្នុងករណីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាដើម ។

ក្នុងករណីដែលច្បាប់បានចែងថា "ថ្ងៃគត់" គេត្រូវអនុវត្តរបៀបរាប់ទី ១ គឺរយៈពេលគត់ ។

របៀបរាប់ថ្ងៃទាំងពីរយ៉ាងនេះ ប្រទេសយើងធ្លាប់ប្រើកាលក្នុងសម័យមុនមានចំបាំង (ឆ្នាំ១៩៧០) ហើយប្រទេសជាច្រើនក្នុងលោកក៏គេប្រើដែរ ដូចជាប្រទេសបារាំងជាដើម ។

យោងតាមទម្លាប់នេះ មាត្រា១១៣ ថ្មី វាក្យខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញដែលបានបញ្ជាក់ច្បាស់ថា "បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកត្រឹមតែប្រាំថ្ងៃ" បានន័យថា ព្រឹទ្ធសភាត្រូវប្រើរបៀបរាប់ទី ២ គឺរបៀបរាប់រយៈពេលមិនគត់ ។

បើថ្ងៃចុងក្រោយដែលត្រូវចប់ ធ្លាក់ចំថ្ងៃឈប់សំរាក ដូចជាថ្ងៃសៅរ៍ អាទិត្យ ឬថ្ងៃបុណ្យ ដែលច្បាប់អនុញ្ញាតឱ្យឈប់ គេត្រូវរំកិលថ្ងៃនោះរហូតដល់ថ្ងៃចូលធ្វើការទី ១ ពេញមួយថ្ងៃ ទៀត ។

ប៉ុន្តែបើថ្ងៃឈប់សំរាកស្ថិតនៅចន្លោះថ្ងៃទទួលឯកសារ " **dies a quo** " និងថ្ងៃផុតកំណត់ "**dies ad quem**" រយៈពេល (៥ថ្ងៃ) នោះ ឥតមានប្រែប្រួលឡើយ គឺថាគ្មានរកយកថ្ងៃធ្វើការណាមកជំនួសបានទេ ។ នេះជាទម្លាប់ដែលគេតែងប្រតិបត្តិតាមជាទូទៅ សឹងតែគ្រប់ប្រទេស ។

សំរេច

មាត្រា ១ - មាត្រា១១៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ទាក់ទងនឹងឃ្លាថា "បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ" ត្រូវបកស្រាយ ដូចមានចែងក្នុងមូលបទខាងលើ ចំពោះការប្រញាប់ និងរយៈពេល ។

មាត្រា ២ - សេចក្ដីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និងត្រា :ចាន់ សុក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៣៥/០០៧/២០០០

ចុះថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០០០

សេចក្ដីសំរេច

លេខ : ០៣៨/០០៤/២០០០ កបធ. ច

ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០០០

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ២៥៨/១០០០/ពស/អគ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០០ របស់សម្ដេចប្រធានព្រឹទ្ធសភា សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបាននៅអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០០

-បានឃើញឯកសារទទួលពីរដ្ឋសភា ទាក់ទងនឹងការពិភាក្សាលើមាត្រា១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ

ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា មាត្រា ៩៩ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានចែងជាអាទិ៍ថា ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ។

-យល់ឃើញថា ការងារក្នុងក្របខ័ណ្ឌនីតិប្បញ្ញត្តិរបស់ព្រឹទ្ធសភា ត្រូវបានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញរួចហើយ ដូច្នេះមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលចែងថា "*ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល* " គឺជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា ។

-យល់ឃើញថា ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ដើម្បីជួយរកដំណោះស្រាយវិបត្តិនយោបាយ នៅពេលណាដែលវិបត្តិនេះកើតឡើង ។ ការងារនេះ មានវិសាលភាពទូលំទូលាយ

មិនអាចកំរិតព្រំដែនតាមលិខិតបទដ្ឋានអ្វីបានទេ ហើយក៏មិនអាចចែង ជាច្បាប់អ្វីបន្ថែមទៀតពីលើមាត្រា ១១២ ថ្មី ដែរ ។

-យល់ឃើញថា មាត្រា ១១២ ថ្មី បានផ្តល់សិទ្ធិអំណាចជូនព្រឹទ្ធសភា អាចធ្វើអន្តរាគមន៍គ្រប់ពេលវេលា ចូលទៅជួយដោះស្រាយវិបត្តិតូច ឬធំ ក្នុងកិច្ចការនយោបាយរវាងរដ្ឋសភា និងរាជរដ្ឋាភិបាលតាមមធ្យោបាយផ្សេងៗដែលមានដោយពុំកំរិតក្របខ័ណ្ឌនៃពេលវេលាឡើយ ។ មាត្រា ១១២ ថ្មី បានផ្តល់កិត្តិយស និងការទុកចិត្តជូនព្រឹទ្ធសភា ជាហេតុបញ្ជាក់ថា តួនាទីសម្របសម្រួលផ្នែកនយោបាយរបស់ព្រឹទ្ធសភា មានសារៈសំខាន់ណាស់សំរាប់អាយុជីវិតរបស់ប្រទេសជាតិ ។

-យល់ឃើញថា ព្រឹទ្ធសភាមានភាពចាស់ទុំខាងនយោបាយ ដូច្នេះតួនាទីសម្របសម្រួលខាង នយោបាយ នៃព្រឹទ្ធសភាពិតជាត្រូវបានយកចិត្តទុកដាក់ដោយរដ្ឋសភា និងរាជរដ្ឋាភិបាល ។

-យល់ឃើញថា តួនាទីនយោបាយរបស់ព្រឹទ្ធសភា ពុំមានអំណាចចាប់បង្ខំឱ្យរដ្ឋសភា និងរាជរដ្ឋាភិបាលធ្វើតាមព្រឹទ្ធសភាឡើយ ។ ការសម្របសម្រួលរបស់ព្រឹទ្ធសភា អាចចាត់ទុកថា បានលទ្ធផលជាវិជ្ជមាន លុះត្រាតែរដ្ឋសភា និងរាជរដ្ឋាភិបាលព្រមព្រៀងស្រុះស្រួលគ្នា ។

សំរេច

មាត្រា ១ - ក្នុងន័យដូចបានបកស្រាយក្នុងមូលបទខាងលើ ភារកិច្ចរបស់ព្រឹទ្ធសភា ក្នុងការសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ដែលមានចែងក្នុងមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ គឺជាតួនាទី នយោបាយរបស់ព្រឹទ្ធសភា ។

មាត្រា ២ - សេចក្តីសំរេចនេះ ធ្វើឡើងនៅរាជធានីភ្នំពេញថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និងត្រា : ចាន់ សុខ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៥៣/០០៦/២០០២

ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២

សេចក្តីសំរេច

លេខ : ០៤៧/០០៣/២០០២ កបធ.ច

ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២

ក្រុមប្រឹក្សាធម្មនុញ្ញ

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ១៣៤/០៨០២/ពស/ក្រ.ច ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ របស់ស្តេចក្រុមឃុន **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** ប្រធានព្រឹទ្ធសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ "មាត្រា ១០១ ថ្មី" និងពាក្យ "ការបោះឆ្នោតអសកល" ដែលមានប្រើក្នុងមាត្រា ៩៩ ថ្មីនិងមាត្រា ១០០ ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា តាមមាត្រា ១៣៦ ថ្មី វាក្យខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៩ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/ ០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ពាក្យបណ្តឹងរបស់ ស្តេចក្រុមឃុន **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** ប្រធានព្រឹទ្ធសភាស្តីទីខាងលើអាចទទួលយកមកពិចារណាបាន ។

-យល់ឃើញថា ក្នុងមាត្រា ១០១ ថ្មី នៃរដ្ឋធម្មនុញ្ញ ពាក្យដែលគួរពិចារណា និងអាចមានការភាន់ច្រឡំ គឺ*អ្នកបោះឆ្នោត អង្គបោះឆ្នោត មណ្ឌលបោះឆ្នោត* ។

-យល់ឃើញថា *អ្នកបោះឆ្នោត* គឺអ្នកដែលមានគ្រប់លក្ខណៈសម្បត្តិតាមច្បាប់កំណត់ ។

-យល់ឃើញថា *អង្គបោះឆ្នោត* គឺជាក្រុមមនុស្ស ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចទៅបោះឆ្នោតបានតាមការកំណត់នៃច្បាប់ សំរាប់រើសតំណាងឱ្យភូមិភាគ ឬតំណាងវិជ្ជាជីវៈនានា ។ ឧទាហរណ៍ ច្បាប់អាចកំណត់ថា

ជាក្រុមជនជាតិ ជាក្រុមកសិករ ក្រុមអ្នកនេសាទ ក្រុមពាណិជ្ជករ ក្រុមឧស្សាហករ ក្រុមកម្មករ មន្ត្រីរាជការ និងក្រុមវិជ្ជាជីវៈដទៃទៀត ។ល ។

-យល់ឃើញថា *មណ្ឌលបោះឆ្នោត* ជារង្វង់ដែនដីភូមិសាស្ត្រ ដែលច្បាប់កំណត់សំរាប់អង្គបោះឆ្នោត ។ ឧទាហរណ៍ ច្បាប់អាចនឹងកំណត់យកភូមិភាគ ឬខេត្តក្រុង ។ល ។ ជាមណ្ឌលបោះឆ្នោត ។

-យល់ឃើញថា *ការបោះឆ្នោតអសកល* ជាការបោះឆ្នោតមិនទូទៅដូចការបោះឆ្នោតសកល ។ ច្បាប់បន្ថែមលក្ខខណ្ឌផ្សេងទៀតដល់អ្នកបោះឆ្នោត លើសពីលក្ខខណ្ឌដែលតំរូវដល់អ្នកបោះឆ្នោតសកល ។ ឧទាហរណ៍ ដូចជាអ្នកមានសិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោតសកលហើយ ប៉ុន្តែត្រូវជាក្រុមកសិករ ក្រុមអ្នកនេសាទ ក្រុមពាណិជ្ជករ ក្រុមឧស្សាហករ ក្រុមកម្មករ មន្ត្រីរាជការ និងក្រុមវិជ្ជាជីវៈដទៃទៀត ។ល ។ ថែមទៀត ។ ការបោះឆ្នោតអសកលអាចប្រព្រឹត្តទៅដោយចំពោះ ឬមិនចំពោះ ។

សំរេច

មាត្រា ១ : មាត្រា ១០១ ថ្មី នៃរដ្ឋធម្មនុញ្ញ និងពាក្យ *ការបោះឆ្នោតអសកល* ត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្តីសំរេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និងត្រា : ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៥៤/០០៨/២០០២

ចុះថ្ងៃទី១២ ខែ កញ្ញា ឆ្នាំ ២០០២

សេចក្តីសំរេច

លេខ : ០៤៥/០០៤/២០០២ កបធ.ច

ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

-បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការបកស្រាយវាក្យខណ្ឌទី ១ នៃមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ

-បានឃើញលិខិតប្រធានព្រឹទ្ធសភាស្តីទីលេខ ១៥២/០៩០២/ពស/នវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី កថាខណ្ឌទី ២ និងទី ៥ នៃរដ្ឋធម្មនុញ្ញ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីបានសុំក្នុងលិខិតលេខ ១៥២/០៩០២/ពស/នវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី កថាខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ត្រង់សេចក្តីថា "បើព្រឹទ្ធសភា... ពុំបានឱ្យយោបល់សោះ" ហើយនិងកថាខណ្ឌទី ៥ ដែលមានសេចក្តីថា "បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែម ឱ្យស្មើគ្នាដែរ" ។

-យល់ឃើញថា សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការបកស្រាយរដ្ឋធម្មនុញ្ញមានចែងក្នុងមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និងក្នុងមាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

តាមមាត្រា ១៤១ ថ្មី ក្នុងចំណោមឥស្សរជន ដែលអាចលើកសំណើសុំបកស្រាយរដ្ឋធម្មនុញ្ញ ក៏មានប្រធាន ព្រឹទ្ធសភាផងដែរ ។

ដូច្នេះ យោងតាមមាត្រា ១៣៦ ថ្មីនិង ១៤១ ថ្មី នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលពិនិត្យ សំណើសុំបកស្រាយ មាត្រា ១១៣ ថ្មី កថាខណ្ឌទី ២ និងទី ៥ របស់ប្រធានព្រឹទ្ធសភាស្តីទីខាងលើនេះបាន ។

-យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីសុំឱ្យបកស្រាយជាដំបូង កថាខណ្ឌទី ២ នៃមាត្រា ១១៣ ថ្មី ត្រង់ពាក្យថា "បើព្រឹទ្ធសភា... ពុំបានឱ្យយោបល់សោះ" ។

តាមបទប្បញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១១៣ ថ្មី ព្រឹទ្ធសភាត្រូវពិនិត្យ ហើយឱ្យយោបល់ ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្នុងករណីធម្មតា ប៉ុន្តែបើជាការប្រញាប់ គឺត្រឹមតែ ០៥ថ្ងៃប៉ុណ្ណោះ ។ ដូច្នេះក្នុងករណី ធម្មតា ផុតរយៈពេលមួយខែ គិតពីថ្ងៃដែល "រដ្ឋសភា បានដាក់ឱ្យពិនិត្យ" បើព្រឹទ្ធសភានៅស្ងៀមស្ងាត់ឥតធ្វើអ្វី ឬឥតឆ្លើយអ្វីសោះទៅរដ្ឋសភាវិញនោះគឺបានន័យថា "ព្រឹទ្ធសភាពុំបានឱ្យយោបល់សោះ" ។ ប៉ុន្តែពាក្យថា "ព្រឹទ្ធសភា" គឺមានន័យថា ត្រូវមានការប្រជុំពេញអង្គរបស់ព្រឹទ្ធសភា ដើម្បីសំរេចថា "មិនឱ្យយោបល់" ។

បញ្ហាដែលស្មុគស្មាញ គឺនៅត្រង់រដ្ឋសភាសុំឱ្យព្រឹទ្ធសភាពិនិត្យជា "ការប្រញាប់" ។ ក្នុងករណីនេះ បើព្រឹទ្ធសភានៅស្ងៀមមិនឆ្លើយតបទៅវិញហួសពី ៥ថ្ងៃ តើរដ្ឋសភាអាចយកច្បាប់ ដែលរដ្ឋសភាបានអនុម័ត យល់ព្រមហើយនោះទៅប្រកាសឱ្យប្រើបានឬទេ?

យោងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបថ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ និងដូចមានចែងក្នុងប្រការ ៤៣ នៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាដែរ ព្រឹទ្ធសភាមានអំណាចសំរេច ខ្លួនឯងថា "យល់ព្រម ឬមិនយល់ព្រមទុកជាការប្រញាប់" ។ ប៉ុន្តែបើព្រឹទ្ធសភាមិនបានសំរេចអ្វីសោះ ហើយនៅស្ងាត់ស្ងៀម លើសពី ៥ថ្ងៃ នោះ ត្រូវចាត់ទុកថា ព្រឹទ្ធសភាទទួលយល់ព្រមថា ជាការប្រញាប់ ហើយ រដ្ឋសភាអាចយកច្បាប់នោះ ទៅប្រកាសឱ្យប្រើក្នុងរយៈពេល៥ថ្ងៃបាន ។ បើព្រឹទ្ធសភាក្នុងសម័យប្រជុំពេញអង្គ បានសំរេចថា "ជាការប្រញាប់ " តាមសំណើសុំរបស់រដ្ឋសភា ហើយក៏បានធ្វើការពិភាក្សាទៅ ស្រាប់តែមាន ការរាំងស្ទះជាយថាហេតុ បណ្តាលឱ្យហួសរយៈពេលពេល ៥ថ្ងៃទៅនោះ រដ្ឋសភាក្នុងករណីនេះ អាចយកច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះទៅប្រកាសឱ្យប្រើបាន ដោយមិនចាំបាច់រង់ចាំការអនុម័តរបស់ ព្រឹទ្ធសភាឡើយ ។

-យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីបានសុំជាបន្ទាប់មកទៀតឱ្យបកស្រាយកថាខណ្ឌទី ៥ នៃមាត្រា ១១៣ ថ្មី ដែលមានសេចក្តីថា " បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ" ។

កថាខណ្ឌទី៥ នេះទាក់ទងនឹងរយៈពេលនៃ "ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា" ដែលមានចែង ក្នុងកថាខណ្ឌទី៤ នៃមាត្រា ១១៣ ថ្មី ។

ក្នុងករណីព្រឹទ្ធសភាមិនឯកភាពតាមការអនុម័តដំបូងរបស់រដ្ឋសភា ព្រឹទ្ធសភាបង្វិលទៅរដ្ឋសភាជាលើកទី ១ ស្នើសុំកែប្រែ ។ រដ្ឋសភាបានទទួលហើយ ប៉ុន្តែមិនឯកភាពទាំងស្រុង ឬដោយអន្លើនឹងសំណើកែប្រែរបស់ព្រឹទ្ធសភា ក៏បង្វិលមកព្រឹទ្ធសភាវិញសុំឱ្យពិចារណាជាថ្មី ។ ព្រឹទ្ធសភាពិចារណាជាថ្មីហើយ ក៏បង្វិលទៅរដ្ឋសភាវិញ ដោយបញ្ជាក់យោបល់របស់ខ្លួនម្តងទៀត ។ បើរដ្ឋសភាមិនទាន់ឯកភាពតាមព្រឹទ្ធសភា ការបង្វិលទៅបង្វិលមកអាច បន្តទៀតបាន ជាធម្មតា ក្នុងរយៈពេលមួយខែសំរាប់ពិនិត្យច្បាប់ផ្សេងៗ ក្រៅពីច្បាប់ថវិកាជាតិ និងហិរញ្ញវត្ថុដែលត្រូវ កំរិតត្រឹម ១០ថ្ងៃ ។ បើជាការប្រញាប់ រយៈពេលនេះមកនៅត្រឹម ២ថ្ងៃតែប៉ុណ្ណោះ ។ រយៈពេល នៃការបង្វិលនេះ ត្រូវគិតពីថ្ងៃបង្វិលលើកទី ១ របស់ព្រឹទ្ធសភា ។

ពាក្យថា "បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់" បានន័យថា ក្រោយបានទទួលការសុំឱ្យកែសំរួល សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះពីព្រឹទ្ធសភាទៅ រដ្ឋសភាមិនបានធ្វើអ្វីសោះរហូតផុត ១ខែ ឬ ១០ ថ្ងៃ ឬ ២ថ្ងៃ ទៅតាមករណីនីមួយៗដូចបានរៀបរាប់ខាងលើ ។

ពាក្យថា "ពន្យារពេលដែលកំណត់ទុក" បានន័យថា រដ្ឋសភាបានធ្វើការប្រជុំពេញអង្គសំរេចពន្យារពេលពិនិត្យ ឱ្យលើសពី ១ខែ ឬ ១០ថ្ងៃ ឬ ២ថ្ងៃ ទៅតាមករណីនីមួយៗនោះ ។

ពាក្យថា "*រយៈពេលជាគោលការណ៍*សំរាប់រដ្ឋសភា និងព្រឹទ្ធសភា" នោះ គឺរយៈពេល ១ខែ ឬ ១០ថ្ងៃ ឬ ២ថ្ងៃ នេះហើយ ។

ពេលវេលាដែលលើសពីរដ្ឋធម្មនុញ្ញកំណត់ ដោយសារការទុក ឬការសំរេចពន្យាររបស់រដ្ឋសភានេះត្រូវបន្ថែម ឱ្យព្រឹទ្ធសភា ឱ្យបានស្មើគ្នាទៅនឹងរដ្ឋសភាដែរ ។ ក្នុងការអនុវត្តជាក់ស្តែង ដើម្បីឱ្យបានស្មើគ្នាកើតគេត្រូវរាប់ ចំនួនថ្ងៃដែលរដ្ឋសភាបានប្រើប្រាស់ ក្នុងរយៈពេលនោះ ដើម្បីឱ្យដឹងច្បាស់ សំរាប់គិតចំនួនថ្ងៃដែល ព្រឹទ្ធសភាត្រូវមានស្មើគ្នាដែរ ។

ដូច្នេះក្នុង "*រយៈពេលជាគោលការណ៍ ១ខែ*" រដ្ឋសភាមានសិទ្ធិប្រើប្រាស់ ១៥ថ្ងៃ ចំណែកឯព្រឹទ្ធសភា ក៏ ១៥ថ្ងៃ ដូចគ្នាដែរ ។ បើរដ្ឋសភាប្រើពេលលើសថែម ឧបមាថា ៣ថ្ងៃ ខាងព្រឹទ្ធសភា ក៏ត្រូវមានសិទ្ធិបន្ថែម ៣ថ្ងៃ ទៀតដូចៗគ្នា ។

របៀបគិតនេះ ត្រូវអនុវត្តដូចគ្នាចំពោះ "*រយៈពេលជាគោលការណ៍ ១០ថ្ងៃ*" និង "*រយៈពេលជាគោលការណ៍ ២ថ្ងៃ*" ទៅតាមករណីជាយថាហេតុ ។

ជារួមគេត្រូវចែក "*រយៈពេលជាគោលការណ៍*" នីមួយៗជាពីរស្មើគ្នា គឺថាបើ "*១០ថ្ងៃ*" គឺ ៥ ថ្ងៃសំរាប់រដ្ឋសភា ហើយនិង ៥ ថ្ងៃទៀតសំរាប់ព្រឹទ្ធសភា ។ បើ "*២ថ្ងៃ*" គឺ "*១ថ្ងៃ*" សំរាប់ រដ្ឋសភានិង "*១ថ្ងៃ*" ទៀតសំរាប់ព្រឹទ្ធសភា ។ ហើយបើរដ្ឋសភាបន្ថែមលើសប៉ុន្មានថ្ងៃ ព្រឹទ្ធសភា ក៏មានសិទ្ធិបន្ថែមចំនួនថ្ងៃលើសឱ្យស្មើគ្នានឹងរដ្ឋសភាដូចគ្នា ។

គួរកត់សំគាល់ម្យ៉ាងទៀតថា "*រយៈពេលជាគោលការណ៍*" ទាំងអស់នេះសុទ្ធតែជា "*រយៈពេលមិនគត់*" ដែលគេត្រូវអនុវត្តតាមវិធានដែលមានចែងក្នុងសេចក្តីសំរេចរបស់ក្រុមប្រឹក្សា ធម្មនុញ្ញលេខ ០៣៦/០០២/២០០០

កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ ។

សំរេច

មាត្រា ១ : មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី ២ ត្រង់ពាក្យថា "បើព្រឹទ្ធសភា... ពុំបានឱ្យយោបល់សោះ" និងកថាខណ្ឌទី ៥ ត្រូវបកស្រាយ ដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្ដីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និងត្រា : ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៩៦/០០៦/២០០៥

ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៥

សេចក្តីសំរេច

លេខ : ០៧០/០០២/២០០៥ កបធ. ច

ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ៥៣៨ រស ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០៥ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទីស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តយល់ព្រម កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានអនុម័តយល់ព្រមតាមទម្រង់ និងគតិច្បាប់នេះ នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ផងដែរ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលសំណើនេះ នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៥ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវ តាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នេះ ត្រូវបានប្រកាសឱ្យប្រើ

-យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវ នូវបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា ទម្រង់នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

-យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលមាន ១៣ជំពូក ៣៧មាត្រា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

សម្រេច

មាត្រា ១.- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០០៥ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ

មាត្រា ២.- សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និងត្រា : ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៩៨/០០៨/២០០៥

ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៥

សេចក្តីសំរេច

លេខ : ០៧២/០០៤/២០០៥ កបធ.ច

ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៥

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ២០២/០៧០៥/ពស/នវ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៥ របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពប្រការ ៤៤ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ហើយដែលអគ្គលេខាធិការ ដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៥

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដោយប្រធានព្រឹទ្ធសភាជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការពិនិត្យ និងសម្រេចអំពីធម្មនុញ្ញភាពប្រការ៤៤ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានេះ ពុំមានអ្វីផ្ទុយនឹងមាត្រា ១១១ ថ្មី (មួយ) វាក្យខ័ណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញទេ

សម្រេច

មាត្រា ១.- ប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័ត កាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្ត លើអំណាចទាំងអស់ ដែលមាន ចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និងត្រា : ប៊ិន ឈិន

១២. សកម្មភាពដោយរូបភាព

ាក់ដឹកនាំព្រឹទ្ធសភា ធ្វើសវនាការជាមួយថ្នាក់ដឹកនាំសភា នៃប្រទេសនានា

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងប្រធានព្រឹទ្ធសភាកាណាដា

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងប្រធានព្រឹទ្ធសភាបារាំង

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភាម៉ារ៉ុក

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភានូវែលហ្សេឡង់

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងគណៈប្រតិភូសភាប្រទេសហុងគ្រី

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងគណៈប្រតិភូសភាសហគមន៍អឺរ៉ុប

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភាហ្វីលីពីន

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា
និងគណៈប្រតិភូគណៈកម្មាធិការជាតិសភាក្រុមប្រឹក្សានយោបាយប្រជាជនចិន

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងគណៈប្រតិភូអង្គការអន្តរសភាអាស៊ាន
(AIPO)

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភាវៀតណាម

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភាប្រជាជនចិន

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា សហរដ្ឋអាមេរិក

សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី និងសមាជិកសភាអឺរ៉ុប

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា
និងគណៈប្រតិភូសភាសហគមន៍អឺរ៉ុប

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា
និងគណៈប្រតិភូសភាឥណ្ឌូនេស៊ី

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា
និងគណៈប្រតិភូព្រឹទ្ធសភាជប៉ុន

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា
និងអ្នកជំនាញជាន់ខ្ពស់ស្តីពីការអភិវឌ្ឍន៍សភា

ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី ២ ព្រឹទ្ធសភា និងប្រធានរដ្ឋសភាវៀតណាម

ថ្នាក់ដឹកនាំព្រឹទ្ធសភា ធ្វើសវនាការជាមួយប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី នៃប្រទេសនានា

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងប្រធានាធិបតីឥណ្ឌូនេស៊ី

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងប្រធានាធិបតីឥណ្ឌា

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីជប៉ុន

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងគណៈប្រតិភូចិន

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីបង់ក្លាដេស

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីប៉ាគីស្ថាន

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីថៃ

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីថៃ

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីសិង្ហបុរី

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីឡាវ

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស ប្រធានព្រឹទ្ធសភាស្តីទី
និងគណៈប្រតិភូក្រសួងការពារជាតិឥណ្ឌូនេស៊ី

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា
និងរដ្ឋមន្ត្រីក្រសួងការបរទេសបារាំង

ថ្នាក់ដឹកនាំព្រឹទ្ធសភា ទទួលសារតាំងពីប្រទេសនានា

សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី ទទួលសារតាំងពីឯកអគ្គរដ្ឋទូតប៉ូឡូញ

សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី ទទួលសារតាំងពីឯកអគ្គរដ្ឋទូតម៉ារ៉ុក

សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី ទទួលសារតាំងពីឯកអគ្គរដ្ឋទូតកូរ៉េខាងត្បូង

សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី ទទួលសារតាំងពីឯកអគ្គរដ្ឋទូតអូស្ត្រាលី

សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី ទទួលសារតាំងពីឯកអគ្គរដ្ឋទូតសូដង់

សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី ទទួលសារតាំងពីឯកអគ្គរដ្ឋទូតសិង្ហបុ

ថ្នាក់ដឹកនាំព្រឹទ្ធសភា ធ្វើសវនាការជាមួយស្ថានទូត នៃប្រទេសនានា

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសហ្វីលីពីន

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសអូស្ត្រាលី

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសកាណាដា

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសឥណ្ឌូនេស៊ី

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរាជទូតប្រទេសព្រុយណេ

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសអ៊ីរ៉ង់

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសវៀតណាម

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសអាល្លឺម៉ង់

សម្ដេច ជា ស៊ីម ប្រមុខរដ្ឋស្ដីទី និងឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋហុងគ្រី

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសហ្ស៊ីមបាបវ៉េ



សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសរុស្ស៊ី

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសឡាវ

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសលីប៊ី

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសគុបា

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប៉ូឡូញ

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក



សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា ភារធារីនៃស្ថានទូតប៉ាគីស្ថាន

ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី ២ ព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសសិង្ហបុរី

ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី ២ ព្រឹទ្ធសភា និងឯកអគ្គរាជទូតប្រទេស

ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី ២ ព្រឹទ្ធសភា និងឯកអគ្គរាជទូតប្រទេស[illegible]

ថ្នាក់ដឹកនាំព្រឹទ្ធសភា និងបណ្ដាស្ថានទូតនៃប្រទេសនានា
ចូលសំដែងការគួរសម និងជំរាបលា

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសហ្ស៊ីមបាវ៉េ

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរាជទូតប្រទេសថៃ

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតប្រទេសអូស្ត្រាលី

សម្ដេច ជា ស៊ីម ប្រមុខរដ្ឋស្ដីទី និងឯកអគ្គរដ្ឋទូតប្រទេសវៀតណាម

សម្ដេច ជា ស៊ីម ប្រមុខរដ្ឋស្ដីទី និងឯកអគ្គរដ្ឋទូតប្រទេសលីប៊ី

ថ្នាក់ដឹកនាំព្រឹទ្ធសភា ធ្វើទស្សនកិច្ចនៅបរទេស

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា អញ្ជើញទៅធ្វើទស្សនកិច្ចនៅប្រទេសចិន

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងប្រធានាធិបតី នៃប្រទេសចិន

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា យាងធ្វើទស្សនកិច្ច
នៅប្រទេសជប៉ុន

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា យាងធ្វើទស្សន
នៅប្រទេសវៀតណាម

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា
យាងចូលរួមសន្និសីទ នៅប្រទេសម៉ូរីតានី

ឯកឧត្តម ញ៉ឹក ប៊ុនឆៃ អនុប្រធានទី ២ ព្រឹទ្ធសភា អញ្ជើញទៅធ្វើទស្សនកិ
នៅប្រទេសវៀតណាម

សមាជិក សមាជិកាព្រឹទ្ធសភា ធ្វើទស្សនកិច្ចនៅបរទេស

ឯកឧត្តម ជា ចេង ប្រធានគណៈកម្មការទី ៤ ព្រឹទ្ធសភា បានចូលរួមសន្និសីទ នៅប្រទេសហ្វីលីពីន

សមាជិកព្រឹទ្ធសភា ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៣ ស្ដីពី តុលាការអន្តរជាតិ និងបទដ្ឋានច្បាប់ នៅក្រុងវែលលីងតុន នៃប្រទេសនូវែលហ្សេឡង់

ឯកឧត្តម សេក សំអៀត លេខាធិការគណៈកម្មការទី ៤ ព្រឹទ្ធសភា ចូលរួមថ្លែងសុន្ទរកថា ក្នុងអង្គសន្និសីទ នៅប្រទេសបារាំង

លោកជំទាវ ម៉ិច សុម៉ាលី សមាជិកាគណៈកម្មការទី ៦ ព្រឹទ្ធសភា បានចូលរួមប្រជុំ ក្នុងសន្និបាតលើកទី ១១២ នៃសហភាពអន្តរសភា នៅប្រទេសហ្វីលីពីរ

ឯកឧត្តម អ៊ុក ប៊ុនឈឿន ប្រធានគណៈកម្មការទី ៦ ដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា អញ្ជើញទៅទស្សនកិច្ច នៅប្រទេសអូស្ត្រាលី

ឯកឧត្តម ទ៉ាន់ ម៉ាត់ សមាជិកគណៈកម្មការទី ២ ព្រឹទ្ធសភា បានអញ្ជើញទៅទស្សនកិច្ចសិក្សា នៅប្រទេសសហភាពអារ៉ាប់អេមីរ៉ាត

លោកជំទាវ ទី បុរ៉ាស៊ី ប្រធានគណៈកម្មការទី ៥ ដឹកនាំគណៈប្រតិភូសមាជិកាព្រឹទ្ធសភាកម្ពុជា អញ្ជើញទៅធ្វើទស្សនកិច្ចនៅប្រទេសបារាំង

លោកជំទាវ ម៉ែន ម៉ាលី ប្រធានគណៈកម្មការទី ១ អញ្ជើញចូលរួមសន្និសីទ នៅប្រទេសស្វីស

ឯកឧត្តម សាប៊ុ បាចា ប្រធានគណៈកម្មការទី ៩ ដឹកនាំគណៈប្រតិភូព្រឹទ្ធស ចូលរួមមហាសន្និបាតទី ១០៧ នៃIPU ប្រទេសម៉ារ៉ុក

លោកជំទាវ ទី បុរ៉ាស៊ី ប្រធានគណៈកម្មការទី ៥ បានអញ្ជើញចូលរួមសន្និសីទពិភពលោកលើកទី ២ នៅសហរដ្ឋអាមេរិក

ម ជា ចេត ប្រធានគណៈកម្មការទី ៤ បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា អញ្ជើញចូលរួមប្រជុំនៅប្រទេសបារាំង

ឯកឧត្តម អ៊ុំ ទី អនុប្រធានគណៈកម្មការទី ១ អញ្ជើញចូលរួមប្រជុំថ្នាក់អន្តរជាតិ នៅសហរដ្ឋអាមេរិក

លោកជំទាវ ពុំ ស៊ីចាន់ អនុប្រធានគណៈកម្មការទី ២ និងលោកជំទាវ ម៉ិច សុម៉ាលី
ធិការគណៈកម្មការទី ៦ បានអញ្ជើញទៅចូលរួម ក្នុងកិច្ចប្រជុំសភាពិភពលោកលើកទី៥ ប្រទេសម៉ិក

គណៈប្រតិភូសភាកម្ពុជា អញ្ជើញទៅទស្សនកិច្ចសិក្សា នៅប្រទេសកាណាដា

សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ដឹកនាំអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ដឹកនាំអង្គប្រជុំ នាសម័យប្រជុំពេញអង្គ

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ដឹកនាំប្រជុំពេញអង្គព្រឹទ្ធសភា

តំណាងរាជរដ្ឋាភិបាល មកការពារសេចក្តីព្រាងច្បាប់

ឯកឧត្តម ស៊ីង អឿម ប្រធានគណៈកម្មការទី ៨ អានរបាយការណ៍

ឧត្តម អ៊ុង ធី អនុប្រធានគណៈកម្មការទី ១ មានមតិក្នុងសម័យប្រជុំពេញអង្គ

ឯកឧត្តម ជាច់ សេដ្ឋា សមាជិកគណៈកម្មការទី ៦ មានមតិក្នុងសម័យប្រជុំពេញអង្គ

សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចុះមូលដ្ឋាន

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា អញ្ជើញពិនិត្យការដ្ឋានទំនប់សន្ដិ នៅឃុំកក់
ស្រុកពញាក្រែក ខេត្តកំពង់ចាម

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា និងលោកជំទាវ
អញ្ជើញសម្ពោធសាលាបឋមសិក្សា នៅស្រុកកំចាយមារ ខេត្តព្រៃវែង

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា អញ្ជើញចូលរួមបញ្ចុះបឋមសិលា
នៅវត្តចមសុទ្ធាវាស ខេត្តបន្ទាយមានជ័យ

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា អញ្ជើញសម្ពោធសាលា
សម្ដេច ជា ស៊ីម នៅស្រុកបាត់ដំបង ខេត្តបាត់ដំបង

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា អញ្ជើញកាត់ឫសសីមា
នៅវត្តភ្នំក្រោម ខេត្តសៀមរាប

សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា អញ្ជើញទស្សនា
រោងចក្រអគ្គិសនីរបស់ក្រុមហ៊ុន Khmer Electrical Power Co., Lt.I

សម្តេច ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា
ប្រទានអំណោយដល់ប្រជាពលរដ្ឋ នៅស្រុកស្អាង ខេត្តកណ្តាល

សម្តេច ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស អនុប្រធានទី ១ ព្រឹទ្ធសភា
ប្រទានអំណោយដល់ប្រជាពលរដ្ឋ នៅស្រុកបាទី ខេត្តតាកែវ

ុម ញ៉ែក ប៊ុនឆៃ អនុប្រធានទី ២ ព្រឹទ្ធសភា អញ្ជើញសម្ពោធផ្លូវលំមួយខ្សែ
នៅភូមិអន្លង់ឈូក ឃុំអង្គភ្នំតូច ស្រុកអង្គរជ័យ ខេត្តកំពត

ឯកឧត្តម ញ៉ែក ប៊ុនឆៃ អនុប្រធានទី ២ ព្រឹទ្ធសភា អញ្ជើញសម្ពោធស្ពានថ្ម
ទំនប់ដាច់ នៅឃុំកោះធំ ២ ស្រុកកោះធំ ២ ខេត្តកណ្តាល

ាកឧត្តម ចៅ ប៊ុនស្រ៊ី អនុប្រធានទី ២ ព្រឹទ្ធសភា អញ្ជើញចុះសាកសួរ
សុខទុក្ខប្រជាពលរដ្ឋ និងចែកអំណោយ នៅខេត្តកំពង់ឆ្នាំង

ឯកឧត្តម ចៅ ប៊ុនស្រ៊ី អនុប្រធានទី ២ ព្រឹទ្ធសភា អញ្ជើញចុះសាកសួរ
សុខទុក្ខប្រជាពលរដ្ឋ និងចែកអំណោយ នៅខេត្តស្វាយរៀង

សកម្មភាពនៃការចុះមូលដ្ឋានខេត្ត-ក្រុង និងក្រសួង-មន្ទីរនានា

គណៈកម្មការទី ៤ ព្រឹទ្ធសភា ចុះជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងការពារជាតិ នៅក្រសួងការពារជាតិ

សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី ប្រធានគណៈកម្មការទី ២
យាងចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋ នៅមន្ទីរពេទ្យ ព្រះនរោត្តម សីហនុ

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីវត្ត អនុប្រធានគណៈកម្មការទី ៥
យាងចុះសួរសុខទុក្ខប្រជាពលរដ្ឋ នៅខេត្តមណ្ឌលគិរី

សមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋ នៅខេត្តក្រចេះ

ឯកឧត្តម អ៊ុង ធី អនុប្រធានគណៈកម្មការទី ១ អញ្ជើញចុះសាកសួរសុខទុក្ខ អាជ្ញាធរនៅតាមព្រំដែនក្នុងស្រុកបុរីជលសារ ខេត្តតាកែវ

កជំទាវ ធី បុរ៉ាស៊ី ប្រធានគណៈកម្មការទី ៥ បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា
ញ្ជើញចុះសាកសួរសុខទុក្ខ អាជ្ញាធរនៅតាមព្រំដែនក្នុងស្រុកកោះធំ ខេត្តកណ្ដាល

ឯកឧត្តម ជា វេជ្ជ ប្រធានគណៈកម្មការទី ៤ បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា
អញ្ជើញចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ នៅខេត្តក្រចេះ

ជំទាវ ធី បុរ៉ាស៊ី ប្រធានគណៈកម្មការទី ៥ បានដឹកនាំសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ នៅខេត្ត[illegible]

១៣. អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

១៣.១ តួនាទី និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទទួលបន្ទុកធ្វើកំណត់ហេតុរបស់ព្រឹទ្ធសភា របស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងរបស់គណៈកម្មការនានា ។ លើសពីនេះ អគ្គលេខាធិការដ្ឋានទទួលរ៉ាប់រងកិច្ចការរដ្ឋបាលរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅពីព្រឹទ្ធសភា ។

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយរូបជាជំនួយការ ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង តែងតាំងដោយព្រះរាជក្រឹត្យ តាមសេចក្ដីស្នើរបស់ប្រធានព្រឹទ្ធសភា ក្រោយពីបានឯកភាពជាមួយអនុប្រធានទី ១ និងអនុប្រធានទី ២នៃព្រឹទ្ធសភា ។

ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ

ឯកឧត្តម ញឹក ឆៃអេង អគ្គលេខាធិការរង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានរចនាសម្ព័ន្ធដូចតទៅ :

ក. រចនាសម្ព័ន្ធចាស់ (១៩៩៩-២០០៥) មាន :

- អគ្គាធិការដ្ឋាន
- ក្រុមប្រឹក្សាច្បាប់
- នាយកដ្ឋានរដ្ឋបាល ចែកចេញជា ៣ការិយាល័យ
- នាយកដ្ឋានហិរញ្ញវត្ថុ ចែកចេញជា ៣ការិយាល័យ
- នាយកដ្ឋាននីតិវិធី ចែកចេញជា ៣ការិយាល័យ
- ការិយាល័យបច្ចេកទេស
- ការិយាល័យពិធីការ ។

មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ស្ថិតក្រោមច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ។

រចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



ខ. រចនាសម្ព័ន្ធថ្មី (២០០៥...) មាន :

- លេខាធិការដ្ឋាន
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានស្រាវជ្រាវច្បាប់ ចែកចេញជា ៥ការិយាល័យ
- នាយកដ្ឋានរដ្ឋបាល ចែកចេញជា ៤ការិយាល័យ
- នាយកដ្ឋានហិរញ្ញវត្ថុ ចែកចេញជា ៥ការិយាល័យ
- នាយកដ្ឋាននីតិវិធី ចែកចេញជា ៤ការិយាល័យ
- នាយកដ្ឋានជំនួយការគណៈកម្មការនានា ចែកចេញជា ៤ការិយាល័យ
- នាយកដ្ឋានធនធានមនុស្ស ចែកចេញជា ៤ការិយាល័យ
- នាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ ចែកចេញជា ៤ការិយាល័យ
- នាយកដ្ឋានព័ត៌មាន ចែកចេញជា ៥ការិយាល័យ
- នាយកដ្ឋានភូមិភាគ និងសមូហភាពដែនដី ចែកចេញជា ៥ការិយាល័យ
- បណ្ណាល័យ ចែកចេញជា ៤ការិយាល័យ

រចនាសម្ព័ន្ធថ្មីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



ស្ថិតិមន្ត្រីរាជការ

ឆ្នាំ	១៩៩៩	២០០០	២០០១	២០០២	២០០៣	២០០៤	២០០៥
ចំនួន	២១៩	២៥៧	២៩២	៣០២	៣០០	២៧៧	២៨៩



១៣.២ សន្ទានុពលបច្ចុប្បន្នសំរាប់អភិវឌ្ឍ និងលើកកំពស់គុណភាពសេវា សមត្ថភាពរបស់បុគ្គលិក

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចាប់ផ្តើមដំណើរការការងារនៅឆ្នាំ ១៩៩៩ ដោយផ្តើមចេញដំណើរពីតម្រូវការបំពាក់ និង អភិវឌ្ឍធនធានមនុស្ស បច្ចេកទេស សម្ភារៈ ជាមួយនឹងមន្ត្រីដែលមានបទពិសោធន៍មានកំរិត ដែលត្រូវបានផ្ទេរមកពីរដ្ឋសភា ។ ចាប់ពីពេលកកើតមក មន្ត្រីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារដោយយកអស់ពីកំលាំងកាយចិត្ត ដើម្បីរ៉ាប់រងការ ផ្តល់សេវាទាន់ពេលវេលាជូនព្រឹទ្ធសភា ទន្ទឹមនឹងបានខិតខំលើកកំពស់សមត្ថភាពធនធានមនុស្ស ។ ការងារទាំងនេះ អាចសំរេចបាន ក៏ដោយសារមានការគាំទ្រពីអង្គការជាដៃគូ ដែលបានជួយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីជំនះលើការលំបាកមួយចំនួនក្នុងការ គ្រប់គ្រង និងបង្កើនសមត្ថភាពដល់មន្ត្រីទូទៅ ។

អគ្គលេខាធិការព្រឹទ្ធសភា និងថ្នាក់គ្រប់គ្រង គាំទ្រឱ្យមានការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិក ។ មន្ត្រីគ្រប់រូប បានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញផ្សេងៗ ។ ការបណ្តុះបណ្តាលនេះ ចែកចេញជាបីប្រភេទ គឺការបណ្តុះបណ្តាលនៅក្រៅប្រទេស ការបណ្តុះបណ្តាលក្នុងប្រទេស និងការបណ្តុះបណ្តាលនៅនឹងកន្លែង (អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា) ។

ការបណ្តុះបណ្តាលនៅក្រៅប្រទេស

ការបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សានៅក្រៅប្រទេស ត្រូវបានរៀបចំឱ្យមានឡើង ដើម្បីជួយឱ្យមន្ត្រីអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា បានស្វែងយល់ពីបទពិសោធន៍ការងារដោយផ្ទាល់នៅក្នុងប្រទេស ដែលមានប្រព័ន្ធ និងដំណើរការសភាមានលក្ខណៈ រីកចំរើនជឿនលឿន ។ មានការចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនៅសិង្ហបុរី បារាំង កាណាដា នូវែលហ្សេឡង់ ជប៉ុន អូស្ត្រាលី ការធ្វើទស្សនកិច្ចសិក្សានៅព្រឹទ្ធសភានៃបណ្តាប្រទេសមួយចំនួន ដូចជាជប៉ុន អូស្ត្រាលី កាណាដា ថៃ ស៊ុយអែត ហ្វីលីពីន វៀតណាម

ចិន បារាំង ឡាវ និងការចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលវែងនៅអូស្ត្រាលី ជប៉ុន និងនូវែលហ្សេឡង់ ។

ការបណ្តុះបណ្តាលក្នុងប្រទេស

កម្មវិធីបណ្តុះបណ្តាលបុគ្គលិកនៅក្នុងប្រទេស មានគោលបំណងពង្រឹងសមត្ថភាពជំនាញផ្នែករដ្ឋបាល និងច្បាប់ជូនដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីបំរើសេវាជូនព្រឹទ្ធសភាប្រកបដោយគុណភាព ។ នៅលើមុខជំនាញច្បាប់ ដោយមានការគាំទ្រពីមូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ (KAF) និងការជួយឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា (CIDA) មន្ត្រីមួយចំនួនធំត្រូវបានធ្វើការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពលើមុខជំនាញរដ្ឋបាលរៀងរាល់ឆ្នាំ មន្ត្រីជាច្រើនរូបបានចូលរួមបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល និងមានមុខជំនាញជាច្រើនទៀតដែលបានបណ្តុះបណ្តាល ដូចជាការងារគ្រប់គ្រងបណ្ណាល័យ ជវលេខខ្មែរ ជំនាញលេខាធិការ សារព័ត៌មាន ទ្រឹស្តីនៃការព្រាង និងតាក់តែងច្បាប់ ជំនាញវិភាគច្បាប់ ច្បាប់អន្តរជាតិ និងភាសាបរទេស (ភាសាអង់គ្លេស និងភាសាបារាំង) ។ល ។

ការបណ្តុះបណ្តាលនៅនឹងកន្លែង (អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា)

ការបណ្តុះបណ្តាលនៅនឹងកន្លែង គឺជាការកសាងសមត្ថភាពបន្ថែមដល់មន្ត្រីរាជការ ដើម្បីបានយល់ដឹងពីបទបញ្ជាផ្ទៃក្នុង ច្បាប់រដ្ឋធម្មនុញ្ញ ការងាររបស់គណៈកម្មការ និងអភិបាលកិច្ចល្អ ។ ជាទូទៅ ការបណ្តុះបណ្តាលនៅនឹងកន្លែងផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើផ្នែករដ្ឋបាល ច្បាប់ ហិរញ្ញវត្ថុ ការគ្រប់គ្រងបណ្ណាល័យ ជំនាញកុំព្យូទ័រ ជំនាញលេខាធិការ ភាសាអង់គ្លេសទូទៅ និង បកប្រែភាសាអង់គ្លេស-ខ្មែរ និងខ្មែរ-អង់គ្លេស និងជំនាញផ្សេងៗទៀត ។

ការបណ្តុះបណ្តាលនៅនឹងកន្លែង ដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឱ្យដំណើរការល្អប្រសើរមានការយល់ដឹងកើនឡើងក្រោមការជួយឧបត្ថម្ភ គាំទ្រពីដៃគូអន្តរជាតិ មានជាអាទិ៍ គម្រោងកិច្ចសហប្រតិបត្តិការកម្ពុជា-កាណាដា គាំទ្រលើការងារនីតិកម្មរយៈពេល ៥ឆ្នាំ និងគម្រោងរយៈពេល ៣ឆ្នាំរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងអង្គការនានាដូចជាសហភាពអន្តរសភា (IPU) គម្រោងគាំទ្រអង្គការនីតិបញ្ញត្តិកម្ពុជា-កាណាដា (CCLSP) មូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ (KAF) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងមជ្ឈមណ្ឌលប្រជាធិបតេយ្យអូស្ត្រាលី (CDI) ជាពិសេសការចូលរួមផ្តល់វិភាគទានដ៏ថ្លៃថ្លា នៅក្នុងកិច្ចខិតខំប្រឹងប្រែងពីសំណាក់ព្រឹទ្ធសភាបារាំង ។

ជាទូទៅ គំនិតផ្តួចផ្តើមបណ្តុះបណ្តាល និងកម្មវិធីកសាងសមត្ថភាពទាំងនេះទទួលបានលទ្ធផលល្អ និងបានជួយឱ្យអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្លើយតបទៅនឹងតម្រូវការរបស់ព្រឹទ្ធសភាបានយ៉ាងមានប្រសិទ្ធភាព ។

១៣.៣ សកម្មភាពរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ក. ផ្តល់សេវាជូនព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាខាងច្បាប់ នីតិវិធី រដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស និងខាងពិធីការដោយស្មារតីយកចិត្តទុកដាក់ និងទទួលខុសត្រូវ ក្នុងការទ្រទ្រង់សកម្មភាពរបស់ព្រឹទ្ធសភា ឱ្យដំណើរការទៅបានយ៉ាងរលូន និងទទួលបានជោគជ័យ ។

ខ. ជួយគាំទ្រដល់ការពិគ្រោះយោបល់ជាសាធារណៈ

អគ្គលេខាធិការដ្ឋាន បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការរៀបចំវេទិកាសាធារណៈ ដែលផ្តល់ឱកាសឱ្យសមាជិកព្រឹទ្ធសភា និងអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល បានធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់ បទពិសោធន៍ លើប្រធានបទសំខាន់ៗជាច្រើន និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នានា ។

គ. រៀបចំផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ (២០០៣-២០០៨)

ដោយមានការសហការ និងជួយឧបត្ថម្ភគាំទ្ររបស់គម្រោងគាំទ្រនីតិប្បញ្ញត្តិកម្ពុជា-កាណាដា(CCLSP) និងរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានកសាងផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំរបស់ព្រឹទ្ធសភា ដើម្បីជួយឱ្យស្ថាប័នព្រឹទ្ធសភាដំណើរការរបស់ខ្លួនទៅមុខប្រកបដោយជោគជ័យ ។

ផែនការយុទ្ធសាស្ត្រនេះ បានលើកឡើងនូវគោលដៅធំៗ ចំនួន ៥ ដូចតទៅ :

គោលដៅទី ១ :

ពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងជំនាញដល់បុគ្គលិកនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីអាចឆ្លើយតបបានយ៉ាងពេញលេញទៅនឹងការរំពឹងទុករបស់សមាជិកព្រឹទ្ធសភា និងគណៈកម្មការរបស់ព្រឹទ្ធសភា ។

គោលដៅទី ២ :

ពង្រឹងរចនាសម្ព័ន្ធរួម ប្រព័ន្ធគោលនយោបាយ និងនីតិវិធីទាក់ទងនឹងការងារផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

គោលដៅទី ៣ :

រៀបចំឱ្យមានយុទ្ធសាស្ត្រព័ត៌មាន ដែលក្នុងនោះរួមមានការធ្វើផែនការ ការតម្លើងប្រព័ន្ធព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានទំនើប ។

គោលដៅទី ៤ :

ជំរុញសេវាស្រាវជ្រាវព័ត៌មាន និងការងារចងក្រងឯកសាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឱ្យបានល្អប្រសើរឡើង ដើម្បីធ្វើឱ្យការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការងាររបស់ព្រឹទ្ធសភា ទៅកាន់សាធារណជន និងសង្គមស៊ីវិលកាន់តែមានប្រសិទ្ធភាព ។

គោលដៅទី ៥ :

អភិវឌ្ឍសមត្ថភាពដល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីឱ្យមានលទ្ធភាពធ្វើទំនាក់ទំនងជាមួយនឹងស្ថាប័នជាតិ អង្គការក្រៅរដ្ឋាភិបាល សាធារណជន សង្គមស៊ីវិល សារព័ត៌មាន សភាបរទេស និងគណៈកម្មការសភាកាន់តែល្អប្រសើរឡើង ។

ផ្អែកតាមផែនការយុទ្ធសាស្ត្រនេះ អង្គភាពទាំងអស់បានរៀបចំឡើងនូវផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ខ្លួន ដើម្បីជាមូលដ្ឋាននៃការធ្វើសកម្មភាពប្រចាំឆ្នាំ ២០០៤ ឆ្នាំ ២០០៥ និងឆ្នាំ ២០០៦ ។

ឃ. ពង្រឹងសមត្ថភាពមន្ត្រីរាជការ

ការពង្រឹងសមត្ថភាពមន្ត្រីរាជការ ជាចំណែកមួយយ៉ាងធំនៅក្នុងសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ។

ការពង្រឹងសមត្ថភាពខាងជំនាញ ទៅតាមតម្រូវការនៃការងាររបស់ព្រឹទ្ធសភា បានទទួលលទ្ធផលល្អជាជំហានតាមរយៈការបណ្តុះបណ្តាលនៅក្រៅប្រទេស និងការបណ្តុះបណ្តាលនៅក្នុងប្រទេស ។

អគ្គលេខាធិការដ្ឋាន បានបញ្ជូនមន្ត្រីជាបន្តបន្ទាប់ឱ្យទៅទទួលការបណ្តុះបណ្តាលរយៈពេលវែង នៅអូស្ត្រាលី ជប៉ុន និងទួរលហ្សេឡង់ រយៈពេលខ្លីនៅសិង្ហបុរី បារាំង ជប៉ុន កាណាដា និងធ្វើទស្សនកិច្ចសិក្សានៅសភាអូស្ត្រាលី កាណាដា ថៃឡង់ដ៏ ស៊ុយអែត ហ្វីលីពីន វៀតណាម ចិន បារាំង ឡាវ ។ល ។

នៅក្នុងប្រទេស ការបណ្តុះបណ្តាលមានសភាពមមាញឹក ដោយផ្តោតលើមុខជំនាញជាច្រើនជាអាទិ៍ ច្បាប់ រដ្ឋបាល លេខាធិការ គ្រប់គ្រង សវនកម្ម ភាសាអង់គ្លេស បារាំង កុំព្យូទ័រ ។ល ។

ស្ថិតិមន្ត្រីរាជការដែលបានទទួលការបណ្តុះបណ្តាលក្រៅប្រទេស

(តួលេខរបស់ការិយាល័យបុគ្គលិក ឆ្នាំ ២០០៥)

ឆ្នាំ	១៩៩៩	២០០០	២០០១	២០០២	២០០៣	២០០៤	២០០៥
ចំនួន			០១នាក់	០២នាក់	១០នាក់	២៧នាក់	០៤នាក់

ស្ថិតិមន្ត្រីរាជការដែលបានទទួលការបណ្តុះបណ្តាលក្នុងប្រទេស

(តួលេខរបស់ការិយាល័យបុគ្គលិក ឆ្នាំ ២០០៥)

ឆ្នាំ	១៩៩៩	២០០០	២០០១	២០០២	២០០៣	២០០៤	២០០៥
ចំនួនវគ្គ	០៦	១៤	១៨	២៨	២០	៤៥	១៥
ចំនួនមនុស្ស	៣៧នាក់	៨១នាក់	២០០នាក់	៣៤១នាក់	៣៧៩នាក់	១០៦៩នាក់	៥០៩នាក់

ស្ថិតិមន្ត្រីរាជការតាមសញ្ញាប័ត្រ

(តួលេខរបស់ការិយាល័យបុគ្គលិក ឆ្នាំ ២០០៥)

ឆ្នាំ / កំរិតវប្បធម៌	១៩៩៩	២០០០	២០០១	២០០២	២០០៣	២០០៤	២០០៥
ចំនួនសរុប	២១៩នាក់	២៥៧នាក់	២៩២នាក់	៣០២នាក់	៣០០នាក់	២៧៧នាក់	២៨៩នាក់
ក្រោមទុតិយភូមិ	៦០នាក់	៧៥នាក់	៨៥នាក់	១០២នាក់	១០៩នាក់	៩៩នាក់	៩៧នាក់
ទុតិយភូមិ	១០០នាក់	១០៥នាក់	៩០នាក់	៦១នាក់	៤៩នាក់	៤៥នាក់	៤៨នាក់
បរិញ្ញាប័ត្ររង	០៦នាក់	០៩នាក់	១០នាក់	៣០នាក់	២៩នាក់	២៦នាក់	២៨នាក់
បរិញ្ញាប័ត្រ	៥០នាក់	៦៥នាក់	១០៤នាក់	១០៥នាក់	១០៧នាក់	៩៣នាក់	៩៧នាក់
អនុបណ្ឌិត	០៣នាក់	០៣នាក់	០៣នាក់	០៤នាក់	០៦នាក់	១៤នាក់	១៥នាក់

ង. ផ្ទេរមន្ត្រីរាជការចូលក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

បន្ទាប់ពីការចូលជាធរមាននៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ មន្ត្រីរាជការទាំងអស់ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវបានផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ។ ការផ្ទេរនេះធ្វើឡើងដោយប្រុងប្រយ័ត្ន និងគ្រប់ជ្រុងជ្រោយ ដើម្បីការពារឱ្យបានជាអតិបរមានូវផលប្រយោជន៍របស់អ្នករាជការម្នាក់ៗ និងធានាបាននូវភាពយុត្តិធម៌ និងសមធម៌សំរាប់ទាំងអស់គ្នា។ មន្ត្រីទាំងអស់ដែលបានផ្ទេរមានចំនួន ២៨៩នាក់ ក្នុងនោះ ១៤៣នាក់ ចូលក្នុងក្របខ័ណ្ឌអភិបាល ៤២នាក់ ចូលក្នុងក្របខ័ណ្ឌឧបការី ២១នាក់ ចូលក្នុងក្របខ័ណ្ឌលេខាធិការ និង ៨៤នាក់ ចូលក្នុងក្របខ័ណ្ឌភ្នាក់ងារ។

មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ មានប្រព័ន្ធបៀវត្សមួយត្រឹមត្រូវ និងមានបៀវត្សសមរម្យខ្ពស់ជាងមុន។

ច. ទំនាក់ទំនងអន្តរជាតិ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានយកការងារទំនាក់ទំនងអន្តរជាតិ ជាកំលាំងក្នុងការអភិវឌ្ឍស្ថាប័នព្រឹទ្ធសភា។ ជាក់ស្តែង អគ្គលេខាធិការដ្ឋាន មានចំណងសហប្រតិបត្តិការជាមួយសហភាពអន្តរសភា (IPU) អង្គការអន្តរសភាអាស៊ាន (AIPO) សហគមសភានៃប្រទេសប្រើភាសាបារាំង(APF) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា(CIDA) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) មូលនិធិខុនរ៉ាដអាឌិនណៅអែរ (KAF) ព្រឹទ្ធសភាបារាំង អូស្ត្រាលី សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋសង្គម-និយមវៀតណាម ថៃឡង់ដ៏ រដ្ឋាភិបាលហូឡង់ ជប៉ុន កាណាដា ឥណ្ឌូណេស៊ី សាធារណរដ្ឋកូរ៉េ វេទិកាសភាតំបន់អាស៊ីប៉ាស៊ីហ្វិក (AAPP) ។ល។

ឆ. ការជួសជុល និងការសាងសង់

ការងារជួសជុល និងការសាងសង់នៅព្រឹទ្ធសភាមានលក្ខណៈធំធេង ដោយត្រូវបានកែប្រែហេដ្ឋារចនាសម្ព័ន្ធចាស់មកជាសភាពថ្មីនិងទំនើប។ ការងារជួសជុលអគារនេះ បានមកពីជំនួយឧបត្ថម្ភរបស់ប្រទេសជាមិត្ត។ អគារសាលប្រជុំ និងអគារចាស់ៗជាច្រើន សុទ្ធតែត្រូវបានជួសជុល និងកែលំអសំរាប់ធ្វើជាកន្លែងប្រជុំ និងជាការិយាល័យដែលបំពាក់ដោយសម្ភារៈ ឧបករណ៍ប្រើប្រាស់សមរម្យគ្រប់គ្រាន់។ អគារ ៤ ដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន ជាសមិទ្ធផលយ៉ាងថ្មីស្រឡាង មានទ្រង់ទ្រាយធំដែលជួយសមាជិកព្រឹទ្ធសភាម្នាក់ៗ ឱ្យមានការិយាល័យមួយយ៉ាងសមរម្យ និងជួយព្រឹទ្ធសភាឱ្យមានបណ្ណាល័យមួយយ៉ាងទំនើប។ ផ្លូវថ្នល់ ប្រព័ន្ធលូបង្ហូរទឹក សួនច្បារ និងទីធ្លាទាំងឡាយ ក៏បានស្ថាបនា និងជួសជុលឡើងវិញទាំងស្រុង។

ជ. ការដាក់តែងគោលនយោបាយគ្រប់គ្រងធនធានមនុស្ស

បន្ទាប់ពីច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ បានចូលជាធរមាន បទប្បញ្ញត្តិជាបន្ទាន់មួយចំនួនត្រូវបានរៀបចំឡើង ដើម្បីបំពេញសេចក្តីត្រូវការចំពោះមុខក្នុងការងារគ្រប់គ្រង។ ជាបន្តបន្ទាប់ គោលនយោបាយជាច្រើនបាននឹងកំពុងរៀបចំឡើង ជាអាទិ៍ គោលនយោបាយជ្រើសរើសអ្នករាជការឱ្យចូលធ្វើការ គោលនយោបាយជ្រើសរើស បុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត គោលនយោបាយស្តីពីការពិពណ៌នាការងារ គោលនយោបាយបណ្តុះបណ្តាលធនធានមនុស្ស និងអភិវឌ្ឍន៍ធនធានមនុស្ស គោលនយោបាយជំរុញ និងលើកទឹកចិត្ត គោលនយោបាយចំពោះស្ត្រី គោលការណ៍អំពីការតែងតាំងអ្នករាជការឱ្យកាន់មុខតំណែង

គ្រប់គ្រង គោលនយោបាយសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ។ ក្រៅពីនេះ នៅមានបទបញ្ជាផ្ទៃក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លិខិតបទដ្ឋានគតិយុត្ត កំណត់អំពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រីរាជការ និងគ្រឿងឥស្សរិយយស ។

គោលនយោបាយទាំងអស់ សុទ្ធតែត្រូវដាក់ឆ្លងយោបល់របស់មន្ត្រីរាជការ ដើម្បីកែលំអនិងដាក់ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យ និងសំរេច ។ នាសម័យប្រជុំថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានអនុម័តជាគោលការណ៍ដាក់ឱ្យអនុវត្តចាប់ពីខែ មករា ឆ្នាំ ២០០៦ តទៅ ។

១៣.៤ របបគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានប្រកាន់យករបបគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ បើកចំហ មានតម្លាភាព និងមានការចូលរួម ។ ការងារទាំងឡាយ ជាអាទិ៍ការពិនិត្យបញ្ហាសំខាន់ៗ ការរៀបចំសេចក្តីព្រាងលិខិតបទដ្ឋាន ឬគោលនយោបាយផ្សេងៗ សំរាប់ការគ្រប់គ្រងភាគច្រើនសុទ្ធតែត្រូវបានប្រគល់ជូនគណៈកម្មការ ដែលមានសមាសភាពចម្រុះមកពីអង្គភាពជាច្រើន ហើយសុទ្ធសឹងជាមន្ត្រីដែលមានបទពិសោធន៍ក្នុងមុខងារដែលគណៈកម្មការត្រូវធ្វើ ។ ជាក់ស្តែង ក្នុងនីតិកាលទី ១ នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបង្កើតគណៈកម្មការ ជាបន្តបន្ទាប់ឱ្យទទួលភារកិច្ចផ្សេងៗពីគ្នា ដូចមានរៀបរាប់តាមលំដាប់ថ្ងៃ ខែ ឆ្នាំ ដូចខាងក្រោមនេះ :

គណៈកម្មការដែលអគ្គលេខាធិការដ្ឋានបានបង្កើត

លេខរៀង	ឈ្មោះគណៈកម្មការ	សេចក្តីសំរេចលេខ	ចុះថ្ងៃ ខែ ឆ្នាំ
១	គ.ក វាយតម្លៃ	០៧៥ /១០/៩៩ អ.ព.ស/រប	០១/ ១០/១៩៩៩
២	គ.ក ត្រួតពិនិត្យខ្លឹមសារឧបសម្ព័ន្ធរបស់សេចក្តីសំរេចស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងនៃអ.ព.ស	០៧៦/១០/៩៩ អ.ព.ស/រ.ប	០១/ ១០/១៩៩៩
៣	គ.ក រៀបចំតាក់តែងពិនិត្យអត្ថន័យខ្លឹមសារប្រទីបព្រឹទ្ធសភា	០៩២/១១/៩៩ អ.ព.ស/រប	១០/ ១១/ ១៩៩៩
៤	គ.ក រៀបចំពិធីបុណ្យឆ្លងសហស្សវត្ស	០៩៦/១១/៩៩ អ.ព.ស/រប	១២ /១១ /១៩៩៩
៥	សេចក្តីសំរេចប្រគល់សិទ្ធិជូនគ.ករៀបចំបុណ្យឆ្លងសហស្សវត្ស	១០៤/១២/៩៩ អ.ព.ស/រប	០១ /១២/ ១៩៩៩
៦	ក្រុមការងារទទួលរៀបចំ គណៈប្រតិភូបរទេស	០០៩/០១/០០ អ.ព.ស/រប	១០/០១ /២០០០
៧	គ.ក រៀបចំវគ្គបំប៉នមន្ត្រីរាជការ	០៣០/០១/០០ អ.ព.ស/រប	២៧ /០១ /២០០០
៨	គ.ក ពិនិត្យលទ្ធភាពបញ្ចូលបុគ្គលិកអណ្តែតក្នុងក្របខ័ណ្ឌពេញសិទ្ធិ	១៤៧/០៥/០០ អ.ព.ស/រប	២៤ /០៥/ ២០០០
៩	គ.ក សារពើភ័ណ្ឌ	៨៣២/១២/០០ អ.ព.ស/រប	២០/១២ /២០០០
១០	គ.ក វាយតម្លៃធ្វើតេស្តបេក្ខជន	០១៨/០១/០១ អ.ព.ស/រប	១៦/០១ / ២០០១
១១	គ.ក ព្រាងច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ	០៦៥/០២/០១ អ.ព.ស/រប	២៧/០២/ ២០០១

១២	គ.ក តម្លើងកាំប្រាក់មន្ត្រីរាជការឆ្នាំ ២០០១	១៣៧/០៥/០១ អ.ព.ស/រប	២៤/ ០៥ /២០០១
១៣	គ.គ គ្រប់គ្រងវគ្គបណ្តុះបណ្តាលជំនាញកុំព្យូទ័រ	២៤៤/០៩/០១ អ.ព.ស/រប	១៣ /០៩ /២០០១
១៤	គ.ក ជ្រើសរើសមន្ត្រីរាជការទៅរៀននៅសាលាភូមិន្ទរដ្ឋបាល	៣២៥/១១/០១ អ.ព.ស/រប	២៥/ ១១ /២០០១
១៥	គ.ក រៀបចំផែនការយុទ្ធសាស្ត្រព្រឹទ្ធសភា	៣២៧/១១/០១ អ.ព.ស/រប	២៩ /១១ /២០០១
១៦	គ.ក ជ្រើសរើសមន្ត្រីទៅរៀននៅទូវែលហ្សេឡង់	០៣០/០១/០២ អ.ព.ស/រប	៣០ /០១ /២០០២
១៧	គ.ក កែសំរួលបទបញ្ជាផ្ទៃក្នុង អ.ព.ស	០៣៧/០២/០២ អ.ព.ស/រប	០៥/ ០២ /២០០២
១៨	គ.ក នារី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា	០៦៥/០៣/០២ អ.ព.ស/រប	០១ /០៣ /២០០២
១៩	គ.ក វាយតម្លៃមន្ត្រីរាជការដែលត្រូវឡើងកាំប្រាក់	០៨០/០៣/០២ អ.ព.ស/រប	២២ /០៣ /២០០២
២០	គ.ក វាយតម្លៃតាំងស៊ប់ក្នុងក្របខ័ណ្ឌពេញសិទ្ធិមន្ត្រីរាជការ អ.ព.ស	១៣០/០៥/០២ អ.ព.ស/រប	០៦/ ០៥ /២០០២
២១	គ.ក រៀបចំគំរោងប្រាក់បំណាច់មុខងារមន្ត្រីរាជការ	១៩៦/០៦/០២ អ.ព.ស/រប	១៤ /០៦ /២០០២
២២	គ.ក បណ្តុះបណ្តាលធនធានមនុស្ស	៣០២/០៧/០២ អ.ព.ស/រប	១៤/០៨/២០០២
២៣	គ.ក សំរាប់ផ្ទេរអ្នករាជការក្របខ័ណ្ឌសព្វថ្ងៃក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ	១៨២/០៥/០៣ អ.ព.ស/រប	០៩ /០៥ /២០០៣
២៤	គ.ក រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់អ.ព.ស	២៩៦/០៩/០៣ អ.ព.ស/រប	០៤/ ០៩ /២០០៣
២៥	គ.ក ធនធានមនុស្សរបស់ អ.ព.ស	៣៩១/១១/០៣ អ.ព.ស/រប	២១ /១១ /២០០៣
២៦	គ.ក ស្រាវជ្រាវបញ្ហាផ្ទៃក្នុង	០៧៦/០៣/០៤ អ.ព.ស/រប	០៥ /០៣ /២០០៤
២៧	គ.ក រៀបចំសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ	៤៣៧/១១/០៤ អ.ពស/រប	១៨ /១១ /២០០៤
២៨	គ.ក ពិនិត្យបញ្ហាតម្លើងកាំប្រាក់	០៣៩/០២/០៥ អ.ព.ស/រប	០២ /០២ /២០០៥
២៩	គ.ក បូកសរុប និងតាក់តែងឯកសារស្នាដៃ ព្រឹទ្ធសភានីតិកាលទី ១	០៤០/០២/០៥ អ.ព.ស/រប	០២ /០២ /២០០៥
៣០	គ.ក រៀបចំសេចក្តីព្រាងគោលការណ៍អំពីការសរសើរ ជូនរង្វាន់ គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ	០៤២/០២/០៥ អ.ព.ស/រប	០២ /០២ /២០០៥

ស្ថិតិគណៈកម្មការដែលបានបង្កើតឡើង

ឆ្នាំ	១៩៩៩	២០០០	២០០១	២០០២	២០០៣	២០០៤	២០០៥
ចំនួន	០៥	០៤	០៦	០៧	០៣	០២	០៣

១៣.៥ ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

សេចក្តីស្នើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ មាន ១២ជំពូក ចែកចេញជា ៧៤មាត្រា ។ សេចក្តីស្នើច្បាប់នេះ រៀបរៀងដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ហើយបានទទួលការគាំទ្រពីសមាជិករដ្ឋសភាចំនួន ២៣រូប ។

សេចក្តីស្នើច្បាប់នេះ ត្រូវបានរដ្ឋសភានីតិកាលទី២ អនុម័តនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៣ នាសម័យប្រជុំលើកទី ៩ ហើយត្រូវបានព្រឹទ្ធសភា នីតិកាលទី ១ អនុម័តយល់ព្រមនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ នាសម័យប្រជុំលើកទី ៨ រួចត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ។

ច្បាប់នេះកំណត់ក្របខ័ណ្ឌមន្ត្រីជា ៤ ហើយក្របខ័ណ្ឌនីមួយៗមាន ៣ឋានន្តរសក្តិ ឋានន្តរសក្តិទី ១ មាន ៦ថ្នាក់ ឋានន្តរសក្តិទី ២ មាន ១០ថ្នាក់ និងឋានន្តរសក្តិទី ៣ មាន ១៤ថ្នាក់ ។ បទប្បញ្ញត្តិភាគច្រើនមានលំនាំប្រហាក់ប្រហែលនឹងច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ បានដាក់ឱ្យអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលក្នុងដំណាក់កាលថ្មីដែលមានការប្រែប្រួលច្រើន ទាំងទស្សនៈ និងសកម្មភាពរបស់មន្ត្រីរាជការ ព្រមទាំងការងារគ្រប់គ្រង ។

១៤. សកម្មភាពដោយរូបភាព

ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ធ្វើទស្សនកិច្ចនៅបរទេស

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយឯកឧត្តម Deniel Hays ប្រធានព្រឹទ្ធសភាកាណាដា

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយអគ្គលេខាធិការព្រឹទ្ធសភាកាណាដា

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយប្រធានរដ្ឋសភាគុយបា

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការព្រឹទ្ធសភា អញ្ជើញធ្វើទស្សនកិច្ចសិក្សានៅប្រទេសបារាំង

ឯកឧត្តម ញ៉ិក ឆៃអេង អគ្គលេខាធិការរងព្រឹទ្ធសភា អញ្ជើញចូលរួមក្នុង នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

អគ្គលេខាធិការព្រឹទ្ធសភា ចុះហត្ថលេខាជាមួយតំណាងអង្គការអន្តរជាតិ

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ ចុះហត្ថលេខាជាមួយតំណាងស្ថានទូត
នៃសាធារណរដ្ឋប្រជាមានិតចិន

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ ចុះហត្ថលេខាជាមួយតំណាងស្ថានទូត
នៃសាធារណរដ្ឋប្រជាមានិតចិន

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ ចុះហត្ថលេខាជាមួយតំណាងស្ថានទូត
នៃសាធារណរដ្ឋប្រជាមានិតចិន

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ ចុះហត្ថលេខាទទួលអគារបណ្ណាល័យ
និងអគារបឺខ្លង ពីសាធារណរដ្ឋប្រជាមានិតចិន

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ ចុះហត្ថលេខាជាមួយតំណាង
មូលនិធិខុនរ៉ាដអាដឺនណៅអ៊ែរ សំរាប់ឆ្នាំ ២០០១

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ ចុះហត្ថលេខាជាមួយតំណាង
មូលនិធិខុនរ៉ាដអាដឺនណៅអ៊ែរ សំរាប់ឆ្នាំ ២០០៥

អគ្គលេខាធិការព្រឹទ្ធសភា ជួបពិភាក្សាជាមួយ
អគ្គទូត និងតំណាងអង្គការនានា

ឯកឧត្តម អ៊ុំ សារិទ្ធ និងលោកជំទាវឯកអគ្គរដ្ឋទូតប្រទេសអូស្ត្រាលី

ឯកឧត្តម អ៊ុំ សារិទ្ធ និងតំណាងស្ថានទូតប្រទេសឥណ្ឌូនេស៊ី

ឯកឧត្តម អ៊ុំ សារិទ្ធ ជួបជាមួយលោកជំទាវឯកអគ្គរដ្ឋទូតនៃប្រទេសគុយបា

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ ជួបជាមួយឯកឧត្តម
អគ្គលេខាធិការព្រឹទ្ធសភាកាណាដា

ឯកឧត្តម អ៊ុំ សារិទ្ធ ជួបជាមួយតំណាងមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ

ឯកឧត្តម អ៊ុំ សារិទ្ធ ជួបជាមួយអ្នកជំនាញជាន់ខ្ពស់ខាងការអភិវឌ្ឍន៍សភា

ឯកឧត្តម អ៊ឹ សារីទ្ធ ជួបជាមួយតំណាងធនាគារពិភពលោក

ឯកឧត្តម អ៊ឹ សារីទ្ធ ជួបជាមួយមន្ត្រីតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

ឯកឧត្តម អ៊ឹ សារីទ្ធ ជួបជាមួយតំណាងអង្គការស៊ីដា

ឯកឧត្តម អ៊ឹ សារីទ្ធ ជួបជាមួយគណៈប្រតិភូវិទ្យាស្ថានជាតិ
ដើម្បីលទ្ធិប្រជាធិបតេយ្យ (NDI)

ឯកឧត្តម អ៊ឹ សារីទ្ធ ជួបជាមួយអ្នកជំនាញផ្នែកបណ្ណសារនៃសភាអូស្ត្រាលី

ឯកឧត្តម អ៊ឹ សារីទ្ធ ជួបជាមួយប្រធាននាយកដ្ឋាន
ទំនាក់ទំនងអន្តរជាតិរបស់ព្រឹទ្ធសភាប្រទេសបារាំង

ថ្នាក់ដឹកនាំអង្គភាព ធ្វើទស្សនកិច្ចសិក្សានៅបរទេស

ថ្នាក់ដឹកនាំអង្គភាព នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅទស្សនកិច្ចសិក្សា
នៅប្រទេសកាណាដា

ឯកឧត្តម មាន សុខុម អគ្គាធិការព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចសិក្សា
នៅប្រទេសបារាំង

លោក គីម លី ប្រធាននាយកដ្ឋាននីតិវិធី អញ្ជើញទៅទស្សនកិច្ចសិក្សា
នៅសភាប្រទេសថៃ

លោក ទើក សានគុ ប្រធានបណ្ណាល័យ អញ្ជើញចូលរួមក្នុងអង្គសិក្ខាសាលា
នៅប្រទេសវៀតណាម

ថ្នាក់ដឹកនាំអង្គភាព នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅធ្វើទស្សនកិច្ចសិក្សា
នៅប្រទេសអូស្ត្រាលី

លោក យ៉ាន់ វ៉ាន់ឌីលុច ជំនួយការអគ្គលេខាធិការព្រឹទ្ធសភា
អញ្ជើញចូលរួមប្រជុំនៅព្រឹទ្ធសភាកាណាដា

វគ្គបណ្តុះបណ្តាលដែលរៀបចំឡើយដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ឯកឧត្តម អ៊ុំ សារិទ្ធ បើកសិក្ខាសាលា
ស្តីពីគោលការណ៍គ្រប់គ្រង និងអភិបាលកិច្ចល្អ

ឯកឧត្តម អ៊ុំ សារិទ្ធ បើកសិក្ខាសាលា
ស្តីពីការពង្រឹងសមត្ថភាពផ្នែកច្បាប់របស់សភា

ឯកឧត្តម អ៊ុំ សារិទ្ធ បើកសិក្ខាសាលា
ស្តីពីសភាប្រជាធិបតេយ្យ

ឯកឧត្តម អ៊ុំ សារិទ្ធ បើកវគ្គបណ្តុះបណ្តាល
ស្តីពីវិធីសាស្ត្រនៃការបញ្ញត្តិច្បាប់

ឯកឧត្តម អ៊ុំ សារិទ្ធ បើកវគ្គបណ្តុះបណ្តាល
ស្តីពីវិធីសាស្ត្រនៃការព្រាង និងតាក់តែងច្បាប់

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ បានអញ្ជើញជាអធិបតីក្នុងពិធី
បើកវគ្គសិក្ខាសាលា ស្តីពីការអភិវឌ្ឍន៍បណ្ណាល័យ និងបណ្ណសារសភា

ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការ អញ្ជើញប្រគល់វិញ្ញាបនប័ត្រ
នៃវគ្គបណ្តុះបណ្តាល ស្តីពីពិធីការ និងទំនាក់ទំនងអន្តរជាតិ

ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការ អញ្ជើញប្រគល់វិញ្ញាបនប័ត្រ
នៃវគ្គបណ្តុះបណ្តាល ស្តីពីសវនកម្ម

ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការ អញ្ជើញប្រគល់វិញ្ញាបនប័ត្រ
នៃវគ្គបណ្តុះបណ្តាល ស្តីពីជំនាញប្រាស្រ័យឆ្លើយឆ្លង

ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការ អញ្ជើញប្រគល់វិញ្ញាបនប័ត្រ
នៃវគ្គបណ្តុះបណ្តាល ស្តីពីជំនាញសរសេរព័ត៌មាន និងកាត់តរូបភាព

ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការ អញ្ជើញប្រគល់វិញ្ញាបនប័ត្រ
នៃវគ្គបណ្តុះបណ្តាល ស្តីពីការងារជំនួយការគណៈកម្មការ

ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការ អញ្ជើញប្រគល់វិញ្ញាបនប័ត្រ
នៃវគ្គបណ្តុះបណ្តាល ស្តីពីទ្រឹស្តីនៃការព្រាង និងតាក់តែងច្បាប់

ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ អញ្ជើញប្រគល់វិញ្ញាបនប័ត្រ
នៃវគ្គបណ្តុះបណ្តាល ស្តីពីអធិការកិច្ច

ឯកឧត្តម ញ៉ឹក ឆៃអេង អគ្គលេខាធិការរង អញ្ជើញជាអធិបតីក្នុង
ពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីសិក្សាស្រាវជ្រាវទូទៅ

ឯកឧត្តម ញ៉ឹក ឆៃអេង អគ្គលេខាធិការរង បានអញ្ជើញជាអធិបតីក្នុងពិធីបើក
វគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រនៃការព្រាង និងតាក់តែងច្បាប់

ឯកឧត្តម ញ៉ឹក ឆៃអេង អគ្គលេខាធិការរង អញ្ជើញជាអធិបតីក្នុងពិធីបើក
វគ្គបណ្តុះបណ្តាល ស្តីពីអធិការកិច្ច

ឯកឧត្តម ញ៉ឹក ឆៃអេង អគ្គលេខាធិការរង អញ្ជើញប្រគល់វិញ្ញាបនប័ត្រ
នៃវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រនៃការព្រាង និងតាក់តែងច្បាប់

ឯកឧត្តម ញ៉ឹក ឆៃអេង អគ្គលេខាធិការរង អញ្ជើញជាអធិបតីក្នុងពិធីបើក
វគ្គបណ្តុះបណ្តាល ស្តីពីលេខាធិការ និងសរសេររបាយការណ៍

ប្លង់មេ វិមានរដ្ឋចំការមន

ព្រឹទ្ធសភា
SENATE

១៥. ព្រឹទ្ធសភាពេលបច្ចុប្បន្ន

អគារព្រូហាម

ខ្លោងទ្វារថ្មីខាងមុខ

ខ្លោងទ្វារថ្មីខាងក្រោយ

ទិដ្ឋភាពសាលប្រជុំពេញអង្គពីខាងក្រោយ

សាលប្រជុំពេញអង្គព្រឹទ្ធសភាពីខាងមុខ

សាលប្រជុំពេញអង្គខាងក្នុង

សាលសិក្ខាសាលាខាងជើង

សាលសិក្ខាសាលាជាន់បណ្ណាល័យ

សាលប្រជុំពិសេស

បន្ទប់ទទួលភ្ញៀវប្រធានរដ្ឋសភា

អាគារ A របស់សមាជិក សមាជិកាព្រឹទ្ធសភា

អាគារ B របស់សមាជិក សមាជិកាព្រឹទ្ធសភា

អាគារ C របស់សមាជិក សមាជិកាព្រឹទ្ធសភា

អគារការិយាល័យអគ្គលេខាធិការ

អគារការិយាល័យអគ្គលេខាធិការរង [illegible]

អគារជំនួយការរបស់អគ្គលេខាធិការ

អគារការិយាល័យផ្នែកទំនាក់ទំនងអន្តរជាតិ

កន្លែងចតរថយន្តមុខនាយកដ្ឋានព័ត៌មានក្រោយសាងសង់

អគារនាយកដ្ឋានរដ្ឋបាល ក្រោយកែជួសជុល

ការិយាល័យនាយកកិច្ចការសម្តេចប្រធានព្រឹទ្ធសភា

បណ្ណាល័យព្រឹទ្ធសភា

សាលបង្រៀនកុំព្យូទ័រ

អគារ...

១៦. ព្រឹទ្ធសភាពីអតីតកាល

អគារក្រហម

ផ្លូវចុំស្តីយានខាងក្រោយ

ទីធ្លាសាងសង់អគារ A

ទីធ្លាសាងសង់អគារ C

ទីធ្លាសាងសង់បណ្ណាល័យ

អគារអគ្គលេខាធិការចាស់

អគារចាស់ បច្ចុប្បន្នជាខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

អគារចាស់ក្រោយខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

អគារទីប្រឹក្សាសម្តេចប្រធាន

ឃ្លាំងសម្ភារៈរបស់ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

អតីតអគារដំណាក់ព្រះករុណាព្រះបាទ នរោត្តម សីហនុ
បច្ចុប្បន្នជាអគ្គលេខាធិការ

ពេលទឹកជំនន់ក្រោយខុទ្ទកាល័យសម្តេចប្រធាន

នាយកដ្ឋានហិរញ្ញវត្ថុចាស់

អគាររោងម៉ាស៊ីនភ្លើងចាស់

អគារបែកបាក់ បច្ចុប្បន្នជានាយកដ្ឋាននីតិវិធី

អតីតរោង[illegible] [illegible] A

អគារចាស់ បច្ចុប្បន្នជាអគារកងសន្តិសុខ

បណ្ណាល័យចាស់

ឧបសម្ព័ន្ធ

បទបញ្ជាផ្ទៃក្នុង

ព្រឹទ្ធសភា

នៃ

ព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

***** *********

សំណុំរឿង

លេខ ០៥ ចុះថ្ងៃទី ១២ មេសា ឆ្នាំ ១៩៩៩

សេចក្ដីសំរេច

លេខ ០៤ កបធ.សសរ.ច

ចុះថ្ងៃទី ៣០ មេសា ឆ្នាំ ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសំណើលេខ ០០៣/៤៩៩/ពសរប ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៩៩ របស់សម្ដេចប្រធានព្រឹទ្ធសភា សុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលទទួលបាននៅអគ្គលេខធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩

- ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា មាត្រា១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់កថាខណ្ឌទី២ ឃ្លាទី១ ចែងថា "បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សា ធម្មនុញ្ញពិនិត្យមុននឹងប្រកាសអោយប្រើ។ "ការសុំអោយពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុង ដោយប្រធានព្រឹទ្ធសភា ជាការស្របតាមរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ការសំរេចអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដោយផ្អែកតាមមាត្រា១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី២ ឃ្លាទី២ ដែលចែងថា : "ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ។"

- យល់ឃើញថា ឃ្លាដើមនៃប្រការ៩ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាចែងថា : "ក្រោយពីព្រះមហាក្សត្រ និងសម្តេចព្រះរាជអគ្គមហេសី ...." មានលក្ខណៈខុសនឹងប្រការ២ ឃ្លាទី២ ដែលចែងថា : "ព្រះមហាក្សត្រ សម្តេចព្រះរាជអគ្គមហេសី..............." គឺឃ្លាក្រោយនេះពុំមានពាក្យ "និង" ទេ ។
- យល់ឃើញថា ប្រការ៤៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ស្តីពីការជ្រើសតាំងប្រធានបណ្តោះអាសន្នមួយរូប អោយដឹកនាំការប្រជុំបន្ត ពុំមានចែងក្នុងរដ្ឋធម្មនុញ្ញទេ និងជាប្រការមួយពិបាកនឹងអនុវត្តក្នុងការជាក់ស្តែង ។

សំរេច

មាត្រា១- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាមាន១៦ជំពូក និង៨០មាត្រា ដែលព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៩៩ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ៤៨ ដែលមិនស្របនឹង មាត្រា១១០ថ្មី នៃរដ្ឋធម្មនុញ្ញ ។

មាត្រា២- សេចក្តីសំរេចនេះធ្វើនៅភ្នំពេញ ថ្ងៃទី៣០ ខែមេសា នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពទៅលើអំណាចទាំងអស់ដែលមានចែងក្នុង រដ្ឋធម្មនុញ្ញ ។

រាជធានីភ្នំពេញ , ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និងត្រា : ចាន់ សុក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

លេខ ០០៥/៩៩៩/ពស/សរ

សេចក្តីសំរេច

ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១-៣-៩៩ អំពីការតែងតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២នៃព្រឹទ្ធសភា សំរាប់នីតិកាលទី១
- បានឃើញសេចក្តីសំរេចលេខ០០៤ កបធ.សសរ.ធ ចុះថ្ងៃទី៣០ មេសា ១៩៩៩ របស់ក្រុមប្រឹក្សាធម្មនុញ្ញ អំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា

សំរេច

ប្រការ ១ - ប្រកាសអោយប្រើបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ដែលត្រូវបានអនុម័តកាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩ នាសម័យប្រជុំព្រឹទ្ធសភាលើកទី១ នីតិកាលទី១ លើកលែងតែប្រកា៤៨ ដែលមិនស្របនឹងមាត្រា១១០ ថ្មីនៃរដ្ឋធម្មនុញ្ញ។

ប្រការ ២ - សេចក្តីសំរេចនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩៩

ហត្ថលេខា និងត្រា : ជា ស៊ីម

ជំពូកទី ១

អំពីការិយាល័យបណ្ដោះអាសន្ន និងភារកិច្ច

ប្រការ ១ :

ព្រឹទ្ធសភាប្រជុំសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗមានថិរវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ ។

ប្រការ ២ :

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូងរយៈពេល៦០ថ្ងៃ យ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះអញ្ជើញរបស់ព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ សម្តេចព្រះរាជអគ្គមហេសី ឬព្រះរាជតំណាងប្រទាន ឬផ្តល់កិត្តិយសចំពោះការបើកសម័យប្រជុំ ដំបូងនៃនីតិកាលនីមួយៗ ។ នៅពេលបើកសម័យប្រជុំលើកទី១ នៃនីតិកាលមួយៗ ព្រឹទ្ធសភាត្រូវចាប់ដំណើរការក្រោមអធិបតីភាព នៃប្រធានបណ្ដោះអាសន្នមួយរូប ដែលជាបេក្ខជនជាប់ឆ្នោតមានអាយុច្រើនជាងគេ ហើយដែលឥតមានបណ្ដឹងតវ៉ា ព្រមទាំងសមាជិក៥រូប ដែលជាបេក្ខជនជាប់ឆ្នោតមានអាយុតិចជាងគេ និងឥតមានបណ្ដឹងតវ៉ាជាលេខាធិការ ដើម្បីជួយការងារប្រធាន ។

ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិកខាងលើ ព្រឹទ្ធសភាត្រូវចាប់ផ្តើមការងារដូចតទៅ :

ក-ប្រកាសឈ្មោះសមាជិកព្រឹទ្ធសភាពេញសិទ្ធិ

ខ-ជ្រើសតាំងប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ។

ក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិក ព្រឹទ្ធសភាមិនអាចជជែកពិភាក្សាគ្មានអ្វីឡើយ ។

ជំពូកទី ២

អំពីសុពលភាពនៃសមាជិកព្រឹទ្ធសភា

ប្រការ ៣ :

នៅពេលបើកសម័យប្រជុំខាងលើនេះ ដើម្បីសំរេចអំពីសុពលភាព ព្រឹទ្ធសមាជិកប្រកាសជូនអង្គសភា :

-ឈ្មោះបេក្ខជនជាប់ឆ្នោតជាស្ថាពរ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជូនមក

-ឈ្មោះបេក្ខជនជាប់ឆ្នោតដែលមានបណ្ដឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធបណ្ដឹងទាំងនោះ ។

សុពលភាពឈ្មោះសមាជិកព្រឹទ្ធសភាពេញសិទ្ធិទាំងនោះត្រូវបិទផ្សាយភ្លាមក្នុងព្រឹទ្ធសភា និងផ្សព្វផ្សាយជាសាធារណៈក្រោយពេលប្រជុំ។

ប្រការ ៤ :

សមាជិកព្រឹទ្ធសភាមានឋានៈនិងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា ។

ជំពូកទី ៣
អំពីប្រធាន អនុប្រធាន គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានានៃព្រឹទ្ធសភា

ប្រការ ៥ :

ក្រោយពីព្រះមហាក្សត្រ និងសម្តេចព្រះរាជអគ្គមហេសី ឬព្រះរាជតំណាង បានបើកនីតិកាលព្រឹទ្ធសភារួចហើយ បើព្រឹទ្ធសភាមានសមាជិកវត្តមានប្រាំពីរភាគដប់យ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ព្រឹទ្ធសភាអាចដំណើរការបោះឆ្នោតជ្រើសរើសដាច់ដោយឡែក ពីគ្នានូវប្រធាន និងអនុប្រធានទាំងពីររបស់ខ្លួន ដោយមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ប្រការ ៦ :

ក្រោមអធិបតីភាពនៃប្រធានរបស់ខ្លួន ព្រឹទ្ធសភាចាប់ដំណើរការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

គណៈកម្មការនានានៃព្រឹទ្ធសភាមាន :

១-គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង

២-គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ

៣-គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន

៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត

៥-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

៦-គណៈកម្មការនីតិកម្ម

៧-គណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍

៨-គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី

៩-គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ។

ប្រការ ៧ :

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមាន :

-ប្រធានព្រឹទ្ធសភា

-អនុប្រធានទាំងពីរនៃព្រឹទ្ធសភា

-ប្រធានគណៈកម្មការនានានៃព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភាជាប្រធាននៃគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមានអាណត្តិស្មើនឹងនីតិកាលរបស់ព្រឹទ្ធសភា ។

ប្រការ ៨ :

ប្រធានព្រឹទ្ធសភាមានភារកិច្ចដូចតទៅ :

ក-ធានាការប្រព្រឹត្តទៅនៃព្រឹទ្ធសភាអោយបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ

ខ-ដឹកនាំអង្គប្រជុំនៃព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍

គ-បើក ឬលើកពេលប្រជុំព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍

ឃ-ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា

ង-ញ៉ាំងអោយប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

ច-រក្សាការពារសណ្តាប់ធ្នាប់ក្នុងព្រឹទ្ធសភា

ឆ-តំណាងព្រឹទ្ធសភាក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ រដ្ឋសភាឬអាជ្ញាធរសាធារណៈ

ជ-ទាក់ទងជាមួយប្រធានរដ្ឋសភាដើម្បីរៀបចំសមាជអង្គសភាទាំងមូល ។

ប្រការ ៩ :

អនុប្រធានទាំងពីរជួយធ្វើការប្រធាន ។ កាលបើប្រធានអវត្តមាន ឬមកធ្វើការពុំបានអនុប្រធានធ្វើការជំនួសប្រធាន ។

ប្រការ ១០ :

គណៈកម្មការនីមួយ ៗ ត្រូវជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូបដោយវិធីបោះឆ្នោត ។

គណៈកម្មការនីមួយៗមានសមាជិកយ៉ាងតិច ៥ រូប ។

កូរ៉ុមសំរាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការនានាត្រូវមានលើសពីពាក់កណ្តាលនៃចំនួន សមាជិកទាំងមូល ។

រាល់ការសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានា ត្រូវអនុម័តដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកទាំងមូល ។

ប្រការ ១១ :

ក្នុងករណីចាំបាច់ ព្រឹទ្ធសភាអាចអនុម័តដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ក្នុងការសំរេចបង្កើតគណៈកម្មការពិសេសដែលមានសមាជិកច្រើនឬតិចតាមតម្រូវការ ។

ប្រការ ១២ :

គណៈកម្មការនីមួយៗអាចស្នើសុំប្រធានព្រឹទ្ធសភាចាត់តាំងអ្នកជំនាញ ដែលមិនមែនជាសមាជិកព្រឹទ្ធសភាអោយចូលរួមធ្វើការបាន ។ អ្នកជំនាញនោះគ្មានសិទ្ធិសំរេចកិច្ចការរបស់គណៈកម្មការទេ ។

គណៈកម្មការនីមួយៗត្រូវកំណត់តួនាទី សមត្ថកិច្ច និងភារកិច្ចរបស់ខ្លួនអោយស្របទៅនឹងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងច្បាប់ជាធរមានរបស់រដ្ឋ រួចដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសំរេច ។

ប្រការ ១៣ :

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមានភារកិច្ចដូចតទៅ :

-ចាត់ចែងការងាររបស់ព្រឹទ្ធសភាក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា

-រៀបចំរបៀបវារៈនៅពេលប្រជុំព្រឹទ្ធសភានីមួយៗ

-ធានាការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន

-លើកជូនព្រឹទ្ធសភាពិនិត្យនិងសំរេចលើការចោទប្រកាន់ ការចាប់ខ្លួន ការឃុំខ្លួន ការឃាត់ខ្លួន ដែលពាក់ព័ន្ធដល់ការប្រាសចាកសមាជិកភាពរបស់សមាជិកព្រឹទ្ធសភា ឬបញ្ហាលើកអភ័យឯកសិទ្ធិរបស់សមាជិកព្រឹទ្ធសភាណាមួយ ។

ក្នុងករណីដែលមានប្រធានគណៈកម្មការណាមួយអវត្តមាន អនុប្រធាន ឬលេខាធិការគណៈកម្មការនោះ មានសិទ្ធិចូលរួមប្រជុំក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ជំនួស ប៉ុន្តែពុំមានសិទ្ធិសំរេចការងារផ្សេងៗក្នុងនាមប្រធានបានឡើយ ។

ប្រការ ១៤ :

សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់ព្រឹទ្ធសភាដែលខានមកប្រជុំដោយឥតជូនដំណឹងត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងប្រការ៦៧និង៦៨ ។

ជំពូកទី ៤
រចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាន

ប្រការ ១៥ :

ព្រឹទ្ធសភាមានអគ្គលេខាធិការដ្ឋានមួយសំរាប់ទទួលបន្ទុកធ្វើកំណត់ហេតុរបស់ព្រឹទ្ធសភា របស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងរបស់គណៈកម្មការនានា ។ លើសពីនេះអគ្គលេខាធិការដ្ឋានទទួលរ៉ាប់រងរាល់កិច្ចការរដ្ឋបាលរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅព្រឹទ្ធសភា ។

ប្រការ ១៦ :

អគ្គលេខាធិការដ្ឋានត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយរូបជាជំនួយការ ។

អគ្គលេខាធិការនិងអគ្គលេខាធិការរងត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីជាន់ខ្ពស់ដែលមានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិច ១០ ឆ្នាំ ហើយដែលមិនមែនជាសមាជិកព្រឹទ្ធសភា និងមិនមែនជាអ្នកដឹកនាំគណបក្សនយោបាយ ។

ប្រការ ១៧ :

អគ្គលេខាធិការនិងអគ្គលេខាធិការរងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសេចក្តីស្នើរបស់ប្រធានព្រឹទ្ធសភា ក្រោយពីបានឯកភាពជាមួយអនុប្រធានទី១ និងអនុប្រធានទី២ ។

អគ្គលេខាធិការនិងអគ្គលេខាធិការរង មានឋានៈស្មើនឹងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ។

ប្រការ ១៨ :

បុគ្គលិកនៃអគ្គលេខាធិការដ្ឋានទាំងអស់ ត្រូវតែងតាំងដោយប្រធានព្រឹទ្ធសភាតាមសេចក្តីស្នើរបស់អគ្គលេខាធិការ ។

ប្រការ ១៩ :

អគ្គលេខាធិការដ្ឋានត្រូវកសាងឧបសម្ព័ន្ធមួយស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលក្ខន្តិកៈនៃមន្ត្រី បុគ្គលិកអគ្គលេខាធិការដ្ឋាន ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍អនុម័ត និងយកទៅអនុវត្ត ។

ប្រការ ២០ :

កំណត់ហេតុទាំងអស់ និងឯកសារដទៃទៀតរបស់ព្រឹទ្ធសភាត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋាន ហើយមិនត្រូវធ្វើអោយបែកខ្ចាត់ខ្ចាយទៅខាងក្រៅ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីប្រធានឡើយ ។

ជំពូកទី ៥
របៀបវារៈ

ប្រការ ២១ :

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នករៀបចំរបៀបវារៈនៃអង្គប្រជុំនីមួយៗ ។ នៅចុងបញ្ចប់នៃពេលប្រជុំ ប្រធានត្រូវអានរបៀបវារៈសម្រាប់អង្គប្រជុំបន្ត ។

ប្រការ ២២ :

របៀបវារៈមានជាលំដាប់មុនក្រោយដូចតទៅ :

១-បញ្ហាទាំងឡាយដែលព្រឹទ្ធសភាបានសំរេចថាទុកជាការប្រញាប់

២-បញ្ហាទាំងឡាយដែលរដ្ឋសភាជូនមកព្រឹទ្ធសភា

៣-បញ្ហាទាំងឡាយដែលរាជរដ្ឋាភិបាលជូនមកព្រឹទ្ធសភា

៤-បញ្ហាទាំងឡាយដែលគណៈកម្មការនានាជូនមកព្រឹទ្ធសភា

៥-បញ្ហាទាំងឡាយដែលសមាជិកព្រឹទ្ធសភាជូនមកព្រឹទ្ធសភា ។

ជំពូកទី ៦
របៀបសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងការពិនិត្យបញ្ហានានា

ប្រការ ២៣ :

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងបញ្ហានានាដែលរដ្ឋសភាបានដាក់អោយពិនិត្យ ត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានានោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយចែកជូនសមាជិកព្រឹទ្ធសភាទាំងអស់ ដោយភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានានោះ ទៅអោយគណៈកម្មការជំនាញពិនិត្យ ។ កាលបើពិនិត្យរួចហើយ ប្រធានគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការមកជំរាបជូនព្រឹទ្ធសភា ។

ប្រការ ២៤ :

សេចក្តីស្នើច្បាប់ដែលសមាជិកព្រឹទ្ធសភាជាអ្នកធ្វើ ត្រូវសរសេរជាលាយលក្ខណ៍អក្សរចែកជាមាត្រា ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយ ។ សេចក្តីស្នើច្បាប់នេះត្រូវបញ្ជូនទៅរដ្ឋសភាតាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ក្រោយពីបានដាក់អោយគណៈកម្មការជំនាញព្រឹទ្ធសភាផ្តល់យោបល់ ។

ប្រការ ២៥ :

អ្នកតែងសេចក្តីស្នើច្បាប់មានសិទ្ធិចូលរាយការណ៍ និងការពារចំពោះមុខគណៈកម្មការដែលពិនិត្យសេចក្តីស្នើនោះ ។

ប្រការ ២៦ :

គណៈកម្មការដែលបានទទួលពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូង ឬបញ្ហានានា អាចសុំអោយព្រឹទ្ធសភា :

- លើកចោលពុំពិចារណា
- បញ្ចេញមតិជាមុនថា តើគួរពិចារណា ឬមិនគួរ ?
- ទទួលពិចារណាហើយនឹងទុកជាការប្រញាប់ផងក៏បាន ។

ប្រការ ២៧ :

អ្នកតែងសេចក្តីស្នើច្បាប់ ឬអ្នកលើកបញ្ហានានា អាចដកសេចក្តីស្នើ ឬបញ្ហានានានោះចេញបាន ទោះបីព្រឹទ្ធសភាចាប់ពិភាក្សាហើយក៏ដោយ ។ ចំពោះសេចក្តីស្នើ ឬបញ្ហានានាដែលដកចេញ សមាជិកឯទៀតអាចសុំអោយព្រឹទ្ធសភាពិភាក្សាវិញបាន ។

ជំពូកទី ៧

វិធីការពិភាក្សាលើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់

ប្រការ ២៨ :

សមាជិកព្រឹទ្ធសភាគ្រប់រូបអាចស្នើសុំធ្វើការកែសម្រួលលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ជាលាយលក្ខណ៍អក្សរជូនទៅគណៈកម្មការជំនាញក៏បាន ឬជូនទៅព្រឹទ្ធសភាក្នុងសម័យប្រជុំពេញអង្គក៏បាន ។

ប្រការ ២៩ :

ព្រឹទ្ធសភាអាចសំរេចយល់ព្រមឬមិនយល់ព្រមយកពាក្យសុំនោះមកពិភាក្សា ។

ប្រការ ៣០ :

ព្រឹទ្ធសភាមិនអនុម័តលើការកែសម្រួលក្នុងថ្ងៃដែលទទួលពាក្យសុំនោះទេ វៀរលែងតែជាការប្រញាប់ ។

ប្រការ ៣១ :

ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ត្រូវធ្វើដូចតទៅ :

១-អង្គប្រជុំព្រឹទ្ធសភាពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថា តើគួរពិចារណាឬទេ ។

២-អង្គប្រជុំព្រឹទ្ធសភានឹងអនុម័តលើមាត្រាមួយម្តងៗក៏បាន ឬលើជំពូកមួយម្តងៗក៏បាន ។

អង្គប្រជុំព្រឹទ្ធសភាអាចប្រើនីតិវិធីពិភាក្សាសង្ខេបបាន ដោយពិភាក្សាតែមាត្រា ឬជំពូកណាដែលមានសំណើធ្វើការកែសម្រួលជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងប្រការទាំងឡាយខាងលើ ។

ក្នុងករណីដែលប្រើនីតិវិធីណាមួយខាងលើ គណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវជូនព័ត៌មានដល់សមាជិកព្រឹទ្ធសភា ។

៣-ព្រឹទ្ធសភាអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូល ។

ជំពូកទី ៨
ថវិកាព្រឹទ្ធសភា

ប្រការ ៣២ :

ព្រឹទ្ធសភាមានថវិកាស្វយ័តសំរាប់ដំណើរការរបស់ខ្លួន ។ សេចក្តីស្នើថវិការបស់ព្រឹទ្ធសភា ត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ហើយបញ្ជូនទៅក្រសួងមានសមត្ថកិច្ចដើម្បីបញ្ចូលគម្រោងក្នុងថវិកាជាតិ ។

ជំពូកទី ៩
ការបោះឆ្នោត

ប្រការ ៣៣ :

ក្នុងបញ្ហាទាំងឡាយដែលព្រឹទ្ធសភាត្រូវពិនិត្យ ព្រឹទ្ធសភាបញ្ចេញមតិដោយវិធីបីយ៉ាងគឺ :

-ដោយលើកដៃ

-ដោយបោះឆ្នោតចំហ ឬ

-ដោយបោះឆ្នោតសម្ងាត់ ។

ប្រការ ៣៤ :

ចំពោះការបញ្ចេញមតិដោយវិធីលើកដៃ ប្រធាននិងលេខាធិការទាំងឡាយជាអ្នករាប់ចំនួនសមាជិកដែលលើកដៃ ។ បើប្រធាននិងលេខាធិការយល់ឃើញថា ការរាប់លទ្ធផលមិនច្បាស់លាស់ទេនោះ ត្រូវបញ្ចេញមតិ និងរាប់សារជាថ្មី ។

ប្រការ ៣៥ :

ចំពោះការបញ្ចេញមតិដោយវិធីលើកដៃដែលបានធ្វើពីរដង ហើយនៅតែមិនបានលទ្ធផលច្បាស់លាស់ ព្រឹទ្ធសភាត្រូវប្រើវិធីបោះឆ្នោតជាចំហ ។

វិធីបោះឆ្នោតចំហត្រូវធ្វើដូចតទៅ :

-គណៈកម្មការបោះឆ្នោត កាន់ហិបឆ្នោតដើរប្រមូលយកសន្លឹកឆ្នោតពីសមាជិកព្រឹទ្ធសភា ។សមាជិកព្រឹទ្ធសភា ត្រូវសរសេរឈ្មោះខ្លួនលើសន្លឹកឆ្នោតនោះ ។សន្លឹកឆ្នោតមានបីយ៉ាង : ពណ៌ខៀវសំគាល់ការមិនព្រម ពណ៌សសំគាល់ការព្រម និងពណ៌សឆ្នូតខៀវសំគាល់អនុបវាទ ។

-ក្រោយពីបោះឆ្នោតរួចស្រេចហើយ លេខាធិការត្រូវរាប់សន្លឹកឆ្នោត ។លុះរាប់សន្លឹកឆ្នោតរួចហើយ ប្រធានព្រឹទ្ធសភាប្រកាសលទ្ធផលជូនអង្គប្រជុំ ។

ប្រការ ៣៦ :

វិធីបោះឆ្នោតចំហនៅវេទិកាប្រព្រឹត្តទៅដូចតទៅ :

-សមាជិកព្រឹទ្ធសភាម្នាក់ៗដើរយកសន្លឹកឆ្នោតមកដាក់ក្នុងហិបដែលនៅលើវេទិកា

-ព្រឹទ្ធសភាប្រើវិធីនេះបាន លុះត្រាតែមានសមាជិកព្រឹទ្ធសភា៦នាក់យ៉ាងតិចស្នើសុំ ។

ប្រការ ៣៧ :

វិធីបោះឆ្នោតសម្ងាត់ត្រូវតែប្រើក្នុងការជ្រើសតាំង ការសំដែងការទុកចិត្ត និងការអនុម័តញត្តិបន្ទោស ។

ប្រការ ៣៨ :

ការអនុម័តទាំងឡាយត្រូវយកតាមមតិភាគច្រើនដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ។ក្រៅពីនេះ មតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលត្រូវទុកជាបានការ ។

ប្រការ ៣៩ :

បើចំនួនមតិយល់ព្រម និងចំនួនមតិមិនយល់ព្រមស្មើគ្នា ការបោះឆ្នោតត្រូវធ្វើម្តងទៀត ។បើលទ្ធផលនៃការបោះឆ្នោតលើកទី២នៅតែស្មើគ្នា ព្រឹទ្ធសភាត្រូវចាត់ទុកថាជាការមិនយល់ព្រម ។

ប្រការ ៤០ :

ក្រោយពីបានឃើញលទ្ធផលនៃការបញ្ចេញមតិរួចហើយ ប្រធានព្រឹទ្ធសភាប្រកាសថា ព្រឹទ្ធសភាបានអនុម័តយល់ព្រមហើយ ឬថាព្រឹទ្ធសភាបានអនុម័តមិនយល់ព្រមទេ ។

ជំពូកទី ១០
វិធីការប្រកាសការប្រញាប់

ប្រការ ៤១ :

សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ការលើកបញ្ហានានា ឬញត្តិណាមួយដែលត្រូវបានប្រកាសជាការប្រញាប់ ត្រូវចុះក្នុងរបៀបវារៈពិភាក្សាមុនគេ ។

ប្រការ ៤២ :

ការប្រញាប់នេះអាចស្នើសុំឡើងដោយរដ្ឋសភា ដោយរាជរដ្ឋាភិបាល ដោយម្ចាស់សេចក្តីស្នើច្បាប់ ដោយអ្នកលើកបញ្ហាផ្សេងៗ ឬដោយម្ចាស់ញត្តិ ។

ព្រឹទ្ធសភាត្រូវសំរេចលើពាក្យសុំដែលមានចែងក្នុងប្រការខាងលើ ។

ប្រការ ៤៣ :

អ្នកសុំអោយប្រកាសទុកជាការប្រញាប់ត្រូវជូនហេតុផលជាលាយលក្ខណ៍អក្សរ ។ ប្រធានព្រឹទ្ធសភា នាំសេចក្តីទៅថ្លែងជំរាបព្រឹទ្ធសភា ហើយព្រឹទ្ធសភាសំរេចថាយល់ព្រម ឬមិនយល់ព្រមទុកជាការប្រញាប់ ។

ជំពូកទី ១១
វិធីរបៀបប្រជុំ

ប្រការ ៤៤ ថ្មី :

កូរ៉ុមសំរាប់ប្រជុំពេញអង្គព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក- កូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតំរូវអោយយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ- កូរ៉ុមប្រាំមួយភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតំរូវអោយយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកដែលអវត្តមានត្រូវបានចុះក្នុងបញ្ជីអវត្តមាន ។ បញ្ជីនេះត្រូវបានប្រកាសដោយប្រធានដោយបញ្ជាក់អំពីមូលហេតុផង ។

បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល ៣០នាទី ក្រោយការកំណត់ចាប់ផ្តើម ប្រធានព្រឹទ្ធសភាត្រូវផ្អាកការប្រជុំ ។

ប្រការ ៤៥ :

អាសនានុក្រមនៃសមាជិកព្រឹទ្ធសភាសាមញ្ញ ត្រូវរៀបតាមលំដាប់អាយុ ។

ប្រការ ៤៦ :

ការកំណត់ថ្ងៃប្រជុំត្រូវធ្វើជាលិខិតផ្ញើទៅជូនសមាជិកព្រឹទ្ធសភា ។ បើមានការកំណត់ដោយផ្ទាល់មាត់ក្នុងពេលប្រជុំ ការកំណត់នេះត្រូវធ្វើជាលិខិតជូនទៅសមាជិកព្រឹទ្ធសភាដែលមិនបានមកប្រជុំ ។

តាមធម្មតា ពេលប្រជុំត្រូវកំណត់យ៉ាងតិច ២ ថ្ងៃមុន វៀរលែងតែក្នុងការប្រញាប់ ។

ប្រការ ៤៧ :

លិខិតអញ្ជើញ ត្រូវមានភ្ជាប់ទៅជាមួយនូវរបៀបវារៈប្រជុំ វៀរលែងតែក្នុងការប្រញាប់ ។

ប្រការ ៤៨ :

ក្នុងពេលប្រជុំណាមួយ បើប្រធាននិងអនុប្រធានព្រឹទ្ធសភាមិននៅ ដោយមានហេតុការណ៍អ្វីជាពិសេស ព្រឹទ្ធសភាអាចជ្រើសតាំងប្រធានបណ្តោះអាសន្នមួយរូបអោយដឹកនាំការប្រជុំបន្ត ។

ប្រការ ៤៩ :

បើមានបញ្ហាត្រូវថ្លែងជរាបព្រឹទ្ធសភា ប្រធានត្រូវថ្លែងមុនចាប់ផ្តើមរបៀបវារៈ ។

ប្រការ ៥០ :

តាមធម្មតា ដំណើរការត្រូវធ្វើតាមរបៀបវារៈ វៀរលែងតែក្នុងពេលប្រជុំខ្លះដែលអង្គប្រជុំសំរេចផ្សេងពីនេះ ។

មុនចាប់ផ្តើមសម័យប្រជុំ ព្រឹទ្ធសភាអនុម័តរបៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំ ។

ប្រការ ៥១ :

បើប្រធានយល់ឃើញថាជាការមានប្រយោជន៍ ឬជាការចាំបាច់ ឬបើមានសមាជិកព្រឹទ្ធសភា៦នាក់យ៉ាងតិចស្នើសុំ ប្រធានអាចលើកពេលប្រជុំបាន ។

ប្រការ ៥២ :

សមាជិកទាំងឡាយនៃព្រឹទ្ធសភា ត្រូវសុំហើយបានទទួលសេចក្តីអនុញ្ញាតពីប្រធានជាមុនសិន ទើបនិយាយបាន ។

ប្រការ ៥៣ :

តាមធម្មតា លេខាធិការត្រូវកត់ឈ្មោះសមាជិកព្រឹទ្ធសភាដែលសុំនិយាយតាមលំដាប់មុនក្រោយ ។

ប្រការ ៥៤ :

ក្នុងការជជែកពិភាក្សា វាគ្មិនត្រូវនិយាយឆ្លាស់គ្នា អ្នកគាំទ្រនិយាយម្តង អ្នកជំទាស់និយាយម្តង ។

ប្រការ ៥៥ :

តាមគោលការណ៍ រយៈពេលនិយាយសំរាប់សមាជិកព្រឹទ្ធសភាម្នាក់ៗត្រូវមានកំណត់ ។ សមាជិកព្រឹទ្ធសភាដែលអនុញ្ញាតអោយនិយាយ ត្រូវនិយាយតែរឿងដែលកំពុងពិភាក្សា ។ បើនិយាយចាកប្រធាន ប្រធានព្រឹទ្ធសភាត្រូវរំលឹកអោយធ្វើតាមរបៀបវារៈខាងលើ ។

ប្រការ ៥៦ :

តាមធម្មតា សមាជិកព្រឹទ្ធសភាដែលបានចុះឈ្មោះសុំនិយាយ និយាយបាន ២០ នាទីយ៉ាងយូរ ។ សមាជិកព្រឹទ្ធសភាដែលគ្រាន់តែសុំឆ្លើយតប និយាយបានតែ ៥ នាទីទេ ។

បើប្រធានយល់ឃើញថាជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សានោះ ប្រធានអាចអនុញ្ញាត បន្ថែមពេល១០ នាទី ។ ការបន្ថែមនេះអាចអនុញ្ញាតអោយបន្តបានពាដងក្នុងរឿងដដែល ។

ប្រការ ៥៧ :

បទប្បញ្ញត្តិអំពីការចុះឈ្មោះសុំនិយាយជាលំដាប់គ្នា និងអំពីការកំណត់រយៈពេលនិយាយនេះ ប្រើសំរាប់តែសមាជិកព្រឹទ្ធសភា មិនប្រើសំរាប់សមាជិករាជរដ្ឋាភិបាល ឬអ្នកតំណាងទេ ។

ប្រការ ៥៨ :

បើមានការជ្រួលច្របល់ក្នុងពេលប្រជុំ ហើយប្រធានហាមពុំស្តាប់ ប្រធានអាចលើកពេលប្រជុំដោយក្រោកដើរចេញពីសាលប្រជុំ។

ប្រការ ៥៩ :

ហាមនិយាយកាត់អ្នកដទៃ និយាយវាយប្រហារលើបុគ្គល និងសំដែងអាការៈផ្សេងៗ ដែលនាំអោយខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

ជំពូកទី ១២
វិធីការរក្សាសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ

ប្រការ ៦០ :

ប្រធានព្រឹទ្ធសភាមានភារកិច្ចរក្សាការពារមិនអោយមានភ័យន្តរាយខាងក្នុងក្តី ខាងក្រៅក្តី ដែលអាចកើតមានឡើងដល់ព្រឹទ្ធសភាដោយថាហេតុ ។ ដើម្បីសំរេចភារកិច្ចនេះ ប្រធានព្រឹទ្ធសភាមានសិទ្ធិសុំអន្តរាគមន៍ពីកម្លាំងនគរបាល ឬកម្លាំងកងទ័ព ។

ប្រការ ៦១ :

ការថែរក្សាការពារសុវត្ថិភាពព្រឹទ្ធសភា ត្រូវធ្វើឡើងដោយប្រធានព្រឹទ្ធសភាក្នុងនាមព្រឹទ្ធសភា ។ ជាគោលការណ៍ ប្រធានព្រឹទ្ធសភាអាចអនុញ្ញាតអោយសាធារណជនចូលក្នុងសាលប្រជុំតាមចំនួនកន្លែងដែលមាន ។ ប៉ុន្តែបើជនណាធ្វើអោយរង្គើស ដោយវិធីណាមួយដល់អង្គប្រជុំ ប្រធានព្រឹទ្ធសភាអាចបណ្តេញជននោះចេញភ្លាម ។

ប្រការ ៦២ :

កាលបើព្រឹទ្ធសភាសំរេចថាត្រូវប្រជុំជាសម្ងាត់ ប្រធានព្រឹទ្ធសភានិងលេខាធិការត្រូវត្រួតពិនិត្យមើល អោយច្បាស់ជាមុនសិនថាពិតជាគ្មានមនុស្សដទៃក្រៅពីសមាជិកព្រឹទ្ធសភា លេខាធិការ និងឥស្សរជនដែលព្រឹទ្ធសភាត្រូវការចាំបាច់នៅក្នុងសាលប្រជុំ ។

ជំពូកទី ១៣
វិធីការខានមកប្រជុំ

ប្រការ ៦៣ :

ក្នុងពេលប្រជុំនីមួយៗ លេខាធិការស្រង់ឈ្មោះសមាជិកព្រឹទ្ធសភាដែលអវត្តមានដោយបញ្ជាក់មូលហេតុច្បាស់លាស់ ។

ប្រការ ៦៤ :

សមាជិកព្រឹទ្ធសភាមិនអាចអវត្តមានដោយមិនមានការអនុញ្ញាតពីប្រធានព្រឹទ្ធសភាបានឡើយ ។

ប្រការ ៦៥ :

ប្រធានអាចអនុញ្ញាតអោយសមាជិកព្រឹទ្ធសភាឈប់បានយ៉ាងយូរបំផុត១៥ថ្ងៃ ក្នុងសម័យប្រជុំនីមួយៗ ។ ការឈប់លើសពី១៥ថ្ងៃ ត្រូវសុំការអនុម័តពីអង្គប្រជុំ ។

ប្រការ ៦៦ :

សមាជិកព្រឹទ្ធសភាដែលអវត្តមានដោយមូលហេតុមានជម្ងឺរយៈពេលប្រាំថ្ងៃជាប់ៗគ្នា ត្រូវមានសំបុត្រពេទ្យយកមកជាសំអាង ។

ប្រការ ៦៧ :

សមាជិកព្រឹទ្ធសភាដែលអាក់ខានមកប្រជុំលើសពីបីថ្ងៃដោយគ្មានការអនុញ្ញាតត្រូវទទួលទណ្ឌកម្មខាងវិន័យ ក្រើនរំលឹក ។

ប្រការ ៦៨ :

កាលណាបានទទួលសេចក្តីអញ្ជើញមកប្រជុំតាមបទប្បញ្ញត្តិនៃប្រការ ៤៦ ហើយសមាជិកព្រឹទ្ធសភាមិនបានមកប្រជុំដោយឥតមានមូលហេតុយកជាការបាន សមាជិកព្រឹទ្ធសភានោះត្រូវទទួលទណ្ឌកម្មខាងវិន័យដូចខាងក្រោម :

ក-ការខានមកប្រជុំចំនួនបីថ្ងៃត្រូវទទួលការក្រើនរំលឹក

ខ-បើទទួលការក្រើនរំលឹកហើយ ហើយនៅតែមិនចូលមកប្រជុំ ត្រូវទទួលការក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ ។

គ-បើបានទទួលដំណឹងលើកក្រោយនេះហើយ ហើយនៅតែមិនចូលប្រជុំឬមិនផ្តល់មូលហេតុច្បាស់លាស់ត្រូវទទួលការបន្ទោសជាលាយលក្ខណ៍អក្សរ ។ ទណ្ឌកម្មខាងវិន័យនេះត្រូវប្រគល់ដល់ទីលំនៅរបស់សាម៉ីខ្លួន ។

ឃ-បើបានទទួលទណ្ឌកម្មខាងវិន័យតាមលំដាប់ទាំងពារយ៉ាងខាងលើនេះ ហើយក្នុងរវាងមួយខែក្រោយមក សមាជិកព្រឹទ្ធសភាដដែលនៅតែប្រព្រឹត្តខុសទៀត ត្រូវធ្វើទណ្ឌកម្មខាងវិន័យជាទម្ងន់ ដោយបន្ទោសជាលាយលក្ខណ៍អក្សរ ហើយប្រកាសផ្សាយដល់មហាជននៅក្នុងប្រភពចាត់តាំង ឬប្រភពជ្រើសតាំងរបស់សមាជិកព្រឹទ្ធសភាដែលបានប្រព្រឹត្តខុស ។

គណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ជាអ្នកដាក់ទណ្ឌកម្មខាងវិន័យដោយស្វ័យប្រវត្តិ កាលបើបានដឹងច្បាស់ថា មូលហេតុដែលខានមកប្រជុំនោះមិនអាចយកជាការបាន វៀរលែងតែក្នុងករណីដែលព្រឹទ្ធសភាបានទទួលពាក្យតវ៉ាសមហេតុសមផលពីសាម៉ីខ្លួនក្នុងពេលប្រជុំពេញអង្គ ។

ជំពូកទី ១៤

វិធីវិន័យក្នុងពេលប្រជុំ

ប្រការ ៦៩ :

ទណ្ឌកម្មខាងវិន័យដែលយកមកប្រើចំពោះសមាជិកព្រឹទ្ធសភាមានដូចតទៅ :

ក-ក្រើនរំលឹក

ខ-ក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ

គ-បន្ទោសជាលាយលក្ខណ៍អក្សរ

ឃ-បន្ទោសជាលាយលក្ខណ៍អក្សរ ហើយបណ្តេញចេញមួយរយៈពេលពីសាលប្រជុំ ។

ប្រការ ៧០ :

ប្រធានព្រឹទ្ធសភា ត្រូវក្រើនរំលឹកវាគ្មិនណាដែលប្រព្រឹត្តខុស ឬសមាជិកព្រឹទ្ធសភាណាដែលធ្វើអោយខូចសណ្តាប់ធ្នាប់ ដោយល្មើសនឹងបទប្បញ្ញត្តិប្រការ៥៩នៃបទបញ្ជាផ្ទៃក្នុង ។

ប្រការ ៧១ :

សមាជិកព្រឹទ្ធសភាណាដែលត្រូវក្រើនរំលឹកមួយដងហើយ ហើយនៅតែប្រព្រឹត្តខុសដដែលទៀត នៅក្នុង ពេលប្រជុំតែមួយនោះ ប្រធានព្រឹទ្ធសភាត្រូវក្រើនរំលឹកម្តងទៀត ដោយចុះសេចក្តីក្រើនរំលឹកនោះទុកក្នុងកំណត់ហេតុនៃអង្គប្រជុំ ។

ប្រការ ៧២ :

សមាជិកព្រឹទ្ធសភា ដែលត្រូវទទួលការបន្ទោសជាលាយលក្ខណ៍អក្សរនោះគឺ :

ក-សមាជិកព្រឹទ្ធសភាណា ដែលប្រធានបានក្រើនរំលឹក ព្រមទាំងចុះសេចក្តីក្នុងកំណត់ហេតុហើយ ហើយនៅតែមិនរាងចាល

ខ-សមាជិកព្រឹទ្ធសភាណា ដែលត្រូវបានក្រើនរំលឹកបីដងហើយ ហើយនៅតែធ្វើខុសដដែលក្នុងវេលា ៣០ ថ្ងៃ

គ-សមាជិកព្រឹទ្ធសភាណា ដែលនាំអាទិ៍អោយមានការជ្រួលច្របល់ក្នុងសាលប្រជុំ ឬនាំអាទិ៍សមាជិកព្រឹទ្ធសភាច្រើនគ្នា កុំអោយធ្វើការក្នុងព្រឹទ្ធសភា

ឃ-សមាជិកព្រឹទ្ធសភាណា ដែលជេរប្រមាថមើលងាយ ឬបង្កជម្លោះ ឬគំរាមកំហែង សមាជិកព្រឹទ្ធសភាឯទៀត ។

ប្រការ ៧៣ :

សមាជិកព្រឹទ្ធសភាដែលត្រូវទទួលការបន្ទោសជាលាយលក្ខណ៍អក្សរ ហើយបណ្តេញចេញមួយរយៈពេល ពីអង្គប្រជុំគឺ :

ក-សមាជិកព្រឹទ្ធសភាណា ដែលត្រូវទទួលការបន្ទោស ហើយនៅតែមិនរាងចាល

ខ-សមាជិកព្រឹទ្ធសភាណា ដែលញុះញង់អោយប្រើហឹង្សា

គ-សមាជិកព្រឹទ្ធសភាណា ដែលជេរប្រមាថមើលងាយព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា

ឃ-សមាជិកព្រឹទ្ធសភាណា ដែលប្រព្រឹត្តខុស ដោយប្រមាថមើលងាយព្រះមហាក្សត្រ ។

ប្រការ ៧៤ :

ការបន្ទោសជាលាយលក្ខណ៍អក្សរ ឬការបន្ទោសជាលាយលក្ខណ៍អក្សរហើយបណ្តេញចេញផង ត្រូវអនុម័តដោយព្រឹទ្ធសភា តាមវិធីបោះឆ្នោតជាសម្ងាត់ដោយមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល តាមសេចក្តីស្នើពីប្រធានព្រឹទ្ធសភា ។

ប្រការ ៧៥ :

ការបន្ទោសជាលាយលក្ខណ៍អក្សរ ត្រូវប្រកាសផ្សាយជាសាធារណៈនូវសំរង់កំណត់ហេតុបន្ទោស ព្រមទាំងយកទៅបោះពុម្ព ហើយបិទនៅក្នុងប្រភពចាត់តាំង ឬប្រភពជ្រើសតាំងរបស់សមាជិកព្រឹទ្ធសភាដែលមានកំហុស ។

ប្រការ ៧៦ :

ការបន្ទោសជាលាយលក្ខណ៍អក្សរហើយបណ្តេញផង ត្រូវទទួលទណ្ឌកម្មដូចតទៅ :

ក-ប្រកាសផ្សាយជាសាធារណៈនូវសំរង់កំណត់ហេតុបន្ទោស ព្រមទាំងយកទៅបោះពុម្ពហើយបិទនៅក្នុងប្រភពចាត់តាំង ឬប្រភពជ្រើសតាំងរបស់សមាជិកព្រឹទ្ធសភាដែលមានកំហុស ។

ខ-ហាមចូលធ្វើការក្នុងព្រឹទ្ធសភាអស់រយៈ១៥ពេលប្រជុំជាបន្តបន្ទាប់ ។

ជំពូកទី ១៥
វិធីការស្នើកែប្រែបទបញ្ជាផ្ទៃក្នុង នៃព្រឹទ្ធសភា

ប្រការ ៧៧ :

បទបញ្ជាផ្ទៃក្នុងនេះនឹងទទួលការកែប្រែបានលុះត្រាតែមានសេចក្តីស្នើសុំពីសមាជិកព្រឹទ្ធសភាមួយភាគបួនយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ហើយត្រូវមានការអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនពីរភាគ បីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ជំពូកទី ១៦
អន្តរប្បញ្ញត្តិ

ប្រការ ៧៨ :

អាសនៈរបស់សមាជិកព្រឹទ្ធសភាដែលនៅទំនេរ ដោយសុំលាលែង ដោយបោះបង់ចោលការងារចំនួន ៣ខែ គ្មានការអនុញ្ញាត ឬដោយទទួលមរណភាព ត្រូវបំពេញជំនួសដោយចាត់តាំង ឬជ្រើសតាំងសមាជិកព្រឹទ្ធសភាថ្មីចេញពីប្រភពដើម ដែលមានអាសនៈទំនេរនោះ ។

ប្រការ ៧៩ :

សំរាប់នីតិកាលទី១នេះ បុគ្គលិកនៃអគ្គលេខាធិការដ្ឋានទាំងអស់ត្រូវតែងតាំង ដោយប្រធានព្រឹទ្ធសភា ក្រោយពីមានការឯកភាពពីអនុប្រធានទាំងពីរតាមសេចក្តីស្នើរបស់អគ្គលេខាធិការ ។

ប្រការ ៨០ :

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូងនៃនីតិកាលទី១ក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរ ក្រោយពីមានព្រះរាជក្រឹត្យតែងតាំងសមាជិកទាំងមូលតាមការកោះប្រជុំរបស់ប្រធានព្រឹទ្ធសភាដែលបានទទួលការតែងតាំងពីព្រះមហាក្សត្រ ។

ការបើកសម័យប្រជុំលើកទី ១ នីតិកាលទី ១ កាលពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ ទុកជាបានការ ។

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវបានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័ត
នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ១៩៩៩ នាសម័យប្រជុំលើកទី១ នីតិកាលទី១ ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ១៩៩៩

ប្រធានព្រឹទ្ធសភា

ហត្ថលេខា និងត្រា : ជា ស៊ីម

ឧបសម្ព័ន្ធ ២

ព្រះរាជក្រម

នស/រកម/០៦០៥/០២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី៣ និងព្រឹទ្ធសភា បានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ ព្រមទាំងក្រុមប្រឹក្សាធម្មនុញ្ញ បានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៧០/០០២/ ២០០៥/កបធ.ច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ:

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ។

មាត្រា ២.-

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៣.-

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់ដំណែង ។

មាត្រា ៤.-

សមាជិកព្រឹទ្ធសភាចំនួន០២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

មាត្រា ៥.-

សមាជិកព្រឹទ្ធសភាចំនួន០២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។

មាត្រា ៦.-

សមាជិកព្រឹទ្ធសភាឯទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកលមិនចំពោះ តាមវិធីជ្រើសរើស ឆ្នោតជាសម្ងាត់ ។

ជំពូកទី ២

ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត ការបែងចែកអាសនៈ អ្នកបោះឆ្នោត អង្គបោះឆ្នោត បញ្ជីអ្នកបោះឆ្នោត និងការិយាល័យបោះឆ្នោត

មាត្រា ៧.-

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវធ្វើឡើង ៦(ប្រាំមួយ) ឆ្នាំម្ដង នៅថ្ងៃអាទិត្យសប្ដាហ៍ទី៤ មុនដំណាច់ឆ្នាំទី៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា១០២ថ្មី នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ៨.-

ការបោះឆ្នោតត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈតាមមណ្ឌល ត្រូវធ្វើតាមរូបមន្ត មធ្យមភាគខ្ពស់បំផុត ដូចមានកំណត់ក្នុងមាត្រា១១៨ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

មាត្រា ៩.-

មណ្ឌលបោះឆ្នោតត្រូវរៀបចំជាភូមិភាគដែលមានតារាងកំណត់ដូចខាងក្រោម :

- ភូមិភាគទី ១ ក្រុងភ្នំពេញ
- ភូមិភាគទី ២ ខេត្តកំពង់ចាម
- ភូមិភាគទី ៣ ខេត្តកណ្ដាល
- ភូមិភាគទី ៤ ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន
- ភូមិភាគទី ៥ ខេត្តតាកែវ កំពត និងក្រុងកែប

- ភូមិភាគទី ៦ ខេត្តព្រៃវែង និងស្វាយរៀង

- ភូមិភាគទី ៧ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ កោះកុង និងក្រុងព្រះសីហនុ

- ភូមិភាគទី ៨ ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី

មាត្រា ១០.-

០៦ខែ យ៉ាងតិចមុនចប់នីតិកាល ព្រឹទ្ធសភាត្រូវអនុម័តកំណត់ចំនួនអាសនៈ និងការបែងចែកអាសនៈ តាមភូមិភាគនីមួយៗ សម្រាប់នីតិកាលបន្ទាប់ ហើយត្រូវផ្សព្វផ្សាយជាសាធារណៈ ។

ក្នុងករណីខកខានពុំបានកំណត់ជាថ្មីនូវអាសនៈក្នុងព្រឹទ្ធសភា ចំនួនអាសនៈតាមភូមិភាគនោះ ត្រូវយកតាមចំនួនអាសនៈក្នុងព្រឹទ្ធសភាដែលមានក្នុងនីតិកាលចុងក្រោយ ។

មាត្រា ១១.-

អ្នកបោះឆ្នោត និងអង្គបោះឆ្នោតគឺតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ ក្នុងតំណែងនៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។

មាត្រា ១២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីអ្នកបោះឆ្នោត និងផ្តល់សុពលភាពលើបញ្ជីនេះ យ៉ាងតិច១៥ថ្ងៃមុនថ្ងៃបោះឆ្នោត ។ បញ្ជីអ្នកបោះឆ្នោត ដែលត្រូវបានផ្តល់សុពលភាពហើយមិនអាចកែប្រែបាន ទេ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតដំបូងយ៉ាងតិច៤៨ (សែសិបប្រាំបី) ថ្ងៃមុនថ្ងៃបោះឆ្នោត នៅទីប្រជុំជនខេត្ត-ក្រុង ។

មាត្រា ១៣.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំការិយាល័យបោះឆ្នោត ការិយាល័យរាប់សន្លឹកឆ្នោត នៅទីប្រជុំជនខេត្ត-ក្រុងនីមួយៗ ។

ជំពូកទី ៣

ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

និង បញ្ជីបេក្ខជនឈរឈ្មោះ

មាត្រា ១៤.-

ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវចាប់ផ្តើម៩០(កៅសិប) ថ្ងៃមុនថ្ងៃ បោះឆ្នោត ។

មាត្រា ១៥.-

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវធ្វើបញ្ជីរាយនាមបេក្ខជនពេញសិទ្ធិស្មើនឹងចំនួនអាសនៈនៃភូមិភាគនីមួយៗ និងបេក្ខជនបម្រុងមានចំនួនស្មើនឹងបេក្ខជនពេញសិទ្ធិរៀបតាមលំដាប់លេខរៀងដូចជារៀបចំបញ្ជីបេក្ខជនតំណាងរាស្ត្រដែរ ។

មាត្រា ១៦.-

បែបបទ លក្ខខណ្ឌនិងនីតិវិធីទាំងឡាយស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តសម្រាប់ការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា ។

ជំពូកទី៤

បេក្ខជនសមាជិកព្រឹទ្ធសភា

មាត្រា ១៧.-

មាត្រា៣៣ថ្មី ៣៤ថ្មី ៣៥ថ្មី ៣៦ថ្មី ៣៧ថ្មី ៣៨ថ្មី និងមាត្រា៣៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦-១២-១៩៩៧ និងព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧-០៩-២០០២ ត្រូវយកមកអនុវត្តចំពោះបេក្ខជនសមាជិកព្រឹទ្ធសភា ប៉ុន្តែបេក្ខជននេះត្រូវមានអាយុយ៉ាងតិច ៤០ (សែសិប) ឆ្នាំ ។

ជំពូកទី ៥

ការឃោសនាបោះឆ្នោត

មាត្រា ១៨.-

ការឃោសនាបោះឆ្នោតមានទិសដៅឱ្យបេក្ខជន និងគណបក្សនយោបាយដែលបានចុះបញ្ជីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត ។

មាត្រា ១៩.-

យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល២១(ម្ភៃមួយ) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត ។

មាត្រា ២០.-

មាត្រា ៧១ ៧៣ ៧៤ ៧៥ ៧៦ ៧៧ ៨០ ៨១ ៨២ និងមាត្រា៨៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ៦

តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

មាត្រា ២១.-

មាត្រា២៦ថ្មី ២៧ ២៨ និងមាត្រា២៩ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការសង្កេតការណ៍នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ៧
ការគ្រប់គ្រងការបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត
និង ការបូកសរុបលទ្ធផលនៃការបោះឆ្នោត

មាត្រា ២២.-

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោត ។

មាត្រា ២៣.-

តាមរយៈក្របខ័ណ្ឌនៃអំណាចដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចកំណត់បទបញ្ជា និងនីតិវិធីពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភាបន្ថែមលើភារកិច្ចបច្ចុប្បន្ននេះ ។

មាត្រា ២៤.-

ការបោះឆ្នោតត្រូវធ្វើតែមួយថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោង ៧:០០(ប្រាំពីរ) ព្រឹករហូតដល់ម៉ោង ១៥:០០(ដប់ប្រាំ) លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះគ្រប់គ្នាហើយ គណៈកម្មការការិយាល័យបោះឆ្នោតអាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោង ១៥:០០ (ដប់ប្រាំ) ។

ប្រធានការិយាល័យបោះឆ្នោត ត្រូវប្រកាសបិទការបោះឆ្នោតនៅម៉ោង ១៥:០០ (ដប់ប្រាំ) ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោតមិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណខាងក្នុងក្រោយម៉ោង ១៥:០០ (ដប់ប្រាំ) ឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោង ១៥:០០(ដប់ប្រាំ) ហើយអាចអនុញ្ញាតអោយបោះឆ្នោតគឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោង ១៥:០០(ដប់ប្រាំ) ។

មាត្រា ២៥.-

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវទទួលខុសត្រូវរាប់សន្លឹកឆ្នោតនៅនឹងកន្លែងក្រោយការប្រកាសបញ្ចប់ការបោះឆ្នោត ។

មាត្រា ២៦.-

គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត ត្រូវបញ្ជូនកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតនៅក្នុងខេត្ត-ក្រុងរបស់ខ្លួនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបូកសរុបលទ្ធផលតាមភូមិភាគនីមួយៗ ។

មាត្រា ២៧.-

បែបបទ នីតិវិធីផ្សេងៗទៀតនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ៨
សមត្ថកិច្ចដោះស្រាយការវិវាទ ស្តីពីការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា

មាត្រា ២៨.-

គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោតជាអ្នកសម្រេចដំបូងបង្អស់លើការវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ក្នុងករណីមានបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមត្ថកិច្ចពិនិត្យ និងសម្រេច ។

មាត្រា ២៩.-

ក្នុងករណីមានបណ្តឹងជំទាស់នឹងមានសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចចុងក្រោយបិទផ្លូវតវ៉ាលើការវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

មាត្រា ៣០.-

នីតិវិធីដោះស្រាយការវិវាទដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការដោះស្រាយការវិវាទស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ការរាប់ចំនួនថ្ងៃតវ៉ានិងការសម្រេចលើបណ្តឹងតវ៉ា ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

ជំពូកទី ៩
ករណីជ្រើសតាំងជំនួសសមាជិកព្រឹទ្ធសភា

មាត្រា ៣១.-

សមាជិកព្រឹទ្ធសភាត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោម :

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិកព្រឹទ្ធសភា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកព្រឹទ្ធសភាណាមួយត្រូវបាត់បង់សមាជិកភាព មានរយៈពេល៦(ប្រាំមួយ)ខែ យ៉ាងតិច មុនចប់នីតិកាល សាមីគណបក្សនយោបាយនោះអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះតាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ ។

ជំពូកទី ១០
ជម្ពិកា

មាត្រា ៣២.-

មាត្រា ១២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ១១
ទោសប្បញ្ញត្តិ

មាត្រា ៣៣.-

មាត្រា១២៤ថ្មី ១២៥ថ្មី ១២៦ថ្មី ១២៧ថ្មី ១២៨ថ្មី ១២៩ថ្មី ១៣០ថ្មី ១៣១ និងមាត្រា១៣៣ នៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ១២

អន្តរប្បញ្ញត្តិ

មាត្រា ៣៤.-

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសំរាប់នីតិកាលទី ២ នៃព្រឹទ្ធសភាត្រូវប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី២២ ខែ មករា ឆ្នាំ២០០៦ ។

មាត្រា ៣៥.-

ក្រោយពីច្បាប់នេះចូលជាធរមាន ដើម្បីការបោះឆ្នោតនៅថ្ងៃអាទិត្យ ទី២២ ខែមករា ឆ្នាំ២០០៦ ចំនួនអាសនៈនៃព្រឹទ្ធសភាដែលត្រូវបោះឆ្នោតជ្រើសតាំងត្រូវកំណត់ត្រឹម ៥៧(ហាសិបប្រាំពីរ) ។ ចំនួនអាសនៈតាមភូមិ ភាគមានដូចខាងក្រោម :

- ភូមិភាគទី ១	ក្រុងភ្នំពេញ	មាន ៦ អាសនៈ
- ភូមិភាគទី ២	ខេត្តកំពង់ចាម	មាន ៨ អាសនៈ
- ភូមិភាគទី ៣	ខេត្តកណ្តាល	មាន ៥ អាសនៈ
- ភូមិភាគទី ៤	ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន	មាន ១០ អាសនៈ
- ភូមិភាគទី ៥	ខេត្តតាកែវ កំពត និងក្រុងកែប	មាន ៧ អាសនៈ
- ភូមិភាគទី ៦	ខេត្តព្រៃវែង និងស្វាយរៀង	មាន ៧ អាសនៈ
- ភូមិភាគទី ៧	ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងក្រុងព្រះសីហនុ	មាន ៨ អាសនៈ
- ភូមិភាគទី ៨	ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និង មណ្ឌលគិរី	មាន ៦ អាសនៈ

ចំនួនអាសនៈនេះត្រូវផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ ។

ជំពូកទី ១៣
អវសានប្បញ្ញត្តិ

មាត្រា ៣៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៧.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០០៥

នស/រកម/០៦០៥/០១៥ *(printed: ពរល.០៥០៦.៣០០)*

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសព្វព្រះរាជហឫទ័យ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និង ព្រះរាជលញ្ឆករ

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ : ២៥០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ហត្ថលេខា និងត្រា : ឈាង ណាន់

ផែនទីប្រទេសក

ប្រទេសថៃឡង់
THAILAND
ឧត្តរមានជ័យ
ODDAR MEANCHEY
បន្ទាយមានជ័យ
BANTEAY MEANCHEY
សៀមរាប
SIEM REAP
ភូមិភាគទី ៤
បាត់ដំបង
BATTAMBANG
ប៉ៃលិន
PAILIN
ពោធិ៍សាត់
PURSAT
កំពង់ឆ្នាំង
KAMPONG CHHNANG
ភូមិភាគទី ៧
កោះកុង
KOH KONG
កំពង់ស្ពឺ
KAMPONG SPEU
GULF OF THAILAND
កំពត
KAMPOT

ចែកជាភូមិភាគ


ប្រទេសឡាវ
LAOS
ស្ទឹងត្រែង
រតនៈគិរី
មណ្ឌលគិរី
ក្រចេះ
កំពង់ចាម
ស្វាយរៀង
ប្រទេសវៀតណាម
VIET NAM

អ្នកគ្រប់គ្រងទូទៅ

១. ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា

២. ឯកឧត្តម **ញឹក នៃអេង** អគ្គលេខាធិការរងព្រឹទ្ធសភា

គណៈកម្មការកសាងសមិទ្ធផលព្រឹទ្ធសភា នីតិកាលទី១ (១៩៩៩-២០០៥)

១. ឯកឧត្តម **គីម លី** ប្រធាន

២. លោក **សុខ រិទ្ធី** អនុប្រធាន

៣. លោកស្រី **ជា គីម** សមាជិក

៤. លោកស្រី **សួន ពុធថាវី** សមាជិក

៥. លោក **សោម សាវុធ** សមាជិក

៦. លោក **ទេព ច័ន្ទអុនវុឌ្ឍិរក្ស** សមាជិក

៧. លោក **ជួន ណារ** សមាជិក

ក្រុមវាយអត្ថបទ និងរចនារូបភាព

១. លោក **ទេព មករា**

២. លោក **ឡុង សុខា**